01390813

E1/507.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៤៨៤**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Feb-2017, 14:53
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ម៉ាដាលេណា ហ្គេហ្សុី
*(Ms.Maddalena Ghezzi)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ(Mr.Victor KOPPE)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វែនស៍ | អង់គ្លេស |
| លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| កញ្ញា លី និមល (មន្ត្រីអង្គភាពគាំពារសាក្សី) | ខ្មែរ |
| សាក្សី 2-TCW-920 | ខ្មែរ |
| លោក នួន ត្រិច (2-TCW-1060) | ខ្មែរ |

## ខ្លឹមសារ ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖** 2-TCW-920

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ៣
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........................................ ទំព័រ ៦

**ការសួរសំណួរទៅសាក្សី៖ លោក នួន ត្រិច/ ទេស ត្រិច** (2-TCW-1060)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........................................ ទំព័រ ៤៨
សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........................................ ទំព័រ ៦១

# កិច្ចដំណើរការនីតិវិធី

[០៩:០២:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-920 តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបង។ ហើយនិងថ្ងៃនេះ ក៏មានសាក្សីបម្រុងឈ្មោះ នួន ត្រិច ដែលបានធ្វើសវនាការកាលពីម្សិលមិញ ហើយថ្ងៃនេះ គឺអង្គជំនុំជម្រះនាំយកគាត់ កោះគាត់មកចូលរួមក្នុងនាមជាសាក្សីបម្រុង។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គល ដែលអង្គជំនុំជម្រះ កោះអញ្ជើញឲ្យចូលរួមកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោកស្រី ម៉ារី ហ្គីរ៉ូដ៍ សហមេធាវីនាំអន្តរជាតិ តំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអវត្តមាននៅសវនាការវគ្គទី១ ព្រឹកនេះ ដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-920។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ ហើយសាក្សីបានធ្វើសម្បថរួចហើយ កាលពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦។

[០៩:០៣:៥៩]

សាក្សីនឹងផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបង ហើយសាក្សីមានមេធាវីព្រឹកប្រឹក្សា គឺលោក ម៉ម រិទ្ធា។ ហើយសាក្សីបម្រុងនៅថ្ងៃនេះ គឺលោក នួន ត្រិច។ លោកមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ តាមការជូនដំណឹងមក គឺប្រព័ន្ធសោតទស្សន៍បាន

រៀបចំរួចរាល់អស់ហើយហើយសាក្សីបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្តល់សក្ខីកម្មនៅព្រឹកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦។

[០៩:០៤:៥៧]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ និងវិលមុខពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាត ឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយមុននឹងស្តាប់សក្ខីកម្មសាក្សី 2-TCW-920 អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សីរូបនេះត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង តើចៅក្រមស៊ើប

អង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះ ស្ថិតនៅក្នុងក្រុម(ក)នៃក្រុមទាំងបីប្រភេទ នៅក្នុងអនុស្សរណៈរបស់ខ្លួន ឯកសារ E319/35 ហើយបានស្នើថាសាក្សីរូបនេះ គួរប្រើរហស្សនាមក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចការស៊ើបអង្កេត។ អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលកម្រិតបែបនេះ គឺត្រឹមត្រូវសមស្របតាមច្បាស់នៅក្នុងករណីជាក់ស្តែងបែបនេះ ហើយការបង្គាប់នេះគឺត្រូវធ្វើឲ្យមានតុល្យភាពគ្នា រវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងសុច្ចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីផងដែរថា សូមឲ្យគោរពនិងអនុវត្តឲ្យខ្ជាប់ខ្ជួននៅសេចក្តីណែនាំក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។ ហើយតាមសំណើសុំរបស់មេ -- របស់សាក្សី អង្គជំនុំជម្រះបានសម្រុះសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ បានផ្តល់មេធាវីប្រឹក្សាជួយដល់សាក្សីក្នុងអំឡុងពេលផ្តល់សក្ខីកម្មរួចហើយ គឺលោកមេធាវី ម៉ម រិទ្ធា។

[០៩:០៧:៤៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! សួស្តីលោកសាក្សី! លោកសាក្សីបានត្រៀមខ្លួនរួចហើយឬនៅ?

**2-TCW-920៖**

**ឆ៖** រួចហើយៗ។

**ស៖** បាទ អរគុណ។ ហើយនៅក្នុងដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើរបស់សហចៅក្រមស៊ើបអង្កេត យើងបានប្រើប្រាស់តែរហស្សនាមរបស់លោកទេ។ ហើយរហស្សនាមរបស់លោកគឺ សាក្សី 2-TCW-920 ហើយជាទូទៅភាគី និងតែងតែប្រើប្រាស់ ហៅលោកក្នុងនាមថាលោកសាក្សីតែប៉ុណ្ណោះ។ អ៊ីចឹងហើយសូមលោកយល់ថា អង្គជំនុំជម្រះនិងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធ រួមទាំងចៅក្រមនៃអង្គជំនុំជម្រះខ្លួនឯងផង មិនឲ្យប្រើនាមត្រកូលនិងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះទេ។

បាទ ហើយដោយសារតែគាត់មានអាយុច្រើនហើយ ហើយសាក្សីគាត់អាចមើលឃើញនិងអាចអានអក្សរបានដែរ តែទោះយ៉ាងនេះក្តី អង្គជំនុំជម្រះក៏សូមឲ្យលោកមេធាវីប្រឹក្សាលោក ម៉ម រិទ្ធា ជួយគាត់ផង បើសិនបើគាត់ត្រូវការជំនួយ តែបើសិនជាគាត់ត្រូវការជំនួយសូមធ្វើខ្សឹបៗបានហើយ។ ហើយ

លោក ម៉ម រិទ្ធា ចូរលោកហុចនៅឯកសារដែលយើងបានរៀបចំ ក្រឡាបញ្ជីបានរៀបចំជូនលោករួច ហើយជូនទៅគាត់គឺឯកសារ E3/9473 ដែលមានលេខ ERNជាភាសាខ្មែរ 00945416, ERN ជាភាសាអង់គ្លេស 00976956 និង ERN ជាភាសាបារាំង 00967262។ ហើយជូនទៅសាក្សីពិនិត្យ ហើយសូមពិនិត្យ ហើយលោកសាក្សីសូមពិនិត្យមើលកន្លែងដែលមានហាយឡាយពណ៌ទឹកក្រូច ថាតើត្រង់នាមត្រកូលនិងនាមខ្លួនរបស់លោក សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុក ឈ្មោះម្ដាយ ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោក ពិតជាត្រឹមត្រូវដែរឬទេ? ហើយបើសិនលោកពិនិត្យមើលរួចហើយគ្រាន់តែឆ្លើយថា ត្រឹមត្រូវឬមិនត្រឹមត្រូវត្រង់ចំណុចណាបានហើយ។

**ឆ៖** ត្រឹមត្រូវហើយៗ។

**ស៖** បាទ អរគុណ។ ហើយលោកសាក្សី តាមរបាយការណ៍ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជា បុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយៗ។

**ស៖** ហើយតើលោកបានធ្វើសម្បថតាមជំនឿសាសនារបស់លោករួចហើយឬនៅ? លោកសាក្សីតើលោកបានធ្វើសម្បថតាមជំនឿសាសនារបស់លោករួចហើយឬនៅ មុននឹងមកអង្គុយផ្ដល់សក្ខីកម្មនៅទីនោះ?

**ឆ៖** បាទ ទទួលអស់ហើយ។

**ស៖** បាទ អរគុណ ហើយជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីដែលត្រូវផ្ដល់សក្ខីកម្មដល់អង្គជំនុំជម្រះ។ អំពីសិទ្ធិ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ គឺលោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬអត្ថាធិប្បាយណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយអំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរៀបរាប់ នាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ ហើយក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮបាន

01390821



ឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរដែលភាគីសួរចំពោះលោក។ លោកសាក្សី តើលោកធ្លាប់បានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះដែរឬទេ ក្នុងរយៈពេលកន្លងមក?

[០៩:១៣:២៣]

**ឆ៖** បាទ ធ្លើរួចហើយ តាមដានបាន ស្ដាប់បាន តាមដានស្ដាប់ដែរ។

**ស៖** លោកដែលបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃតុលាការខ្មែរក្រហមនេះដែរឬទេ លោកសាក្សី?

**ឆ៖** បាទ។

**ស៖** ហើយមុនមកអង្គុយនៅទីនោះ តើលោកសាក្សីបានអាន ឬក៏បានស្ដាប់ការអានពីបុគ្គលណាម្នាក់អំពីកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុន ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ចាំបាន។

**ស៖** តាមការចងចាំរបស់លោកសក្ខីកម្មដែលលោកអានដើម្បីរំឭកការចងចាំហ្នឹង វាសមស្របវាដូចគ្នាទៅនឹងអ្វីដែលលោកបានផ្ដល់ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលលើកមុនដែរឬទេ?

**ឆ៖** បាទ *(ឮមិនច្បាស់)* ស្របបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយតាមព័ត៌មានគឺ ដោយសារមូលហេតុសាក្សីមានវ័យចាស់ អាយុជិត៩៣ឆ្នាំហើយ ហើយគាត់និយាយតិចពិបាកស្ដាប់។ ដូច្នេះ សូមភាគីដែលតាំងសំណួរ សូមតាំងឲ្យច្បាស់លាស់ ហើយឲ្យខ្លីៗងាយយល់ ដើម្បីសាក្សីអាចស្ដាប់យល់ និងអាចឆ្លើយតបបាន។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។

[០៩:១៦:០៧]

**លោក វាំងសង់ វ៉ាយដ៍ ដេស្លាឯល៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រុម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្លាឯល៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ វ៉ាំសង់ ដឺវីល ខ្ញុំនឹងសួរសំណួរទៅកាន់លោក តាំងនាមឱ្យការិយាល័យសហព្រះរាជអាជ្ញានៅព្រឹកនេះ។ បើលោកមិនយល់សំណួរណាមួយ សូមលោកប្រាប់ខ្ញុំឱ្យសួរឡើងវិញ ហើយសូមឱ្យលោកឆ្លើយខ្លីៗច្បាស់ៗ។ បើខ្ញុំចង់បានព័ត៌មានលម្អិត ខ្ញុំនឹងសួរបន្ថែម។ ដូច្នេះសូមលោកឆ្លើយឱ្យចំៗទៅនឹងសំណួររបស់ខ្ញុំបានហើយ កុំឆ្លើយវែងឆ្ងាយពេក។ ខ្ញុំដឹងថា ហេតុការណ៍នោះវាបានកើតឡើងជាយូរណាស់មកហើយ អ៊ីចឹងលោកប្រហែលជាពិបាកក្នុងការចងចាំបន្តិច អ៊ីចឹងបើលោកមិនចាំទេ លោកប្រាប់ខ្ញុំទៅថា មិនចាំទេ ប៉ុណ្ណឹងទៅបានហើយ។

[០៩:១៧:០៤]

ខ្ញុំមានប្រធានបទជាច្រើនដែលត្រូវសួរលោក។ ដំបូង ខ្ញុំសូមសួរលោកអំពីប្រវត្តិលោក មុនពេលខ្មែរក្រហមវាយយកទីក្រុងភ្នំពេញបាន។ ជាពិសេស ក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ និង៦០ គឺការងារលោកជាមួយនឹង រស់ ញឹម និង នួន ជា។ ក្រោយមកទៀត ខ្ញុំនឹងសួរអំពីមុខងាររបស់លោក ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ហើយខ្ញុំនឹងផ្តោតទៅលើការចាប់ខ្លួនមនុស្សដែលបានកើតឡើងនៅក្នុងភូមិភាគពាយ័ព្យ មុន និងក្រោយពេលគេចាប់ខ្លួន រស់ ញឹម។ ជាដំបូងក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ និង ៦០ លោកអាចជម្រាបបានទេថា លោកចូលបដិវត្តន៍នៅពេលណា? ហើយលោកធ្វើការឱ្យមេដឹកនាំមួយណាដែរ?

**2-TCW-920៖**

**ឆ៖** ខ្ញុំបដិវត្តតាំងពី១៩៥០ ៦០ – ៦៦។ បាទ ចូលធ្វើបដវិត្តន៍ គឺតាំងពីឆ្នាំ៦៦។

**ស៖** នៅក្នុងចម្លើយពីមុនរបស់លោក លោកថា ក្នុងឆ្នាំ៥០។ អ៊ីចឹងប្រហែលជាលោកអាចច្រឡំថា ៦៦ ហើយនិង ៥៦ <>ឬក៏យ៉ាងម៉េច? ជាពិសេសក្នុងឯកសារ E3/9473នេះ នៅក្នុងចម្លើយទី២ នោះ លោកថា លោកចូលខ្មែរឥស្សរៈនុំងនៅឆ្នាំ រហូតទៅដល់ឆ្នាំ១៩៥៤។ ហើយក្រោយមក លោកចូលក្នុងសមាជិកបក្សខ្មែរក្រហម ក្នុងឆ្នាំ១៩៥៦ តាមរយៈ តាផាត ជាអ្នកចាត់តាំងលោកឱ្យចូលនោះ។ អ៊ីចឹងសូមលោកបញ្ជាក់ម្តងទៀតទៅមើល ៥៦ ឬក៏<៦៦> ពេលដែលលោកចូលបដិវត្តន៍នោះ?

[០៩:១៩:២៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចូលតាំងពីឆ្នាំហាជាងទៅ គឺត្រឹមសម័យឥស្សរៈ។ ក្រោយមកបានឆ្នាំប្រហែល៦៦នោះចូលខ្មែរក្រោម -- ខ្មែរក្រហមយើងនេះ។

**ស៖** តើលោកមានបានធ្វើការជាមួយ រស់ ញឹម និង នួន ជា ទេ? ហើយបើបានធ្វើការ ធ្វើការនៅពេលណាជាមួយអ្នកទាំងពីរហ្នឹង?

**ឆ៖** ធ្វើការ រស់ ញឹម និង នួន ជា ហ្នឹងយូរហើយ ព្រោះគេឲ្យខ្ញុំជាអ្នករត់សារពីភ្នំពេញមកបាត់ដំបង ពីបាត់ដំបងទៅភ្នំពេញ។

**ស៖** អ្នកណាជាអ្នកចាត់ឲ្យលោកធ្វើជានីរសារនាំសំបុត្រពីភ្នំពេញទៅបាត់ដំបងហ្នឹង?

**ឆ៖** កាលនោះ នែ! តា រស់ ញឹម។

**ស៖** <ចុះនៅឯភ្នំពេញ តើលោកប្រគល់សំបុត្រជូនទៅនរណា?>

**ឆ៖** ភ្នំពេញៗ --

**ស៖** ចាប់ពីពេលណាដែលលោកធ្វើជានីរសារឲ្យ នួន ជា និង រស់ ញឹម? ហើយលោកធ្វើរហូតទៅដល់ពេលណា?

[០៩:២១:៣៩]

**ឆ៖** តាំងពីឆ្នាំហុក -- តាំងពីឆ្នាំ -- អារត់ឯកសារនេះតាំងពីឆ្នាំ៦៦។

**ស៖** ខ្ញុំដឹងថាលោកពិបាកចងចាំបន្តិច។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E3/9473 នៅក្នុងចម្លើយទី២ លោកបានឆ្លើយដូចតទៅ៖ "នៅឆ្នាំ៦០ តា នួន ជា ចាត់តាំងឲ្យខ្ញុំធ្វើជានីរសាររត់សំបុត្ររបស់ តាញឹម ពីបាត់ដំបងទៅឲ្យតា នួន ជា នៅភ្នំពេញ។ រហូតដល់ឆ្នាំ១៩៦៦ ទើបខ្ញុំរត់ទៅលាក់ខ្លួននៅស្រុកសំឡូត ដោយសារបែកការណ៍។" អ៊ីចឹងលោកចាំទេលោកសាក្សី គឺថាលោកធ្វើជានីរសារនាំសំបុត្រពី រស់ ញឹម ទៅឲ្យ នួន ជា ហ្នឹងគឺពីឆ្នាំ៦០ ទៅដល់ឆ្នាំ៦៦។

**ឆ៖** ដល់ពេលបែកការណ៍ទៅ គេរកចាប់ខ្ញុំ ខ្ញុំរត់ទៅព្រៃ។

**ស៖** ពេលដែលលោកធ្វើនីរសារឲ្យ នួន ជា និង រស់ ញឹម គឺជានីរសាររបស់ រស់ ញឹម យកសំបុត្រទៅឲ្យ នួន ជា។ អ៊ីចឹងពេលលោកធ្វើការហ្នឹង តើមេដឹកនាំទាំងពីររូបហ្នឹងទុកចិត្តលោកទេ?

**ឆ៖** ទុកចិត្តហើយបានគេឲ្យខ្ញុំអ្នកនាំសំបុត្រទៅមក។ តាំងពីបែកការណ៍ថាខ្ញុំអ្នកនាំសំបុត្រអ៊ីចឹងលើកក្រោយ គេយកចិត្តខ្ញុំ។ ខ្ញុំអត់ដឹងខ្លួន ឆ្នាំ៦៦ ខ្ញុំទៅលាក់ខ្លួននៅសំឡូត។

[០៩:២៤:៣៤]

**ស៖** រស់ ញឹម និង នួន ជា ជឿទុកចិត្តលោកក្នុងចន្លោះពីឆ្នាំ៦០ ដល់ឆ្នាំ៦៦។ អ៊ីចឹងក្រោយមក នោះ នៅក្នុងរបបខ្មែរក្រហមពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ នោះ តើមេដឹកនាំទាំងពីរហ្នឹង នៅតែជឿទុកចិត្ត លោកទៀតទេ?

**ឆ៖** ទុកចិត្ត។

**ស៖** នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៦០នោះ តើ នួន ជា មានតួនាទីអ្វីដែរ នៅក្នុងបក្ស?

**ឆ៖** ហើយនិងខ្ញុំ ថ្ងៃក្រោយបានគេទុកចិត្ត។ ក្រោយមកបានគេបញ្ចូលខ្ញុំជាបក្ខជន។

**ស៖** ខ្ញុំចង់ដឹងថានៅក្នុងបក្សហ្នឹង តើ នួន ជា មានតួនាទីអ្វីដែរ? គាត់ជាមេដឹកនាំដ៏សំខាន់មួយ រូបក្នុងចំណោមមេដឹកនាំនានាមែនទេ?

**ឆ៖** នួន ជា គាត់នៅភ្នំពេញ។

**ស៖** លោកដឹងថាគាត់មានតួនាទី ឬក៏មានមុខតំណែងអីនៅក្នុងគណៈអចិន្ត្រៃយ៍បក្សទេ?

**ឆ៖** ដឹងៗ ដឹងថាគាត់ប្រចាំការនៅភ្នំពេញ។ *(ឮមិនច្បាស់)* ឈ្មោះ រស់ ញឹម។ ហើយខ្ញុំអ្នក កាន់ឯកសារឡើងចុះទៅមក។

**ស៖** នៅសម័យនោះ ក្នុងបក្សអ្នកណាធំជាងអ្នកណា? នួន ជា ធំជាង រស់ ញឹម ឬក៏ រស់ ញឹម ធំជាង នួន ជា?

**ឆ៖** នួន ជា ធំជាង។

[០៩:២៧:១៩]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ទៅនឹងការសួរសំណួរបែបនេះ ព្រោះថាយើងអាចមានជម្រើសផ្សេងមួយទៀត ទាក់ទងនឹងឋានានុក្រម ព្រោះពួកគាត់មានឋានានុក្រមស្មើគ្នានៅក្នុងមជ្ឈិម។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំនឹងរៀបចំសំណួរ។ ឥឡូវខ្ញុំសួរសំណួរផ្សេងសិន។

**ស៖** លោកសាក្សី លោកធ្លាប់ឃើញ នួន ជា និង រស់ ញឹម នៅជាមួយគ្នាទេ នៅភ្នំពេញ ឬក៏ បាត់ដំបងក៏ដោយ?

01390825



2-TCW-920៖

**ឆ៖** នួន ជា អ្នកនៅភ្នំពេញ។ នួន ជា គាត់នៅភ្នំពេញ។ រស់ ញឹម មកនៅបាត់ដំបង។

**ស៖** លោកធ្លាប់ឃើញ នួន ជា ទៅជួប រស់ ញឹម នៅបាត់ដំបង ឬក៏ រស់ ញឹម មកពីបាត់ដំបង មកជួបនួន ជា នៅភ្នំពេញ ពេលដែលលោកធ្វើជានីរសារហ្នឹង លោកធ្លាប់អ្នកទាំងពីរហ្នឹងមកជួបគ្នាទេ?

**ឆ៖** មិនសូវបានជួបគ្នាទេ មានតែខ្ញុំនាំសំបុត្រទៅមក។ ឲ្យខាង រស់ ញឹម ហ្នឹងគាត់ក្ដាប់សភាពការណ៍ប្រជាជននៅតាមភូមិឃុំ និងស្រុកសំឡូត ស្រុកលើ។ នួន ជា គាត់នៅភ្នំពេញ។

**ស៖** បាទ ខ្ញុំមិនសួរអ្វីច្រើនវែងឆ្ងាយទេ។ ក៏ប៉ុន្តែនៅក្នុងចម្លើយពីមុន លោកថា នួន ជា ទៅជួប តាសម្បត្តិ ឬក៏ តាកែវ ដែលជាឈ្មោះផ្សេងទៀតរបស់ រស់ ញឹម នៅពន្លៃ នៅស្រែចា<ស់> គឺនៅក្នុងឯកសារ E3/9084 ដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា បារាំងទំព័រ១៧ ហើយជាភាសាអង់គ្លេសហ្នឹងទំព័រ២៣ បកប្រែមិនសូវល្អប៉ុន្មានទេ ហើយជាភាសាខ្មែរ 00057650។ លោកសាក្សី លោកនឹកឃើញទេថា លោកធ្លាប់បានឆ្លើយថា នួន ជា ហ្នឹងទៅជួប រស់ ញឹម នៅ<ស្រែចាស់> កន្លែងមួយដែលគេហៅថាពន្លៃ?

[០៩:៣០:២៩]

**ឆ៖** នួន ជា ជួនណាគាត់មកពីភ្នំពេញ គាត់ចុះរទេះភ្លើងផ្សារអូរដំបង ទៅជួប រស់ ញឹម នៅសំឡូត ស្រុកលើ។

**ស៖** ពេលដែលលោកឃើញ នួន ជា ទៅដល់ ហើយទៅជួប រស់ ញឹម ហ្នឹង តើនរណាគោរពនរណាជាង? តើអ្នកទាំងពីរហ្នឹង ចាត់ទុកគ្នាថាមានឋានៈស្មើគ្នា ឬក៏មាននរណាម្នាក់មានឋានៈខ្ពស់ជាង?

**ឆ៖** រស់ ញឹម គាត់គោរព នួន ជា។ នួន ជា គាត់មានមុខមានមាត់ធំជាង។

**ស៖** លោកដឹងអ្វីខ្លះពីឈ្មោះ ស៊ីវ ហេង នៅក្នុងចលនាកុម្មុយនីស្ដ ហើយតើ ស៊ីវ ហេង នេះគាត់មានជាប់សាច់ញាតិ ឬក៏មានទំនាក់ទំនងអីជាមួយ នួន ជា ដែរ?

**ឆ៖** នួន ជា គាត់អ្នករត្តគដែរ។ រស់ ញឹម គាត់*(ឮមិនច្បាស់)*។

**ស៖** លោកសាក្សី សូមលោកឆ្លើយម្ដងទៀត ខ្ញុំស្ដាប់អត់ឮ ពេលនិយាយពាក់ព័ន្ធនឹងឈ្មោះ ស៊ីវ ហេង អម្បាញ់មិញហ្នឹង?

[០៩:៣៣:១២]

**ឆ៖** លោកតា នួន ជា គាត់នៅ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំស្ដាប់អត់ឮការបកប្រែទេ។ តើលោកយ៉ាងម៉េចដែរ? សូមទោស គឺថា ខ្ញុំអត់ឮការបកប្រែជាភាសាអង់គ្លេសទេ។

**ប្រធានអង្គជំនុំ៖**

ខ្មែរក៏ពិបាកស្ដាប់ដែរ ប្រហែលជាអ្នកបកប្រែហ្នឹងក៏ស្ដាប់មិនបានដែរ។ ស្ដាប់ខ្មែរវាមិនបាន អ៊ីចឹងបានបកវាមិនកើត!

ខាងសោតទស្សន៍អាចដំឡើងសំឡេងបន្តិចជាងនេះបានទេ គាត់ផ្ដល់សក្ខីកម្មមកពិបាកស្ដាប់ណាស់ ស្ដាប់អត់បានណា។ អាចសម្របសម្រួលយ៉ាងម៉េចជាមួយនឹងខាងនោះ ដើម្បីឱ្យគាត់ហ្នឹង ខិតជិតជាមួយនឹងឧបករណ៍ផ្ដល់សំឡេង បញ្ជូនសំឡេងមក អាហ្នឹងបានអាចដោះស្រាយបាន។

*(សម្រាករយៈពេលខ្លី)*

[០៩:៣៥:១៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តទៀត! ហើយតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្ដងទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី ខ្ញុំបានសួរសំណួរអម្បាញ់មិញនេះពាក់ព័ន្ធនឹងឈ្មោះ ស៊ីវ ហេង។ ខ្ញុំចង់ដឹងថា លោកដឹងអ្វីខ្លះពាក់ព័ន្ធនឹងឈ្មោះ ស៊ីវ ហេង ក្នុងចលនាបដិវត្តន៍ ហើយខ្ញុំចង់ដឹងថាតើ ស៊ីវ ហេង ហ្នឹង ត្រូវជាអ្វី ជាប់សាច់ឈាមអីជាមួយ នួន ជា? សូមលោកឆ្លើយម្ដងទៀត។

**2-TCW-920៖**

**ឆ៖** ស៊ីវ ហេង គាត់អ្នកវត្តគរដែរ។ ស្រុកកំណើតកើតជាគាត់ ដែល នួន ជា ក៏អ្នកវត្តគរដែរ។ ហើយដល់ពេលធ្វើការហ្នឹងទៅ នួន ជា គាត់ទៅបង្កប់ខ្លួននៅភ្នំពេញ ហើយរស់ ញឹម ហ្នឹងគាត់នៅបាត់ដំបង ហើយទាក់ទងគ្នាអី ឱ្យខ្ញុំនាំសារទៅភ្នំពេញ។ រត់សំបុត្រពីភ្នំពេញមកបាត់ដំបង។

[០៩:៣៦:៤៥]

**ស៖** បាទ យើងមិនបានទទួលការបកប្រែពាក់ព័ន្ធនឹងអ្វីដែលលោកឆ្លើយអំពី ស៊ីវ ហេង ទេ។ ឥឡូវ ខ្ញុំសូមអាននូវអ្វីដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9084 ទំព័រ ៨ ជាភាសាបារាំង, ភាសាអង់គ្លេស១៨, ជាភាសាខ្មែរ 00057640។ បាទ ខ្ញុំសូមអាន មុនពេលមេធាវីការពារក្តីគាត់ជំទាស់។ បើអ៊ីចឹងទេយើងមិនទៅមុខរួចទេ។ លោកសាក្សី លោកបាននិយាយថា ស៊ីវ ហេង--

**លោក គង់ សំអុន៖**

បាទ មិនមែនជាការជំទាស់ទេ ដោយសារតំណាងសហព្រះរាជអាជ្ញាថា អត់បានឮការបកប្រែ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់នូវខ្លឹមសារដែលសាក្សីបានបញ្ជាក់អម្បាញ់មិញ។ គាត់ថា ស៊ីវ ហេង ហើយនិង នួន ជា នៅវត្តគរដែរ ហើយចំពោះ រស់ ញឹម គាត់នៅខាងបាត់ដំបង។ នេះជាព័ត៌មានដែលសាក្សីបានបញ្ជាក់។ បាទ សូមអរគុណ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកមេធាវី។

[០៩:៣៧:៥៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី នេះជាចម្លើយដែលលោកបានឆ្លើយកាលពីមុន "ស៊ីវ ហេង ជាឪពុកមា នួន ជា ហើយសព្វថ្ងៃហ្នឹង ងាប់ហើយ។ ពួកគេក្បត់គ្នាឯងនៅឆ្នាំ៦២។ ក្បត់គ្នាឯងហ្នឹង សម្លាប់គ្នាឯងម៉ាប្រាវទៅ។ បានក្រោយមកទៀត គេចាត់ទុក ស៊ីវ ហេង ជាជនក្បត់។ ពេលរដ្ឋប្រហារ ស៊ីវ ហេង ក៏ងាប់ខ្លួនទៅ ហើយក៏នៅតែវត្តគរហ្នឹង។ ដល់ឆ្នាំ៧៥ ចប់សង្គ្រាម គេអូសយកទៅវៃចោលទៅ។ សម្លាប់ចោល អត់មានទុកគាត់ទេ។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី លោកបាននិយាយថា នៅឆ្នាំ ១៩៧៥ គេសម្លាប់ ស៊ីវ ហេង ចោល។ លោកដឹងទេ អ្នកណាជាអ្នកចេញបញ្ជាឲ្យកម្ទេច ស៊ីវ ហេង?

**2-TCW-920៖**

**ឆ៖** ខ្ញុំមិនដឹងអ្នកណាគេបញ្ជាទេ ប៉ុន្តែថាពួកគ្នាគេធ្វើការជាមួយគ្នាហ្នឹង បើអ្នកណាក្បត់ គឺស្លាប់។

**ស៖** តើការសន្មតថា ស៊ីវ ហេង ក្បត់ នៅឆ្នាំ៦២ហ្នឹង វាបណ្តាលឲ្យមានវប្បធម៌នៃការមិនជឿ

ទុកចិត្តគ្នា ឬក៏ការភ័យខ្លាចគ្នានៅក្នុងបក្ស។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អាហ្នឹងគេមិនជឿទុកចិត្តគ្នា ហើយមួយក្បត់ មួយមិនក្បត់អីហ្នឹង។ បញ្ហាអ្នកណា -- តែទៅ គេបញ្ហាឲ្យកម្ទេចចោល។

[០៩:៣៥:០០]

**សៈ** បាទ អម្បាញ់មិញនេះលោកបាននិយាយថា លោកធ្វើនីរសារដល់ឆ្នាំ១៩៦៦ ក្រោយមកលោករត់ទៅគេចខ្លួន។ អ៊ីចឹងខ្ញុំសួរលោកថាតើលោកត្រឡប់មកចូលជួរបដិវត្តន៍ហ្នឹងនៅពេលណា? តើលោកមកចូលជួរបដិវត្តន៍<ម្តងទៀត>វិញហ្នឹងមុន<ពេលរំដោះក្រុងភ្នំពេញ>ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥?

**ឆ៖** រហូតខ្ញុំនៅដល់ព្រៃហើយ ក៏នៅតែជាប់ទំនាក់ទំនងគ្នាអ៊ីចឹង។ គេរកចាប់ខ្ញុំ ខ្ញុំទៅនៅព្រៃហើយ នៅ ខ្ញុំមិនចោលការងារហ្នឹង ទាក់ទងគ្នាជាប់។

**សៈ** មុនពេលដណ្តើមបានទីក្រុងភ្នំពេញថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥នោះ តើលោកបាន<ត្រឡប់មកប្រឡូកកិច្ចការ>បដិវត្តន៍វិញ<សកម្មជាងមុន ឬក៏>ពេលដែលលោកត្រឡប់ពីព្រៃមកវិញលោក<ក្លាយខ្លួនជាពលរដ្ឋសាមញ្ញម្នាក់?>

**ឆ៖** បាទ ខ្ញុំត្រឡប់មកពីព្រៃវិញមក ខ្ញុំនៃគេឲ្យធ្វើប្រធានសមាគមសាលារៀន។ រៀបចំសាលារៀន កូនក្មេងរៀន ក្នុងឃុំអូរដំបង១។

[០៩:៤២:២២]

**សៈ** ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកមានមុខតំណែង<អ្វី>មួយ<ជាពិសេស>នៅឃុំអូរដំបង១<របស់លោកដែរឬទេ>?

**ឆ៖** អត់ទេ ប្រាប់ទៅធ្វើឃុំនៅអូរដំបងមួយ។ កាលហ្នឹងវាយឈ្នះពួកខាងលន់ នល់។

**សៈ** លោកបានឆ្លើយនៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9084 ជាភាសាបារាំងគឺ<ទំព័រ>៣៥, <អង់គ្លេសគឺទំព័រ៤៨,> ជាភាសាខ្មែរ <00056670> "<លោក ដានី បានសួរ>សំណួរថា៖ ក្រោយបែកភ្នំពេញនៅឆ្នាំ១៩៧៥ហើយហ្នឹង លោកត្រូវបានគេតែងតាំងធ្វើជាប្រធានសហករណ៍អូរដំបង? ចម្លើយ៖ បាទ ហ្នឹងហើយពីដំបូង ហើយពីដំបូងនោះនៅក្រោមតំបន់៤។" ហើយបន្ទាប់មកទៀត លោកឆ្លើយថា ក្រោយមកគេបញ្ចូលសហករណ៍ហ្នឹងទៅតំបន់៣វិញ។ អ៊ីចឹងតើ<ត្រឹមត្រូវដែរឬទេថា>លោកធ្វើជាប្រធានសហករណ៍ អូរដំបង?

**ឆ៖** ប្រធានសហករណ៍នៅអូរដំបង បានគេបញ្ចូលទៅតំបន់៣។

**ស៖** ឥឡូវខ្ញុំ<មានសំណួរពីរ បីទៀតត្រូវ>ចោទសំណួរទាក់ទង<នឹង>រចនាសម្ព័ន្ធអំណាចនៅភូមិភាគពាយ័ព្យ។ អ៊ីចឹងខ្ញុំសួរលោកថាតើ<នរណាជាអ្នកដឹកនាំ>នៅភូមិភាគពាយ័ព្យ? <តើនរណាជាសមាជិក>គណៈភូមិភាគហ្នឹង?

[០៩:៤៤:៥៨]

**ឆ៖** គណៈភូមិភាគធ្វើតំបន់៣ មានតា រស់ ញឹម ហ្នឹងហើយគាត់កាន់ក្តាប់។

**ស៖** លោកក៏បាននិយាយផងដែរ ជាច្រើនដង ដូចឈ្មោះ តាគី ហើយនិង តាផាត។ តាគី ហ្នឹង គាត់ជាអនុប្រធាន ហើយ តាផាត ជាសមាជិក។ តើត្រឹមត្រូវដែរឬទេ? លោកអាចបញ្ជាក់ពីចម្លើយនេះបានទេ?

**ឆ៖** តាផាតៗ គាត់ទៅ គាត់ប្រគល់ទទួលនាទីឲ្យខ្ញុំមើលការខុសត្រូវ សហករណ៍អូរដំបង។

**ស៖** នៅតំបន់៣ហ្នឹង លោកស្គាល់អ្នកដឹកនាំណាខ្លះដែរ?

**ឆ៖** តំបន់៣ នែ៎ ស្លាប់បាត់ទៅទៀតទៅ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងសួរម្តងទៀត គាត់អត់ចាំសំណួរទេ មើលទៅ មិនអាចឆ្លើយបាន គាត់អត់ចាំសំណួរ។

**2-TCW-920៖**

**ឆ៖** មានបង ហេង គាវ, បង រស់ ញឹម ហ្នឹង ឯង។ គាត់ដាក់អា នែដីខាងស្រុកសង្កែហ្នឹង ត្រូវគេដកដាក់ទៅតំបន់៣ ទៅខាង រស់ ញឹម ហ្នឹងក្តាប់ផ្ទាល់ នៅតំបន់៣។ ឈប់ហៅស្រុកសង្កែ ទៅដីតំបន់៣ទៅវិញ។ មានប្រាំពីរឃុំ។ ឃុំវត្តគរ ឃុំអូរម៉ាល់ ឃុំព្រៃ ឃុំភ្នំសំពៅ។ ប្រាំពីរឃុំហ្នឹងដាក់ទៅតំបន់៣។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** តើលោកមានធ្លាប់ឮគេនិយាយអំពីថ្នាក់ដឹកនាំនៅតំបន់៣ ឈ្មោះ តាឆាំ ហើយនៅស្រុកភ្នំសំពៅនោះគឺ តាហឿន <ដែរឬទេ?> លោកមាននិយាយពីឈ្មោះពួកគាត់នេះ គឺនៅ<ក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី>ឯកសារE3/9473 ចម្លើយទី៩ លោកបាននិយាយពីឈ្មោះគាត់ទាំងពីរនេះ គឺលោកមាននិយាយពីឈ្មោះ តាឆាំ ហើយនិង តាហឿន ហ្នឹង។ តើលោកចាំឈ្មោះគាត់ទាំងពីរហ្នឹងទេ?

**ឆ៖** តាផាំ និង តាហឿន ហ្នឹងគេ ថ្ងៃក្រោយគេដកចេញ តាផាំ។ គេដកតាផាំ ដកតាហឿន ហ្នឹងចេញ។

**ស៖** លោកសាក្សី ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ នៅភូមិភាគពាយ័ព្យនោះ តើមានរឿងអ្វីកើតឡើងដែរចំពោះអតីតទាហានលន់នល់ ឬក៏មន្ត្រីរដ្ឋការជាន់ខ្ពស់របស់<របប>លន់នល់។ តើគេមានតាមស្វែងរក ឬក៏តាមចាប់<>អតីតទាហាន និងអតីតមន្ត្រីរដ្ឋការ<ទាំងនោះដែរឬទេ>?

[០៩:៥០:០០]

**ឆ៖** នៅកន្លែងខ្ញុំអត់មានទេ គឺថាឲ្យតែអ្នកណាសម្រុបខ្លួនមកនៅជាមួយ ការពារគ្នាឲ្យបានរស់សុខទាំងអស់គ្នា ព្រោះខ្ញុំនៅក្នុងឃុំអូរដំបងហ្នឹងខ្ញុំការពារបងប្អូនទាំងអស់ ទោះមានប្រវត្តិរូបអ្នកណាធ្វើអីក៏ដោយ ឲ្យតែគេសម្រុបខ្លួនជាមួយយើង ត្រូវតែការពារគ្នា ឲ្យគ្នាបានសុខទាំងអស់គ្នា។ ដោយឡែកតែកន្លែងផ្សេងៗ ដូចតំបន់៤ទៅឯកើត ខាង*(ឮមិនច្បាស់)* ការសម្លាប់គ្នាមាន។ តែកន្លែងខ្ញុំ អត់មានទេ អ្នកណាធ្វើអីក៏ដោយ អីក៏ដោយ។ ខ្លះធ្វើទាហានដល់ថ្នាក់ស័ក្តិ៥ក៏ដោយ ក៏ដោយ មកនៅនឹងខ្ញុំទាំងអស់បានរស់រហូតទាល់សព្វថ្ងៃ។

**ស៖** បាទ ក្រៅពីកន្លែងលោកនោះ ខ្ញុំដឹងថាលោកបានការពារមនុស្សមួយចំនួន តែនៅក្រៅពីកន្លែងលោកហ្នឹង តើមានគេតាមស្វែងរកអតីតទាហានជាន់ខ្ពស់ លន់ នល់ ហើយនិងអតីតមន្ត្រីរដ្ឋការជាន់ខ្ពស់របស់ លន់ នល់ ដែរឬទេ? ហើយបើសិនជាករណីហ្នឹងមាននោះ តើគេទទួលបញ្ជាពីអ្នកណាដែរ ឲ្យតាមរកអតីតទាហានលន់នល់ ហើយនិងអតីតមន្ត្រីរដ្ឋការ លន់ នល់ នេះ?

**ឆ៖** ចំណែកខ្ញុំអត់មានទេ អ្នកធ្វើការអីក៏ដោយ មកនៅជាមួយខ្ញុំ បានសុខទាំងអស់ សូម្បីតែទាហានស័ក្តិប៉ុន្មានក៏ដោយ ឲ្យគ្នាសម្រុបខ្លួន កុំឲ្យប្រឆាំងនឹងយើង យើងត្រូវតែឲ្យគ្នារស់។ បើចំណែកគេផ្សេងៗខ្ញុំមិនដឹងទេអាហ្នឹង។

[០៩:៥២:២៩]

**ស៖** នៅចម្លើយទី២ នៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/9473 នៅចម្លើយចុងក្រោយរបស់លោកនុ៎ង លោកនិយាយថា “តាផាំ ហ្នឹងឃោរឃៅណាស់។ ហើយក្រោយឆ្នាំ១៩៧៥ហ្នឹង ទាហានលន់នល់ ទាំងអស់ហ្នឹង <>ទៅពួននៅក្នុងព្រៃ ហើយ តាផាំ ហ្នឹង ជិះឡានទៅ ទៅដេញបាញ់ ហើយនិងដេញចាប់ពួកទាហានទាំងអស់ហ្នឹង។” សូមបញ្ចប់ការដកស្រង់។

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ គឺថាព្រះរាជអាជ្ញាគាត់<មិនបានអានឃ្លាចុងក្រោយដែលនិយាយថា៖ "ប៉ុន្តែ ខ្ញុំមិនដែលឃើញគាត់សម្លាប់នរណាម្នាក់ឡើយ។">

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាងឈល៖**

**ស៖** លោកសាក្សី តាឆាំ ពេលគាត់ជិះឡានទៅ ដើម្បីដេញចាប់អតីតទាហាន លន់ នល់ ហ្នឹង <តើ>គាត់ទៅដោយចិត្តឯង ឬគាត់ទៅដោយសារ<ថ្នាក់លើ>បញ្ជាគាត់?

**2-TCW-920៖**

**ឆ៖** គេអារឿងគាត់ ចិត្តគាត់ៗបង្ក្រាប គាត់រកចាប់ ឯពួកអស់ហ្នឹងទៅសម្ងំលាក់ខ្លួននៅក្នុងព្រៃក្នុងអី គាត់រកចាប់ រត់តាម។ ហើយ តាឆាំ ក៏អ៊ីចឹង។

**ស៖** បាទ មានផ្នែកមួយទៀតនៅក្នុងឯកសារដដែលហ្នឹង គឺឯកសារ E3/9473 ដដែល ចម្លើយ២៧, ២៨ លោកនិយាយថា លោកត្រូវតែរាយការណ៍អំពីប្រជាជននៅក្នុងឃុំអូរដំបង១ហ្នឹង ទៅតាហឿន លោកត្រូវរាយការណ៍ទៅ តាហឿន។ លោកឆ្លើយដូចតទៅនេះ គាត់ថា៖ "ក្រៅពីរាយការណ៍ពីផលស្រូវនោះ តើលោកត្រូវរាយការណ៍អំពីអ្វីផ្សេងទៀតដែរឬទេ? លោកឆ្លើយថា៖ ខ្ញុំត្រូវរាយការណ៍អំពីចំនួនប្រជាជនក្នុងឃុំ ហើយបើប្រសិនជាប្រជាជនមានបាតុភាពមិនល្អ ឬក៏មានសមាសភាពខ្មាំងក្នុងភូមិ យើងត្រូវរាយការណ៍ដែរ។ សំណួរទី២៨៖ អ្នកណាជាខ្មាំងដែលលោកចង់សំដៅនោះ? ចម្លើយ៖ ខ្មាំងនោះគឺគេសំដៅទៅលើអ្នកដែលធ្លាប់ធ្វើមន្ត្រី នៅធ្វើយោធាពីសង្គមចាស់។ គេឲ្យយើងប្រាប់ថាតើមានសកម្មភាពអីចម្លែកដែរឬទេ ហើយធ្វើយ៉ាងណាឲ្យពួកហ្នឹង មកសម្រុះសម្រួលមកតាមបក្សយើងវិញទៅ។ តែខ្ញុំរាយថា គេរាយការណ៍ថា គេមកសម្រុះសម្រួលយើងអស់ហើយ។" <បញ្ចប់ការដកស្រង់> អ៊ីចឹងក្នុងចម្លើយរបស់លោក <ខ្មាំងគឺជាអតីតរដ្ឋការ និងអតីតទាហានរបបមុន>។ តើនៅពេលប្រជុំជាមួយ រស់ ញឹម <តើ>គាត់ធ្លាប់និយាយពីខ្មាំងទាំងអស់ហ្នឹងដែរឬទេ <គឺ>អតីតទាហាន លន់ នល់ ហើយនិងអតីតមន្ត្រីរដ្ឋការ លន់ នល់ ដែរឬទេ? <>

[០៩:៥៦:១៩]

**ឆ៖** ខាងខ្ញុំឲ្យតែអ្នកណាគេសម្រុះខ្លួនមករស់នៅជាមួយយើង ទោះជាធ្វើស័ក្តិធំតូចអីក៏ដោយ កុំឲ្យតែគេប្រឆាំងយើង ត្រូវតែឲ្យគ្នារស់។ កំសត់កម្រ អ្នកណាក៏ដោយ ឲ្យមកនៅជាមួយ អ៊ីចឹងឲ្យគ្នា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានសុខបានរស់ទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

សាក្សីស្ដាប់សំណួរមិនយល់ទេ ហើយខាងបុគ្គលិកអង្គភាពគាំពារសាក្សី អ្នកជំនាញដែលជួយគាំទ្រកិច្ចការសវនាការតាមទូរទស្សន៍ហ្នឹង គឺកញ្ញា លី និមល? លី និមល មានវត្តមានទេ?

**កញ្ញា លី និមល៖**

ចាស លោកប្រធាន មានវត្តមានទីនេះ។

**ប្រធានអង្គជំនុំ៖**

ឥឡូវអ៊ីចេះ ដើម្បីសម្រួលបញ្ហានេះ សូម លី និមល សម្របសម្រួលបញ្ហាសំណួរ។ ឥឡូវហ្នឹងស្ដាប់សំណួរខាងភាគីដែលសួរឲ្យបាន ហើយ និមល សម្របសម្រួលសំណួរហ្នឹងបញ្ជាក់ប្រាប់គាត់ខ្លឹមសារជា ដែលនៃគោលបំណងសួរគាត់ ដើម្បីឲ្យគាត់ស្ដាប់យល់ពីសំណួរ ហើយគាត់ឆ្លើយតបនឹងសំណួរបាន ដល់អ៊ីចឹងគាត់ឆ្លើយអត់បានទេ គាត់អត់ស្ដាប់សំណួរយល់ផង។ ធ្វើបានទេ?

**កញ្ញា លី និមល៖**

ចាស លោកប្រធាន ខ្ញុំនឹង -- ចាស ស្ដាប់បានលោកប្រធាន ខ្ញុំជួយសម្រួលសំណួរហ្នឹង ដើម្បីឲ្យគាត់យល់។

**ប្រធានអង្គជំនុំ៖**

បាទៗ អរគុណ។ ហើយអញ្ជើញបន្តទៀតតាមតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ។

[០៩:៥៨:០០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំនឹងមិននិយាយវែងឆ្ងាយអំពីស្ថានភាពនៅសហករណ៍អូរដំបង១នោះទេ ក៏ប៉ុន្តែ ខ្ញុំនិយាយអំពីអ្វីដែល រស់ ញ៉ឹម បាននិយាយអំពីខ្មាំង គឺអតីតទាហាន លន់ នល់ ហើយនិងអតីតមន្ត្រីរដ្ឋការលន់ នល់។ អ៊ីចឹងខ្ញុំ សំណួរខ្ញុំ ខ្ញុំសួរថានៅពេលដែលលោកប្រជុំជាមួយគាត់ ឬក៏ពេលលោកជួបគាត់អីហ្នឹង តើ<គាត់>បាននិយាយ<>ថា<>អតីតទាហាន លន់ នល់ ហើយនិងអតីតមន្ត្រីរដ្ឋការ លន់ នល់ ហ្នឹងជាខ្មាំងដែរឬទេ?

**2-TCW-920៖**

**ឆ៖** សម្របខ្លួន មករស់នៅជាមួយយើង គេមិនប្រឆាំងនឹងយើង--

**កញ្ញា លី និមល៖**

អត់ទេ គេសួរថា នៅពេលដែលលោកតាជួបមន្ត្រី -- ជួប រស់ ញឹម តើគាត់មានបាននិយាយថា មន្ត្រីថាមន្ត្រីផ្សេងៗទៀតជាខ្មាំងអត់? គេបាននិយាយថាមន្ត្រីផ្សេងៗ ឬក៏អ្នកណាផ្សេងហ្នឹង ជាខ្មាំងអត់?

[០៩:៥៩:២០]

**2-TCW-920៖**

**ឆ៖** អត់ទេ គាត់និយាយឲ្យគេសម្របខ្លួនមករស់នៅជាមួយយើង គោរពយើង ធ្វើតាមយើង កុំឲ្យតែគេប្រឆាំងនឹងយើង អាហ្នឹងគាត់ឲ្យគ្នារស់ទាំងអស់គ្នា។ ព្រោះយើងច្រើនសង្គមមកហើយ គេធ្វើនោះ យួនធ្វើនេះ បើអាលែងតែសម្លាប់គ្នា អស់ហើយ។ បើអាកន្លែងផ្សេងៗ ខ្ញុំមិនដឹងទេណ៎ា។ អាកន្លែងផ្សេងៗ ហៅតំបន់៤១ឯកើត ត្រង់នោះកាប់សម្លាប់គ្នា អានោះខឹងវាកាលពីសម័យពីសង្គម ប្រើវាឲ្យធ្វើបន្ទាយ ធ្វើប៉ុស្តិ៍ ធ្វើប៉ម ឥឡូវត្រឡប់មកបក្សជំនាន់អញ អញកាប់អ្ហែងចោល ហ្នឹងកាប់គ្នាវា ហ្នឹងមាន។ បើកន្លែងខ្ញុំ អត់មានទេ។

**ប្រធានអង្គជំនុំ៖**

សំណួរសួរអ៊ីចេះទេ សួររឿងបញ្ហា តើលោកដែលស្តាប់ឮការនិយាយ ជាការប្រជុំប្រាប់ និយាយប្រាប់ ឬក៏ជួបផ្ទាល់ជាឯកជនរវាងលោកសាក្សីជាមួយនឹង រស់ ញឹម តើគាត់ដែលនិយាយពីបញ្ហាវិធានការនៃការកំណត់ថាជាខ្មាំងបដិវត្តន៍ ហើយចាត់វិធានការកម្ទេចចំពោះខ្មាំងទាំងអស់នុ៎ងទេ ជាពិសេសអតីតអ្នករដ្ឋការ លន់ នល់ ទាហាន លន់ នល់ អ៊ីចឹងណ៎ា! ដែល រស់ ញឹម ដែលនិយាយទេ? មិនមែនលោកទេ មិនមែនលោកធ្វើខ្លួនឯងទេ រស់ ញឹម និយាយពីបញ្ហានេះ។

**2-TCW-920៖**

**ឆ៖** អត់មានទេ គាត់អត់ថាទេ។ ឲ្យតែគេសម្របខ្លួន រស់នៅជាមួយយើង ឲ្យគ្នារស់ទៅ ព្រោះវាច្រើនជំនាន់មកហើយ អ្នកនេះធ្វើនោះ អ្នកនោះធ្វើនេះ។ បើរវល់តែរឿងធ្វើនោះ អ្នកនេះធ្វើនេះ យកគ្នាមកសម្លាប់អស់។

[១០:០០:៥៨]

**ប្រធានអង្គជំនុំ៖**

បានៗហើយ ប៉ុណ្ណឹងបានហើយ។ អញ្ជើញតទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ!

**2-TCW-920៖**

**ឆ៖** បើគាត់ ស័ក្តិ៥។

**កញ្ញា លី និមល៖**

បាន លោកតា។

**ប្រធានអង្គជំនុំ៖**

ឥឡូវអ៊ីចេះទៅ ដើម្បីនេះ យើងបានរំឭកហើយថាឲ្យសួរខ្លីៗទៅ។ ហើយលោកកាលណារៀបរាប់អត្ថាធិប្បាយហ្នឹង គឺធ្វើឲ្យអ្នកខាងនោះក៏ស្មុគស្មាញដែរ ដោយសារខ្លឹមសារនៃអត្ថាធិប្បាយរបស់លោក។ លោកសួរជាក់លាក់ទៅសំណួរ សួរខ្លីហ្នឹងទៅបានហើយ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ លោកសាក្សី ទាក់ទងទៅនឹងខ្មាំងរបស់របបខ្មែរក្រហម តើនៅក្នុងភូមិភាគ<> ពាយ័ព្យ <ចាត់ទុក>អ្នកដែលមិនគោរពគោលនយោបាយ <ឬ>វិន័យរបស់អង្គការពាក់ព័ន្ធទៅនឹងសមូហភាពនោះ<>ជាខ្មាំងដែរឬទេ?

**កញ្ញា លី និមល៖**

លោកតាស្តាប់សំណួរយល់ទេ?

[១០:០២:១៦]

**2-TCW-920៖**

**ឆ៖** ឲ្យតែគេសម្របខ្លួនគេមិនប្រឆាំងនឹងយើង គេចាត់ទុកថាជាប្រជាជនរបស់យើងទាំងអស់គ្នា។ ទេខ្ញុំនិយាយតែកន្លែងខ្ញុំទេ កន្លែងផ្សេងខ្ញុំមិននិយាយទេ។

**កញ្ញា លី និមល៖**

លោកតា សំណួរសួរថា ពួកខាងពាយ័ព្យ -- លោកតាស្តាប់សំណួរយល់ទេ?

**2-TCW-920៖**

**ឆ៖** ក្រោយមក--

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

<**ស៖** មិនថ្វីទេ។ សំណួររបស់ខ្ញុំមានលក្ខណៈទូទៅ ដោយមិនផ្តោតលើអ្នកដែលទទួលធ្វើតាមវិន័យ ឬបញ្ជារបស់អង្គការទេ។ ខ្ញុំផ្តោតទៅលើអ្នកដែលប្រឆាំងនឹងអង្គការ មិនថានៅតំបន់របស់លោកតែប៉ុណ្ណោះទេ គឺសំដៅលើភូមិភាគពាយ័ព្យទាំងមូល។ តើមានអ្វីកើតឡើងចំពោះអ្នកដែលប្រឆាំង ឬជំទាស់នឹងបញ្ជា និងវិន័យរបស់អង្គការ?>

**2-TCW-920៖**

**ឆ៖** អ្នកមានកន្លែងគេផ្សេង ហ្នឹងខ្ញុំមិនហ៊ានថាទេ មិនដឹងទេ។ ប៉ុន្តែត្រង់កន្លែងខ្ញុំ អត់មានទេ។

**កញ្ញា លី និមល៖**

អត់ទេ លោកតា សំណួរសួរថា នៅក្នុងតំបន់របស់លោកតា ប្រសិនបើមិនមានអ្នកគោរពវិន័យទេ គេនឹងមានវិធានការអីអត់? គេនឹងធ្វើអីចំពោះគាត់អត់ ប្រសិនបើគាត់មិនគោរពវិន័យនៅក្នុងតំបន់របស់លោកតា។

**2-TCW-920៖**

**ឆ៖** ហ្នឹងអត់មានទេ *(ឮមិនច្បាស់)* ឃើញតែមកនៅ ឃើញសម្របខ្លួនតាម។

**កញ្ញា លី និមល៖**

អ៊ីចឹងអត់--

**2-TCW-920៖**

**ឆ៖** បាទ សូម្បីតែទាហានធ្លាប់បម្រើ លន់ នល់ ទៅនៅអីក៏ដោយ។ មកនៅនឹងយើង សម្របខ្លួនតាមយើង។ គេអត់ប្រឆាំងអីនឹងយើង ។ត្រូវតែការពារគ្នាឲ្យបានរស់ទាំងអស់គ្នាទៅ។

[១០:០៤:៣៨]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** ឥឡូវខ្ញុំចូលមកនិយាយករណីជាក់លាក់តែម្តង។ តើមានរឿងអីកើតឡើងចំពោះ តាហឿន ដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង? ហើយ<តើនរណា>ជាអ្នកទទួលខុសត្រូវ<>ចំពោះ<រឿងរ៉ាវ គាត់នោះ>?

**កញ្ញា លី និមល៖**

លោកតាយល់សំណួរទេ? យល់សំណួរទេ? លោកតាចាំ តាហឿន បានអត់?

01390836



**2-TCW-920៖**

**ឆ៖** តាហឿន?

**កញ្ញា លី និមល៖**

ចាស ចាំអត់?

**2-TCW-920៖**

**ឆ៖** តាហឿន គឺខាងស្រុក តាហឿន (ឮមិនច្បាស់)។

**កញ្ញា លី និមល៖**

តើមានរឿងអីកើតឡើងចំពោះ តាហឿន អត់នៅក្នុងរបបហ្នឹង? មានរឿងអីកើតឡើងអត់?

**2-TCW-920៖**

**ឆ៖** ក្រោយមក តាហឿន ក៏គេដកចេញទៅបាត់ទៅ ឈប់ឲ្យធ្វើការទៅ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី តើលោក<>ដឹងដែរឬទេ ថាតើគេដកគាត់ចេញហ្នឹង<>មុន<> ឬក៏ក្រោយពេលដែលគេចាប់ រស់ ញឹម<>?

[១០:០៦:០០]

**ឆ៖** ដកមុន គេដកមុន រស់ ញឹម។ គេដកចេញ គេដកមុន រស់ ញឹម គេដកមុន។

**ស៖** តើ រស់ ញឹម ចោទ តាហឿន អំពីបទអីដែរ?

**ឆ៖** គាត់ចោទហ្នឹង គឺមើលសកម្មភាពរបស់ -- គេដូចជាថាវាមិនទុកចិត្ត ប្រហែលជាការមិនទុកចិត្តគ្នាណ៎ា។ អ្នកណាមិនទុកចិត្ត គេដកចេញ។

**ស៖** តើលោកដឹងថា រស់ ញឹម <បាន>បញ្ជូន ហឿន ហ្នឹងទៅណាដែរឬទេ?

**ឆ៖** គេនែ ហឿន ហ្នឹងគេដកចេញមក គឺនៅ ទៅ -- មិនដឹងទៅខាងណា បាត់ទៅ។

**ស៖** នៅចម្លើយទី១០<ក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយរបស់លោក>គឺឯកសារ E3/9473 <>លោកនិយាយថា "រស់ ញឹម ចាប់តាហឿន <ប្រហែលជា>នៅដើមឆ្នាំ<១៩៧៨។"> លោកនិយាយថា<៖ "បន្ទាប់ពីទស្សនកិច្ចរបស់>គណៈប្រតិភូចិនមក<> តាញឹម <>ចាប់ តាហឿន ដោយចោទប្រកាន់ថា តាហឿន នេះ គាត់ជា <ភ្នាក់ងារ>សេ.អ៊ី.អា ចាប់ហើយគេបញ្ជូនទៅភ្នំពេញបាត់ទៅ។" <នៅពេលនោះតើលោកដឹងថា តាហឿន ត្រូវគេ>បញ្ជូនទៅភ្នំពេញ<ដែរឬទេ?>

**ឆ៖** តាហឿន ហ្នឹងទៅ ដកចេញពីហ្នឹង គឺទៅបាត់ទៅ មិនដឹងទៅខាងណា។ យកទៅវ៉ៃចោល មិនដឹង។

[១០:០៨:៥៧]

**ស៖** តើនៅពេលដែលប្រជុំនោះ លោកមានធ្លាប់ឮ រស់ ញឹម ឬកម្មាភិបាលផ្សេងទៀត និយាយថា តាហឿន ក្បត់បដិវត្តន៍ដែរឬទេ?

**ឆ៖** មិនឮនិយាយទេ គ្រាន់តែថា ស្រាប់តែគេដកចេញទៅបាត់ទៅ។

**ស៖** អម្បាញ់មិញលោកនិយាយអំពី តាឆាំ ដែរ។ និយាយថា តាឆាំ ហ្នឹងជាប្រធានតំបន់៣។ តើមានរឿងអ្វីកើតឡើងដែរ ចំពោះ តាឆាំ ហ្នឹងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ? តើ <គាត់>បាត់ខ្លួន<ទេ>?

**ឆ៖** តាឆាំ ថ្ងៃក្រោយបាត់ទៅ គេដកទៅខាងណា អីខាងណាទៅ។

**ស៖** តើគេចាប់ តាឆាំ មុន តារស់ ញឹម ឬក៏គេចាប់ រស់ ញឹម មុន តាឆាំ?

**ឆ៖** តាឆាំ មុនៗ រស់ ញឹម ដកខ្លួនបាត់ មិនដឹងទៅខាងណា។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា តាឆាំ ហ្នឹងគាត់មានតួនាទីជាអ្នកគ្រប់គ្រងការដ្ឋាន<ទំនប់>កំពីងពួយផងដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** ទំនប់កំពីងពួយយកតែតាមសហករណ៍ផ្សេងៗទេ។

**កញ្ញា លី និមល៖**

តាឆាំ ហ្នឹងគាត់មានតួនាទីគ្រប់គ្រងតំបន់កំពីងពួយហ្នឹងអត់?

**2-TCW-920៖**

**ឆ៖** អត់ទេ។

**កញ្ញា លី និមល៖**

អត់ទេ។

**2-TCW-920៖**

**ឆ៖** កំពីងពួយគេយកតាមឃុំទេ យកប្រាំពីរឃុំទៅវ៉ៃទំនប់កំពីងពួយ ចល័ត។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំមានសំណួរមួយទៀត ទាក់ទងទៅនឹង<មនុស្សម្នាក់>ឈ្មោះ តាងួន។ <តើ>

លោកមានស្គាល់ឈ្មោះ តាងួន ដែលកាលនោះគាត់<មាននាទីជាអ្នកដឹកនាំ>យោធាភូមិភាគ<ដែរ ឬទេ>?

[១០:១២:០៩]

**ឆ៖** តាងួន ណាអ៊ីចេះ។

**កញ្ញា លី និមល៖**

តាងួន លោកតាចាំ តាងួន ទេ? គាត់ជា ធ្វើការជាយោធាភូមិភាគ តាងួន ចាំទេ?

**2-TCW-920៖**

**ឆ៖** មិនចាំទេ តាងួន ណាអ៊ីចេះ! មិនបានចាំ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាងល៖**

**ស៖** គឺឈ្មោះ តាង៉ន បាទៗចម្លើយរបស់លោកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9084 ទំព័រជាភាសាបារាំង ទំព័រ៤០ ដល់៤១ ហើយជាភាសាអង់គ្លេសគឺ ទំព័រ៥៤, ជាភាសាខ្មែរ គឺ 00057676 ទៅដល់ 7 "តាង៉ន ខ្ញុំស្គាល់គាត់ ប៉ុន្តែគាត់ឡើងស័ក្តិទៅជាប្រធានកងពល។ បាទ តាង៉ន ហ្នឹងគាត់មាននីរសារ<ស្រីក្មេងៗ>ពីរ<នាក់> ដែល<គាត់ទុកឲ្យគក់ច្របាច់>គាត់។ ខ្ញុំដឹង<តែ ប៉ុណ្ណឹង។ ខ្ញុំគិត>ថា តាង៉ន នេះរស់<មិនយូរ>ទេ។ ព្រោះ<ការ>រស់នៅ<បែប>នេះគឺ<នាំឲ្យគាត់> ក្បត់ហើយ គេហៅ តាង៉ន ហ្នឹងមកគេបាញ់ចោលទៅ មិនអាចរត់រួចទេ។ សំណួរ៖ តើ តាញ៉ឹម ហ្នឹង អ្នកបាញ់គាត់ចោល? លោកឆ្លើយថា៖ ហ្នឹងហើយ តាញ៉ឹម បាញ់គាត់ចោល មិនបាច់ទុកវាឲ្យរស់ទេ ទោះបីវាជាប្រធានកងពលក៏ដោយ។ សំណួរ៖ អ៊ីចឹងបានថាគាត់ស្លាប់នៅឆ្នាំ១៩៧៥? <>ចម្លើយថា៖ ហ្នឹងហើយ វាងាប់នៅឆ្នាំ១៩៧៥។" ហើយលោកបញ្ជាក់មកទៀតថា ចុង៧៥។ <ដោយសារហេតុផល នេះឬទើបលោកប្រាប់>ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា មិនបាច់ទុកវាឲ្យរស់ទេ អាង៉ន <នោះ? តើ>ដោយហេតុថាគាត់ហ្នឹងមិនគោរពវិន័យបក្ស ឬក៏ដោយមូលហេតុអីផ្សេងបានជាគេបាញ់គាត់ចោល <នោះ>?

[១០:១៤:៤៤]

**កញ្ញា លី និមល៖**

លោកតាចាំ តាង៉ន ទេលោកតា? លោកតាចាំ តាង៉ន ទេ?

**ឆ៖** តាង៉ន ណាអ៊ីចេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា លី និមល៖**

លោកតាចាំ តាង៉ន? តាង៉ន ហ្នឹងចាំអត់?

**2-TCW-920៖**

**ឆ៖** អត់។

**កញ្ញា លី និមល៖**

អត់ចាំទេ?

**2-TCW-920៖**

**ឆ៖** មិនដឹង តាង៉ន ណាផងអ៊ីចេះ។ អត់ចាំ។

[១០:១៥:០០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ។ ខ្ញុំឮព្រះរាជអាជ្ញានិយាយថា ជាមេបញ្ជាការកងពលធំ ប៉ុន្តែភាសាអង់គ្លេស<និយាយ>ថាជាប្រធានកងទៅវិញ។ ដូច្នេះខ្ញុំមិនដឹងថាភាសាបារាំង<ឮផ្សេងទេ> ប៉ុន្តែបើភាសាអង់គ្លេស<ឮ>ថាជាប្រធានកង។ ប្រធានកងនេះជាឋានៈទាបណាស់ បើប្រៀបជាមួយប្រធានកងពលដែលជា<តំណែង>ធំបំផុត<ក្នុងជួរ>យោធានោះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

បាទ ខ្ញុំគិតថា<>ឯកសារព្រាងហ្នឹងជាភាសាអង់គ្លេសហ្នឹង មិនមែន<>បកប្រែ<ដោយអ្នកបកប្រែ>អាជីព<នោះ>ទេ។ អ៊ីចឹងយើងមិនអាចទុកចិត្តការបកប្រែជាភាសាអង់គ្លេសទេ ពីព្រោះគ្រាន់តែជាឯកសារព្រាង<តែប៉ុណ្ណោះ ប៉ុន្តែយើងពិតជាត្រូវការការបញ្ជាក់ដែរ។ ខ្ញុំនឹងបន្តទៅទៀត>។

**ប្រធានអង្គជំនុំ៖**

ឥឡូវៗឲ្យៗលេខ ERN ជាភាសាខ្មែរ ឲ្យខ្ញុំឲ្យច្បាស់មើល៍។

[១០:១៦:១៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្អាឯល៖**

ERN គឺ00057676 បាទ នៅកន្លែងហ្នឹងហើយគេនិយាយអំពីតួនាទីរបស់គាត់នោះ ហើយមានឆ្លងទៅដល់ទំព័របន្ទាប់ផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មើលខាងជាតិ យ៉ាងម៉េចដែរ ខ្ញុំដូចមិនត្រូវរក គ្នាមិនត្រូវសោះនេះ! លេខ ERN ហ្នឹង។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាននៅក្នុងឯកសារ E3/9084, ERN 00057676 នៅក្នុងនោះមាននិយាយថា មានប្រើឈ្មោះ តាង៉ន ហើយដែលនិយាយថា តាង៉ន ហ្នឹង ឡើងប្រធានកងពល។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ។

បាទ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងដប់ និងសាមសិបប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

អរគុណលោកសាក្សី ឥឡូវនេះដល់ពេលសម្រាកហើយ។ ហើយសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ និងសាមសិបប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយ និមល ជួយសម្របសម្រួលជាមួយនឹងគាត់ផង ដើម្បីឲ្យគាត់អញ្ជើញមានវត្តមាននៅកន្លែងផ្ដល់សក្ខីកម្មនៅពេល នៅវេលាឲ្យបានមុនម៉ោងដប់ និងសាមសិបប្រាំនាទី។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោយកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៨ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សួស្ដីលោកសាក្សី តើលោកបានត្រៀមខ្លួនហើយឬនៅ?

**កញ្ញា លី និមល៖**

លោកតាត្រៀមខ្លួននៅ? ត្រៀមខ្លួនហើយនៅ?

**2-TCW-920៖**

ត្រៀមហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី។ ហើយផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សាក្សីមុននេះយើងនិយាយអំពីការចាប់ខ្លួន ហឿន, ឆាំ និង ង៉ន ដែលលោកមិននឹកឃើញឈ្មោះគាត់ ង៉ន ហ្នឹង។ មុនពេលចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់<ទាំងនោះ> តើ រស់ ញឹម មានបានធ្វើការស៊ើបអង្កេតអី<ដោយផ្ទាល់>ទេ?

[១០:៣៨:០៦]

**កញ្ញា លី និមល៖**

មុនពេលចាប់ខ្លួននរណាម្នាក់ រស់ ញឹម ត្រូវការធ្វើការស៊ើបអង្កេតអីសិនអត់មុននឹងចាប់ខ្លួនគេ?

**2-TCW-920៖**

**ឆ៖** នែគាត់មើលការខុសត្រូវ គាត់មើលដែរអ្នកណាខុស អ្នកណាត្រូវ អ្នកណាមិនកើតដកចេញទៅ។

*(សម្រាករយៈពេលខ្លី)*

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំអត់ស្តាប់ឮចម្លើយផង។

**កញ្ញា លី និមល៖**

មុនពេលដែល រស់ ញឹម ធ្វើការដកអ្នកណាមួយ--

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំសួរថា មុនពេលចាប់ខ្លួនកម្មាភិបាលដូចជា តាហឿន, តាឆាំ, តាង៉ន និងកម្មាភិបាលផ្សេងទៀតនោះ តើ រស់ ញឹម គាត់មានបានធ្វើការស៊ើបអង្កេតអីទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនដឹងថាតើលោកមានបញ្ហាកាស<ដែរ>ឬ<ទេ ដោយឡែកនៅខាងពួកយើងមានឮសំឡេងង្វូងៗនៅក្នុងកាស ហើយយើងមិនបាន>ឮចម្លើយ<របស់>សាក្សី<ទេ>។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទឧបករណ៍ខ្ញុំអស់ថ្មហើយ។ អ៊ីចឹងខ្ញុំសួរសហការីខ្ញុំ <តើ>អំមិញសាក្សីឆ្លើយយ៉ាងម៉េចនោះ។

[១០:៣៩:៥៣]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកដឹងទេថា រស់ ញឹម ធ្លាប់ទទួល<បញ្ជា ឬ>សេចក្ដីណែនាំ<>ពីថ្នាក់លើឲ្យចាប់កម្មាភិបាលទេ?

**កញ្ញា លី និមល៖**

លោកតាធ្លាប់ដឹងហើយ រស់ ញឹម ធ្លាប់បានទទួលបញ្ជាពីខាងលើ ដើម្បីឲ្យចាប់អ្នកណាគេម្នាក់អត់? រស់ ញឹម ដែលទទួលបញ្ជាពីថ្នាក់លើ ដើម្បីចាប់អ្នកណាគេមួយអត់?

**2-TCW-920៖**

**ឆ៖** អត់ទេ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយៗតប លោកសាក្សី! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរនេះ។ រស់ ញឹម គឺជាថ្នាក់លើហើយអ៊ីចឹង <គប្បី>សួរ<ឲ្យជាក់លាក់ទៅ>ថា<នរណាបញ្ជារស់ ញឹម ប្រសិនបើថាគាត់>ទទួលបញ្ជា<គេនោះ>។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី យើងនឹងដឹង។ យើងបានពិភាក្សាគ្នាលើបញ្ហានេះពីម្សិលមិញរួចហើយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

ចុះ<>"ថ្នាក់លើ"នេះ មានន័យថាដូចម្ដេចដែរ បើ រស់ ញឹម <នេះ>ជាថ្នាក់លើ<ហើយតើ? ខ្ញុំមិនយល់។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<អ៊ីចឹង ហេតុអ្វីបានជាយើងមិនចាំស្ដាប់ចម្លើយសិនទៅ?>

**លោក វ៉ិចទ័រ កូប៉េ៖**

<ប៉ុន្តែ-->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<យើងអាចតវ៉ាគ្នានៅពេលក្រោយ។ ខ្ញុំដឹងថាយើងជិតមានឱកាសនេះហើយ ប៉ុន្តែ-->

**លោក វ៉ិចទ័រ កូប៉េ៖**

<ថ្នាក់លើមិនមែន-->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<-- នៅទេ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ថ្នាក់លើ>គឺថាត្រូវតែមានមនុស្សណាម្នាក់ ជាអ្នកបញ្ជា មិនមែនម៉ាស៊ីន មិនមែនជាស្អីជាអ្នកបញ្ជាមនុស្សនោះទេ។ <តើអ្វីជា "ថ្នាក់លើ"ទៅ?>

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី លោកដឹងទេថា រស់ ញឹម ធ្លាប់ទទួលបញ្ជា ឬសេចក្ដីណែនាំពីភ្នំពេញទេជាពិសេស ពី ប៉ុល ពត ឬ នួន ជា ដើម្បីចាប់កម្មាភិបាលណាម្នាក់នៅក្នុងភូមិភាគរបស់គាត់នោះ?

[១០:៤១:៤៣]

**កញ្ញា លី និមល៖**

លោកតាដឹងទេថា រស់ ញឹម លោកបានយល់សំណួរឬនៅ?

**2-TCW-920៖**

**ឆ៖** គាត់ៗ ឮគេថា គាត់មើលក្ដាប់កន្លែងហ្នឹងហើយ គាត់មើលថានរណាមិនកើត គាត់ដកគេពីព្រោះគាត់--

**កញ្ញា លី និមល៖**

អត់ទេ លោកតា សំណួរសួរថា តើលោកតាដឹងថា រស់ ញឹម ធ្លាប់ទទួលបញ្ជាអំពី នួន ជា ឬក៏ប៉ុល ពត ដើម្បីចាប់ខ្លួនអ្នកណាគេម្នាក់អត់? ធ្លាប់ដឹងបញ្ជាហ្នឹងទេ លោកតា?

**2-TCW-920៖**

**ឆ៖** បាទ ហ្នឹងខ្ញុំក្តាប់មិនបានទេ។

**សួរដោយលោក វាំងសង់ វ៉ាយឌ័ ដេស្មាងលេ៖**

**ស៖** លោកសាក្សី នៅក្នុងរបបខ្មែរក្រហម តើលោកដឹងទេថា កម្មាភិបាលដែលគេចាប់ខ្លួនបាន ហ្នឹង ត្រូវបានគេជំរុញឲ្យឆ្លើយដាក់កម្មាភិបាលផ្សេងទៀតទេ?

**ឆ៖** អត់ដឹងទេ អត់ដឹង អត់មានទេ។

[១០:៤៣:០១]

**ស៖** ខ្ញុំមិនដឹងថា លោកចាំចម្លើយពីមុនរបស់លោក ឬក៏អត់ទេ។ ខ្ញុំ<នឹង>អានសម្រង់មួយនៃចម្លើយរបស់លោក នៅចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជា គឺ E3/10762, <ទំព័រ១៤ ដល់ទំព័រ១៥ ជាភាសាអង់គ្លេស<>, ជាភាសាខ្មែរ 00923746 ទៅដល់ 47។ មិនមានជាការបកជាភាសាបារាំងទេ។ អ៊ីចឹងខ្ញុំសុំដកស្រង់ជាភាសាអង់គ្លេស សុំដកស្រង់៖ "តាមដែលខ្ញុំគិត ការបោសសម្អាតហ្នឹង គឺថាដោយសារតែការឆ្លើយទម្លាក់កំហុស ដោយសារការធ្វើទារុណកម្ម ដែលជាការមួយមិនច្បាស់លាស់នោះទេ ឧទាហរណ៍ថា ខ្ញុំ<ត្រូវបានគេ>ចាប់ខ្លួន អ្នកឯងគឺជាជនក្បត់*(ស៊ីក)*។ ក៏ប៉ុន្តែ គឺថាខ្ញុំ<ត្រូវតែយកអ្នកឯងឲ្យចូល>ពាក់ព័ន្ធ<តាមរយៈការឆ្លើយ>ដាក់ទម្លាក់កំហុសទៅលើអ្នកឯង។ ខ្ញុំនឹងរៀបរាប់ឈ្មោះសហការីទាំងអស់ខ្ញុំ <ដើម្បីបានរួចខ្លួនពីការធ្វើទារុណកម្ម។> ហើយនៅពេលដែល<>ការធ្វើទារុណកម្ម<មានស្នាមរបួសធ្ងន់ធ្ងរ យើង>តែងតែឆ្លើយទម្លាក់កំហុសទៅលើអ្នកដទៃ។ ហើយការឆ្លើយទម្លាក់កំហុសអ្នកដទៃនេះ គេយល់ឃើញថាជាការពិតទៅវិញ។ ដោយសារតែហេតុផលនេះហើយទើបមនុស្សជាច្រើនត្រូវបានគេសម្លាប់ចោល។ ដូចជាការចាប់ខ្លួនប្រធានភូមិភាគ យើងឃើញហើយថាប្រធានភូមិភាគហ្នឹង គាត់ឆ្លើយទម្លាក់កំហុសទៅលើអ្នកណាខ្លះ គឺច្រើនមែនទែន។ ឧទាហរណ៍ ខ្ញុំគឺជាមនុស្សដែលគ្មានទោសពៃរ៍ទេ ក៏ប៉ុន្តែពេលដែលគេឆ្លើយទម្លាក់កំហុសមកលើខ្ញុំ គឺថាខ្ញុំត្រូវតែមានការជាប់ពាក់ព័ន្ធហើយ។" ហើយនៅត្រង់ទំព័រ<ជាភាសាអង់គ្លេស> 01066800, ខ្មែរ 00923747 លោកក៏បានឆ្លើយដូចតទៅ សូមដកស្រង់៖ "ខ្ញុំជឿជាក់ថា ហើយនេះគឺជាការពិតហើយ នេះគឺជាដំណើរការមួយដែលគេបានអនុវត្តនៅទីក្រុងភ្នំពេញនាពេលនោះ ដែលបានសម្លាប់មនុស្សរាប់រយពាន់នាក់ តាមរយៈការចាប់ខ្លួនដែលមានខ្សែរយៈនេះ រួមទាំងអ្នកគ្មានទោសពៃរ៍ផងដែរ។ ជឿខ្ញុំចុះ ថានេះជាការពិតហើយ"។ បញ្ចប់ការដក ស្រង់។

នៅសម័យនោះ លោកដឹងថាការធ្វើទារុណកម្ម ដើម្បីឲ្យមានការឆ្លើយដាក់អ្នកណាម្នាក់ហ្នឹង

---

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ត្រូវបានប្រព្រឹត្តិទៅនៅទីក្រុងភ្នំពេញទេ?

[១០:៤៥:៥៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់តប! អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

<សាក្សីស្ដាប់នូវអំណានដែលជាការយល់ឃើញរបស់គាត់តែប៉ុណ្ណោះ។> សាក្សីត្រូវតែផ្ដល់សក្ខីកម្ម<នូវ>អ្វីដែលខ្លួនបានដឹង បានឃើញ និងបទពិសោធន៍ធ្លាប់ជួបប្រទះ។ ដូច្នេះការយកសម្រង់<សក្ខីកម្មដែលជាការយល់ឃើញ>មកសួរគាត់<វិញគឺជាការចង់ឲ្យគាត់ឆ្លើយ>ចម្លើយស្មាន១<តែប៉ុណ្ណោះ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺថាសាក្សី គាត់ជាអ្នកឆ្លើយនៅពេលនោះ។ យើងតែងតែសួរតទល់សាក្សីនូវសក្ខីកម្មរបស់ខ្លួនបានឆ្លើយពីមុនៗរបៀបនេះឯង។

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹងចុះយើងម៉េចក៏មិនប្រាប់សាក្សី<ថា> សាក្សីត្រូវតែឆ្លើយតែអ្វីដែល<>ខ្លួនបានដឹង បានឮ បានឃើញ និងបានជួបប្រទះ។ <អ៊ីចឹងចាំបាច់នៅណែនាំសាក្សីបែបនេះធ្វើអ្វី។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូចដែលខ្ញុំបានជម្រាបជូនហើយ នេះគឺជាការអនុវត្តរយៈពេល២ឆ្នាំមកហើយ យើងតែងតែអនុញ្ញាតឲ្យភាគីដទៃធ្វើបែបនេះឯង។ <លោកមេធាវីខ្លួនឯងផ្ទាល់ក៏បានអនុវត្តបែបនេះជាច្រើនដងរួចហើយដែរ។> ការដែលខ្ញុំនិយាយដូច្នេះនេះ គឺថា <មិនមាននរណាម្នាក់រារាំងយើងមិនឲ្យសួរបញ្ជាក់ជាមួយសាក្សីពី>គំនិតយោបល់<នោះទេ។ បើសិននេះជាអ្វីដែល>គាត់<>មានបទពិសោធន៍ជួបប្រទះ<ដោយខ្លួនគាត់ នោះយើងនឹងដោះស្រាយរឿងនេះនៅក្នុងសាលក្រម>។

[១០:៤៧:៣០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកស្រីចៅក្រម ហ្វេនស៍ <>ខ្ញុំចង់ដឹងថានៅសម័យនោះ គាត់ដឹងអំពីការធ្វើទារុណកម្ម<និងមានការ>ឲ្យឆ្លើយដាក់ហ្នឹង <កើតឡើង>នៅភ្នំពេញ<ដែរឬទេ>។ អ៊ីចឹងខ្ញុំចង់ដឹងថាគាត់ដឹង ឬក៏

គាត់មិនដឹងត្រង់ចំណុចហ្នឹង។<>

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកដឹងទេថា នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គេ<បញ្ជូនមនុស្ស> ទៅភ្នំពេញ <>គេធ្វើទារុណកម្ម <ហើយអ្នកទាំងនោះ>ឆ្លើយដាក់អ្នកផ្សេងទៀត ឧទាហរណ៍ដូចថា ឆ្លើយខ្សែរយៈរបស់ខ្លួននោះមានអ្នកណាខ្លះអ៊ីចឹង។ លោកដឹងដោយខ្លួនឯងផ្ទាល់ទេ? អ៊ីចឹងខ្ញុំចង់ដឹងថា លោកដឹងដោយខ្លួនឯងផ្ទាល់ក្នុងរបបនោះ ឬក៏លោកដឹងក្រោយរបបនោះហើយទេ នូវអ្វីដែលខ្ញុំអានឲ្យលោកស្តាប់អម្បាញ់មិញហ្នឹង?

[១០:៤៨:៤២]

**2-TCW-920៖**

**ឆ៖** មិនបានដឹងទេ។

**កញ្ញា លី និមល៖**

សំណួរសួរថា ពីឆ្នាំ៧៥ ដល់៧៩ មានការធ្វើទារុណកម្មចំពោះអ្នកដែលបាននាំមកភ្នំពេញអត់ ដើម្បីឲ្យឆ្លើយនឹងសំណួរ មានការធ្វើទារុណកម្មចំពោះអ្នកដែលគេមកនៅភ្នំពេញអត់ ដើម្បីឆ្លើយនូវចម្លើយសារភាព លោកតាដឹងទេ ថាមានគេធ្វើទារុណកម្មអត់?

**2-TCW-920៖**

**ឆ៖** អត់ទេ នរណាដឹង បើវាឆ្ងាយគេ--

**ប្រធានអង្គជំនុំ៖**

ឈប់អាល។ បាទ ហើយ -- កុំអាលៗទាន់ឆ្លើយ លោក។ សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះ សាក្សី គាត់បានឆ្លើយនឹងសំណួររួចហើយ។ អ៊ីចេះ ខ្ញុំសូមអ្នកដែលជួយសម្រួល កុំអន្តរាគមន៍នៅពេលដែលសាក្សីឆ្លើយហើយ លើកលែងតែសំណួរហ្នឹង វាឆ្លើយទៅចាកប្រធាន ក្រែងលោវាស្តាប់គ្នាមិនបាន។ អ៊ីចឹងសូមលោកប្រធានជួយណែនាំផងបាទ។ សូមអរគុណ។

[១០:៤៩:៤៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំខ្លាចថា ខ្ញុំទៅមុខយឺតណាស់ ដោយសារតែមានបញ្ហាបច្ចេកទេស ហើយនិងមានការកាត់ផ្តាច់រហូតអ៊ីចឹង។ អ៊ីចឹងខ្ញុំព្យាយាមសួរទៅមុខឲ្យបានលឿន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំចង់ឲ្យលោកឆ្លើយតបទៅនឹងអ្វីដែលលោកបានឆ្លើយជូនជម្លូមណ្ឌលឯកសារកម្ពុជាគឺនៅក្នុងឯកសារ E3/9084 ទំព័រ៧២ ជាភាសាបារាំង, ៩៧ ជាភាសាអង់គ្លេស, ជាភាសាខ្មែរ 00057713 គឺលោកនិយាយពាក់ព័ន្ធនឹងអ្នកដែលត្រូវបានគេចាប់ខ្លួន។ ខ្ញុំសូមដកស្រង់៖ “បើគេចាប់អ្នកណាម្នាក់ គឺមានន័យថាអ្នកហ្នឹងក្បត់ហើយ។ ដូច្នេះត្រូវតែកម្ទេចអ្នកនុ៎ងចោល។ ខ្ញុំមិនឯកភាពទេ ពីព្រោះថាគេបង្ខំឲ្យនិយាយដោយសារគេវ៉ៃ គឺជួនកាលគេដកក្រចក ហើយដោយសារតែពួកគេទ្រាំមិនបាននឹងការធ្វើទារុណកម្មហ្នឹង គឺចេះតែឆ្លើយទៅ។” សូមបញ្ចប់ការដកស្រង់។ នៅពេលដែលលោកនិយាយថា នៅពេលដែលគេចាប់អ្នកណាម្នាក់នុ៎ងគឺ អ្នកហ្នឹងគឺក្បត់ហើយ ហើយត្រូវតែសម្លាប់ចោល។ អ៊ីចឹងខ្ញុំចង់សួរលោកថា នៅពេលដែលអង្គការចាប់អ្នកណាម្នាក់គឺអង្គការ<គិតថាខ្លួនឯងធ្វើ>ត្រូវរហូតមែនទេ?

**ឆ៖** គេតាមដានមើល បើថាអ្នកណាក្បត់ អ្នកណាអីគេដឹង គេត្រូវការចាប់ គឺមិនមែនថាចេះតែចាប់ទេ។ គេតាមដានមើលសិន។ គេមុននឹងចោទ មុននឹងចាប់ គេតាមដានមើលសកម្មភាព អ្នកហ្នឹងយ៉ាងម៉េច អីយ៉ាងម៉េច។

[១០:៥២:២១]

**ស៖** មុននេះយើងនិយាយអំពីកម្មាភិបាលមួយចំនួននៃតំបន់៣ដែលត្រូវបានចាប់ខ្លួន ហើយបាត់ខ្លួន។ លោកអាចជម្រាបបានទេថា តើមេដឹកនាំតំបន់១ត្រូវបាន រស់ ញឹម ចាប់ខ្លួនដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** នៅចំពោះមុខជម្លូមណ្ឌលឯកសារកម្ពុជា នៅក្នុងឯកសារ E3/9084 ទំព័រ<៥៥> ជាភាសាបារាំង, ៦០ ជាភាសាអង់គ្លេស និងជាភាសាខ្មែរ 00057680 លោកបាននិយាយថា តាសាយជាប្រធានតំបន់១។ ហើយក្រោយមកទៀត គេសួរ<ថា> “តាវ៉ាញ <ហ្នឹង?” ហើយលោកឆ្លើយ>ថា “តាវ៉ាញ ហ្នឹង ហើយក្រោយមកទៀតគឺ<ពួក>និរតី គេមកដល់”។ <បញ្ចប់ការដកស្រង់>។ អ៊ីចឹងខ្ញុំចង់ដឹងថា <លោកស្គាល់> តាវ៉ាញ <ច្បាស់ទេ? ហើយតើ>គាត់នៅរស់រានមានជីវិតពីរបបខ្មែរក្រហមទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា លី និមល៖**

តាវ៉ាញ ៗនៅរស់អត់? តាវ៉ាញ គាត់នៅរស់ពីរបបខ្មែរក្រហម ដល់បច្ចុប្បន្នអត់? លោកតាចាំទេ តាវ៉ាញ?

**2-TCW-920៖**

**ឆ៖** តាវ៉ាញ ៗណាអ៊ីចេះ? តាវ៉ាញ គាត់នៅតំបន់ណាអ៊ីចេះ? ខ្ញុំចាំមនុស្ស ប៉ុនមិនចាំ--

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ គប្បីសួរថា គាត់ស្គាល់ តាវ៉ាញ ដែរឬទេ។ អាហ្នឹងសំណួរទី១។ បើសិនជាគាត់ស្គាល់ ហ្នឹងសឹមតាំងសំណួរបន្ទាប់ទៀត ដែល សំណួរលោកសួរអម្បាញ់មិញនេះ។ យើងកត់សម្គាល់ព្រឹកនេះ លោកសួរ តែងតែសួរដូច្នេះ គឺមិនមាន សួរបញ្ជាក់អំពីភាពស្គាល់ ឬក៏មិនស្គាល់ជាមុនសិនទេ នាំបង្កើតជាបញ្ហា។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ លោកប្រធាន ខ្ញុំជឿថា ពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា គឺគាត់នៅចាំ អ៊ីចឹងគាត់ជា អ្នកឆ្លើយខ្លួនឯងហើយអំពីឈ្មោះហ្នឹងនោះ។ លោកសាក្សី ខ្ញុំនិយាយពីតំបន់១។ តំបន់១ហ្នឹង លោក ស្គាល់ឈ្មោះ តាវ៉ាញ ទេ គាត់ជាលេខាតំបន់១? ហើយលោកអាចជម្រាបបានទេថា មានរឿងអ្វីកើត ឡើងចំពោះ តាវ៉ាញ?

**កញ្ញា លី និមល៖**

តាវ៉ាញ ហ្នឹងគាត់ជាលេខានៅតំបន់១ លោកតាចាំ តាវ៉ាញ ដែលជាលេខានៅតំបន់១ អត់?

**2-TCW-920៖**

**ឆ៖** អត់ទេ អត់ចាំទេ។ (ឮមិនច្បាស់) មានតែតំបន់៣។ ខាងខ្ញុំដាក់ទៅតំបន់៣អស់ ទៅខាង គណៈតំបន់៣ មន្ទីរឃុំ។

**ស៖** ខ្ញុំមិនបានសួរលោកថា លោកទៅតំបន់៣ ឬក៏អត់ទេ។ អម្បាញ់មិញហ្នឹង ខ្ញុំ<អាន> ចម្លើយរបស់លោក ដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនៅក្នុងឯកសារហ្នឹង លោកនិយាយអំពីឈ្មោះ តាវ៉ាញ ដែល<បាន>ឡើង<កាន់>តំណែង<>ជំនួស តាសាយ ជាប្រធាន<> តំបន់១។ លោកនៅចាំទេ? <>

**ឆ៖** មិនចាំទេ ភ្លេចអស់ហើយ។

[១០:៥៦:៣៨]

**ស៖** សម្រាប់ជាប្រតិចារឹក ខ្ញុំសូមបង្ហាញឯកសារពីរ គឺ E3/2285 ដែលជាបញ្ជីស-២១ ដែលមានចំណងជើងថា "ឈ្មោះអ្នកទោសកម្មេចនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧" នៅទំព័រជាភាសាអង់គ្លេស00873644, ជាភាសាខ្មែរ 00009307 មិនមានជាភាសាបារាំងទេ។ យើងឃើញនៅលេខរៀងទី១២២ គឺមានឈ្មោះ ជា ហួន ហៅ វ៉ាញ លេខាតំបន់១ ចូលស-២១ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ កម្មេចនៅថ្ងៃទី១៨ តុលា ១៩៧៧។ លោកសាក្សី លោកចាំអំពីមេដឹកនាំតំបន់២ទេ ហើយលោកដឹងថា អ្នកទាំងអស់ហ្នឹង ត្រូវបានគេចាប់ខ្លួនទេ នៅពេលដែល រស់ ញឹម ដឹកនាំ ឬក៏គ្រប់គ្រងភូមិភាគពាយ័ព្យនុ៎ង?

**កញ្ញា លី និមល៖**

យល់សំណួរទេ លោកតា?

**2-TCW-920៖**

**ឆ៖** វាមិនបានចាំទេ ខ្ញុំភ្លេចអស់ហើយៗ ម្យ៉ាងទៀត គឺពេលនោះ យើងមិនបានទៅទាក់ទងគ្នាធ្វើការងារទៅលើគេទេ កន្លែងឯងធ្វើ កន្លែងឯង ខំតែកន្លែងឯងទៅណា ដឹកនាំប្រជាជនធ្វើស្រែធ្វើចម្ការទៅ។ អារឿងគេ យើងមិនបានទៅធ្វើអីលើគេទេ។

[១០:៥៨:៥២]

**ស៖** បាទ លោកថាលោកភ្លេច។ បាទ ដើម្បីរំឭកការចងចាំរបស់លោក ខ្ញុំបញ្ជាក់ឱ្យលោកស្ដាប់ គឺឈ្មោះ វ៉ែន ឈ្មោះពេញគាត់ <ស្រេ> អឿន – ហៅ វ៉ែន។ លោកធ្លាប់ឮឈ្មោះហ្នឹងទេ?

**កញ្ញា លី និមល៖**

លោកតាធ្លាប់ឮឈ្មោះ ស្រី អឿន ហៅ វ៉ែន អត់លោកតា? ធ្លាប់នៅឈ្មោះហ្នឹងទេ?

**2-TCW-920៖**

អត់ដឹង។

**កញ្ញា លី និមល៖**

អត់ដែលឮទេ?

**2-TCW-920៖**

**ឆ៖** អត់ដែល។ មិនបានដឹងទេ (ឮមិនច្បាស់) មិនបានគ្រប់គ្រងទៅលើគេទេ នៅតែឯង ខិតខំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ធ្វើតែឯង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្ពាឯល៖**

**ស៖** បាទ ខ្ញុំនឹងអានឈ្មោះមួយចំនួនដែលធ្វើការនៅក្នុងតំបន់៣ ជាកន្លែងដែលធ្វើការ គឺឈ្មោះកម្មាភិបាល។ លោកធ្លាប់ឮឈ្មោះ គូ ទេអនុលេខាតំបន់៣?

**កញ្ញា លី និមល៖**

គូ ជាអនុលេខាតំបន់៣ៗលោកតាធ្លាប់ឮទេ ឈ្មោះ គូ? គាត់ជាអនុលេខាតំបន់៣ លោកតាធ្លាប់ឮឈ្មោះទេ?

**2-TCW-920៖**

**ឆ៖** មិនដែលបានឮផង។

**កញ្ញា លី និមល៖**

គូ អត់បានឮទេ?

**2-TCW-920៖**

**ឆ៖** អត់។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្ពាឯល៖**

**ស៖** ចុះឈ្មោះ ប៉ា លេខាស្រុកភ្នំសំពៅ លោកធ្លាប់ឮទេ?

**កញ្ញា លី និមល៖**

ឈ្មោះ ប៉ា លោកតាធ្លាប់ឮទេ ប៉ា លេខាភ្នំសំពៅធ្លាប់ឮទេលោកតា?

**2-TCW-920៖**

**ឆ៖** មិនដែលបានជួបបានឮផង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្ពាឯល៖**

**ស៖** ចុះឈ្មោះ ចាន់ អឿន លេខាស្រុកមង្គលបុរី លោកធ្លាប់ឮទេ?

**2-TCW-920៖**

**ឆ៖** អត់ទេ។ បើយើងថ្នាក់ធំប៉ុណ្ណឹង មិនបានទៅឮដឹងឮអី នៅតែខំធ្វើការកន្លែងឯងអី។

[១១:០២:០៧]

**ស៖** បាទ ខ្ញុំបន្តមិនបន្តសួរទៀតទេ ក៏ប៉ុន្តែនៅក្នុងសំណុំរឿងជាប្រតិចារឹកយើងមានចម្លើយ

សារភាពរបស់ គូ ជាអនុលេខាតំបន់៣ គឺឯកសារ E3/7372, ចម្លើយសារភាពរបស់ ហ៊ា លេខាស្រុកភ្នំសំពៅ គឺឯកសារ E3/7359 និងចម្លើយសារភាព E3/7353 ជាចម្លើយសារភាពរបស់ ចាន់ អឿន លេខាស្រុកមង្គលបុរី។ អ្នកទាំងបីបានឆ្លើយសារភាពនៅដើមឆ្នាំ១៩៧៨ គឺមុនពេលចាប់ខ្លួន រស់ ញឹម។ លោកសាក្សី លោកដឹងទេថា រស់ ញឹម បានចាប់កម្មាភិបាលតំបន់៤ ដោយសារតែមានហេតុការណ៍ដែលកើតឡើងនៅទីនោះ?

**កញ្ញា លី និមល៖**

លោកតាឆ្លើយសំណួរ លោកតាឮសំណួរគេសួរទេ? ឮសំណួរគេសួរអម្បាញ់មិញទេ? ឮសំណួរគេសួរអំមិញ? សុំសួរម្តងទៀត សុំឲ្យគេសួរសំណួរមួយសាទៀត។

**2-TCW-920៖**

**ឆ៖** ខ្ញុំក្តាប់មិនបានទេ ព្រោះខ្ញុំវានៅតែកន្លែងខ្ញុំគេឲ្យខំធ្វើការតែប៉ុណ្ណឹង កន្លែងខ្ញុំណា កន្លែងគេផ្សេងៗ ខ្ញុំមិនបានក្តាប់ផ្ទាល់លើគេបានទេ។

[១១:០៤:០១]

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** បាទ ខ្ញុំដឹងហើយលោកសាក្សី ក៏ប៉ុន្តែខ្ញុំចង់អានអ្វីដែលលោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9084 និយាយអំពី<>អ្នកដឹកនាំតំបន់៤ ទំព័រជាខ្មែរ <00057680> ជាបារាំងគឺ <នៅទំព័រ៤៤> ជាភាសាអង់គ្លេសទំព័រ៦0<>។ ដកស្រង់៖ “នៅក្នុងគណៈតំបន់៤ មានតាវួច តាស៊ុយ ហើយបន្ទាប់មកទៀត នៅពេលដែលគេចាប់ ស៊ុយ ហើយហ្នឹងនៅសល់តែ វួច ហើយនិង ប៉ាង ទេ។ ហើយក្រោយមកទៀត គេចាប់ វួច និង តាប៉ាង ហ្នឹងទៀត ចាប់ទាំងអស់មិនដឹងឯណាឯណីទេ។” សូមបញ្ចប់ការដកស្រង់។ តើលោកនៅចាំឈ្មោះ តាស៊ុយ នៅតំបន់៤ ហើយនិងតាប៉ាង ហ្នឹងដែរឬទេ?

**ឆ៖** ចាំតែឈ្មោះ តែមនុស្សមិនដឹងនៅឯណាអស់ទេ។ តាស៊ុយ នៅស្រុកលើជាមួយខ្ញុំដែរ។ គេរកចាប់ទាំងពីរដែរ ដល់ចាប់មក គេយកមកវិញ មិនដឹងគេទៅកាន់កាប់ខាងណាអីខាងណារហូតទៅបែកគ្នាអស់។

[១១:០៥:០៦]

**ស៖** នៅក្នុងឯកសារដដែលគឺ ឯកសារ E3/9084 ជាភាសាបារាំងគឺ ទំព័រ៥៤, ៥៥, ជា

អង់គ្លេស ទំព័រ៧៤, ជាភាសាខ្មែរគឺ 00057692។ លោកបាននិយាយដូចតទៅនេះ លោកបាននិយាយថា លោកបានរាយការណ៍ទៅប្រាប់ រស់ ញឹម ថា អ្នករស់នៅតំបន់៤ ហ្នឹងដាច់អាហារស្លាប់។ ហើយបន្ទាប់មក ពេលគាត់ដឹងហើយ ក៏គាត់ចេញទៅស៊ើបអង្កេត ហើយកាលនោះ ឃើញថាជាការពិតមែន ក្រោយមកគេចាប់គណៈតំបន់ ហើយនិងគណៈឃុំ។ ហើយចាប់ហ្នឹងទាំងខ្សែៗ ហើយបន្ទាប់មកទៀត បានគេចាប់ផ្ដើមចាប់ ស៊ុយ។ ស៊ុយ ហ្នឹងបាត់ខ្លួនមុនគេ។ គាត់ចាប់ស៊ុយ ហើយបន្ទាប់មក ទៅចាប់អ្នកនៅតំបន់៤ទៀត មានតារូច ហើយនិង តាប៊ាង។ ហើយបន្ទាប់ពីចាប់ខ្លួនអ្នកទាំងអស់ហ្នឹងហើយ ក៏ចាប់ តាវង ទៀត <>ប្រើពេលប៉ុន្មានខែដែរទម្រាំតែចាប់បាន។ ចុងក្រោយចាប់ តាវង ហ្នឹងបាន។ តើលោកមាននៅចាំទេថា លោកបានឆ្លើយចម្លើយទាំងអស់ហ្នឹងថា រស់ ញឹម ហ្នឹងចាប់ ស៊ុយ ហើយនិងចាប់កម្មាភិបាលនៅតំបន់៤ហ្នឹង ទាំងខ្សែៗតែម្ដង?

**ឆ៖** ខ្ញុំមិនបានចាំបាននេះទេ ពីព្រោះថា នៅដាច់ដោយឡែកពីគ្នា។ ខ្ញុំមិនបាននៅ ខំធ្វើការនៅកន្លែងឯង អាកន្លែងគេផ្សេងៗ ឋានៈប្រហែលខ្ញុំ ខ្ញុំមិនបានទៅតាមដានផង។

**ស៖** បាទ ដើម្បីជាកំណត់ត្រាប្រតិចារឹក នៅបញ្ជី E3/2285 ទំព័រជាភាសាអង់គ្លេសគឺ 00873637, ជាភាសាខ្មែរគឺ 00009304។ វាជាបញ្ជីមន្ទីរស-២១ ដែលមានចំណងជើងថា ឈ្មោះអ្នកទោសដែលត្រូវ<កម្ទេច>នៅថ្ងៃទី១៨ តុលា ឆ្នាំ១៩៧៧។ អ្នកទោសចូលមកខែកក្កដា ឆ្នាំ១៩៧៧ នៅលេខរៀងទី៣៤ ហ្នឹងមានឈ្មោះ ស៊ុយ។ <>ឈ្មោះពេញគាត់គឺ ស៊ុន គុណ ហៅស៊ុយ ដែលជា អនុលេខាតំបន់៤។ ហើយក៏មានផងដែរ មានឈ្មោះ ប៊ាង ដែលសាក្សីរូបនេះបាននិយាយពី<ឈ្មោះ> ប៊ាង នេះដែរ ចំពោះមុខមជ្ឈមណ្ឌលឯកសារកម្ពុជាថា គាត់ហ្នឹង<ជាលេខាតំបន់៤។ គាត់នេះ ចូលមកមន្ទីរស-២១ ថ្ងៃទី១៣ មីនា ១៩៧៨> -- បាទ គឺឯកសារ E3/1942 ជាភាសាអង់គ្លេសគឺ 001 83855, ជាភាសាបារាំង 00870455, ជាភាសាខ្មែរ 00040024។ អ៊ីចឹង ខ្ញុំសួរលោកថា តើលោកមានស្គាល់គណៈតំបន់៥ ឈ្មោះ ហឿង ទេ?

**ឆ៖** តំបន់៥ អ្នកណាចេះតំបន់៥?

**កញ្ញា លី និមល៖**

តំបន់៥ ឈ្មោះ ហឿង គណៈ--

**2-TCW-920៖**

**ឆ៖** តំបន់៥ៗ--

**កញ្ញា លី និមល៖**

ឈ្មោះ ហឿងៗ លោកតាចាំទេ ឈ្មោះ ហឿន?

**2-TCW-920៖**

**ឆ៖** អាហឿន វាបាត់ មិនដឹងទៅខាងណាបាត់ទៅ។

**កញ្ញា លី និមល៖**

តើលោកតាធ្លាប់ស្គាល់ឈ្មោះហ្នឹងទេ?

**2-TCW-920៖**

**ឆ៖** តាហឿនហ្នឹង?

**កញ្ញា លី និមល៖**

ចាស។

**2-TCW-920៖**

**ឆ៖** ស្គាល់ គាត់រត់បាត់ទៅ។

[១១:១០:៥៨]

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** តើលោកស្គាល់អនុប្រធានគាត់ដែរឬទេ ព្រោះលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាថាមានឈ្មោះ ឆ្នាំង។

**ឆ៖** *(ឮមិនច្បាស់)*

**លោក ម៉ម រិទ្ធា៖**

ឈ្មោះ ឆ្នាំងៗស្គាល់ទេ?

**2-TCW-920៖**

**ឆ៖** ឆ្នាំង កូន តារស់?

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល៖**

**ស៖** បាទគឺ ឆ្នាំង កូន រស់ ញឹម ហ្នឹង។ អ៊ីចឹងគាត់ហ្នឹង<មានតួនាទីអ្វី ធ្វើការ>ជាមួយ ហឿង <នៅតំបន់៥>ហ្នឹង?

**កញ្ញា លី និមល៖**

ឆ្នាំង ធ្វើការនៅតំបន់៥ ហ្នឹងតួនាទីគាត់ជាអនុប្រធាន ឬក៏ជាអី?

**2-TCW-920៖**

**ឆ៖** អាឆ្នាំង នោះ?

**កញ្ញា លី និមល៖**

ចាស ឆ្នាំង ហ្នឹង។

**2-TCW-920៖**

**ឆ៖** អា ឆ្នាំង ហ្នឹង កូន តារស់ ញឹម។

**កញ្ញា លី និមល៖**

ប៉ុន្តែគាត់ធ្វើការនៅតំបន់៥ តួនាទីគាត់ជាអី?

[១១:១២:០០]

**2-TCW-920៖**

**ឆ៖** អាហ្នឹងវាការជាមួយកូនតា សោ ភឹម។ សោ ភឹម និង រស់ ញឹម ដន្លងគ្នា។ ហើយខាង--

**កញ្ញា លី និមល៖**

ប៉ុន្តែ ឆ្នាំង ហ្នឹងតួនាទីគាត់ជាអីនៅក្នុងតំបន់៥?

**2-TCW-920៖**

**ឆ៖** កាលនោះនៅក្មេង មិនចាត់តាំងឲ្យធ្វើអី។ អាឆ្នាំង ហ្នឹងទើបបានកូន រស់ ញឹម ហ្នឹង -- អ៊ំ! បានកូន សោ ភឹម។ កូន សោ ភឹម និង រស់ ញឹម ត្រូវដន្លងគ្នា។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

បាទ ខ្ញុំសូមអរគុណហើយ លោកប្រធាន ខ្ញុំសូមឲ្យអ្នកជំនួយការហ្នឹងខាងគាំពារសាក្សីនោះកុំឲ្យចោទសំណួរបន្ថែមពីលើខ្ញុំ។ <យ៉ាងណាក៏ដោយចុះ ក៏សូមថ្លែងអំណរគុណគាត់ក្នុងការជួយ>។

**ស៖** លោកសាក្សីតើដឹងមានរឿងអីកើតឡើងចំពោះ តាហឿង <ដែល>ជាប្រធានតំបន់៥ <ដែរឬទេ>? តើ រស់ ញឹម ចាប់គាត់<ដែរ> ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅយើងអត់យល់ដែរ ព្រោះយើងមើលវាពិបាក ហើយក្រែងលោដំណើរការហ្នឹងវាបញ្ហាខ្លាំងពេក។ ឥឡូវហ្នឹងលោកចង់ប្រាប់យើងថា បញ្ឈប់កុំឲ្យគាត់ធ្វើអន្តរាគមន៍ក្នុងការបញ្ជាក់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សំណួររបស់លោកចំពោះសាក្សី ឬយ៉ាងម៉េច? យើងដូចជាមានបញ្ហាមិនច្បាស់លាស់ទេ។

[១១:១៣:៤៨]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

មិនមែនទេលោកប្រធាន ខ្ញុំចង់និយាយថា មុនហ្នឹងអំមិញហ្នឹងនេះគឺថា ខាង វេ.ស៊្វ ហ្នឹងគាត់សួរអាយុរបស់កូន រស់ ញឹម ហ្នឹង <និងថាតើគាត់រៀបការហើយឬនៅ ជាដើម>។ សំណួរនេះ ខ្ញុំអត់បានសួរទេលោកប្រធាន។ អ៊ីចឹងសូមកុំឲ្យគាត់ចោទសំណួរបន្ថែមពីលើសំណួរដែលខ្ញុំសួរនោះ លោកប្រធាន ខ្ញុំចង់និយាយអ៊ីចឹងទេអំមិញនោះ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ ឥឡូវ ខ្ញុំសូមអនុញ្ញាតចោទសំណួរបន្ត។ អ៊ីចឹងខ្ញុំចង់ដឹងថា តើមានរឿងអីកើតឡើងចំពោះ តាហឿង <>ជាប្រធានតំបន់៥ នោះ? តើគាត់ហ្នឹង<នៅ>ក្នុងចំណោមដែល រស់ ញឹម ចាប់ខ្លួនដែរ ឬក៏យ៉ាងណា?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សំណួរនេះគឺថាបានសួរពីរ<បី>ដងរួចមកហើយ។ ហើយខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរនេះ។ ថាហេតុអ្វីបានជាកម្មាភិបាលទាំងនោះត្រូវបានចាប់<ខ្លួន>ដោយ រស់ ញឹម វាអាចត្រូវអ្នកណាម្នាក់ជាអ្នកចាប់ខ្លួនទៅវិញ។ ដូច្នេះហើយសំណួរគួរតែសួរថា តើគាត់ត្រូវបានគេចាប់ខ្លួនឬ<ទេ>? ហើយបើបានចាប់ខ្លួន តើ<នរណា>ជាអ្នកចាប់ខ្លួនគាត់?

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទ ខ្ញុំរៀបសំណួរឡើងវិញ លោកសាក្សី។ តើ តាហឿង ត្រូវបានគេចាប់ខ្លួននៅពេលដែល រស់ ញឹម ជាប្រធានភូមិភាគពាយ័ព្យដែរឬទេ?

**លោក ម៉ម រិទ្ធា៖**

ស្ដាប់សំណួរអត់បាន លោកតាឲ្យគេសួរម្ដងទៀត។

[១១:១៦:០០]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញារងអន្តរជាតិ តាំងសំណួរម្ដងទៀត។ ហើយជំនួយពី និមល នៅតែដដែលទេ គ្រាន់តែ និមល កុំបន្ថែមសំណួរ ហើយក្ដាប់សំណួរឲ្យបាន ហើយសួរយកតែចំណុចសំខាន់នៃ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សំណួរទៅ កុំឲ្យយកការរៀបរាប់របស់អ្នកសួរហ្នឹង គឺយើងមិនចាំបាច់ទេណា៎ ដើម្បីឲ្យក្ដាប់បញ្ហាហ្នឹងបាន។ ហើយបើអាចកត់ហ្នឹង គឺកត់ត្រាផង ដើម្បីឲ្យសំណួរហ្នឹង គឺជាក់លាក់ត្រឹមត្រូវ នូវការបញ្ជូនសំណួររបស់អ្នកសួរ ទៅឲ្យគោលដៅដែលត្រូវឆ្លើយណ៎ះ!

តាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្ដងទៀត។

[១១:១៦:៤៥]

**សួរដោយលោក វ៉ាំងសង់ វ៉ាយអ៍ ដេស្មាឯល៖**

**ស៖** នៅតំបន់៥ តើ តាហឿង នេះ ត្រូវបានចាប់ខ្លួននៅពេលដែល រស់ ញឹម ជាលេខាភូមិភាគពាយ័ព្យដែរឬទេ?

**កញ្ញា លី និមល៖**

នៅពេលដែលតា -- នៅពេលដែល រស់ ញឹម គាត់ៗធ្វើ មានបានចាប់ខ្លួន តា--

**2-TCW-920៖**

**ឆ៖** ហឿន!

**កញ្ញា លី និមល៖**

សុំៗសំណួរមួយសាទៀត ខ្ញុំអត់ទាន់ដែរ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយអ៍ ដេស្មាឯល៖**

**ស៖** បាទ សំណួរខ្ញុំ<ងាយយល់>ទេ។ យើងនិយាយអំពីតំបន់៥ ហើយនិងអ្នកដឹកនាំនៅតំបន់៥ហ្នឹង គឺ តាហឿង។ តើ តាហឿង ហ្នឹង ត្រូវបានចាប់ខ្លួន នៅពេលដែល រស់ ញឹម ធ្វើជាលេខាភូមិភាគពាយ័ព្យដែរឬទេ?

**កញ្ញា លី និមល៖**

តើ តាហឿង ត្រូវបានចាប់ខ្លួនដល់ ចាស --

**2-TCW-920៖**

**ឆ៖** នៅកាលនោះ តា រស់ ញឹម គាត់ភូមិភាគពាយ័ព្យនៅឡើយ ដក ហឿន ចេញទៅបាត់។

[១១:១៨:២៤]

**សួរដោយលោក វ៉ាំងសង់ វ៉ាយអ៍ ដេស្មាឯល៖**

**ស៖** បាទ នៅសំណុំរឿង គឺចម្លើយសារភាពរបស់ ម៉ែន ជុន ហៅ ហ៊ីង្ស ជាលេខាតំបន់៥ គឺ

ឯកសារ E3/2474 ហើយនិងឯកសារ E3/1558។ លោកសាក្សី ខ្ញុំមកចូលនិយាយអំពីការចាប់ខ្លួន រស់ ញឹម វិញម្តង។ តើលោកដឹងរឿងអ្វីខ្លះអំពីការចាប់ខ្លួន រស់ ញឹម នេះ?

**2-TCW-920៖**

**ឆ៖** គេចាប់ រស់ ញឹម គឺពួកនិរតីគេចាប់ ក្រោយគេពួកនិរតីគេមក គេចាប់ ពួកហ្នឹងគេថា រស់ ញឹម ចូលដៃយួន តា រស់ ញឹម ហ្នឹង។ បាទពួកនិរតីគេចាប់តា រស់ ញឹម ទៅទៀត។ គេដាន់កគ្នាអ៊ីចឹង។

**ស៖** ពេលដែលលោកនិយាយអំពីនិរតីនេះ លោកសំដៅលើ<នរណា>ជាក់លាក់ <ហើយដែលក្រោយមក>ទៅកាន់មុខតំណែងនៅ<ភូមិភាគ>ពាយ័ព្យ?

[១១:១៩:៥០]

**ឆ៖** ពួកនិរតីមកក្រោយ តា -- និរតីពួកតាៗ តាម៉ុក, តាទិត្យ។ អាហ្នឹងពួកមកថ្មី និរតីចាប់ពួកពាយ័ព្យទៅណា។

**ស៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**កញ្ញា អង់តា ហ្គីសសេ៖**

លោកអត់បើកមីក្រូផង។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណ។

**ស៖** លោកនិយាយថា រស់ ញឹម ត្រូវបានគេចាប់ខ្លួន ដោយសារគាត់ហ្នឹងចូលដៃខាងយួន។ តើលោកបានចូលរួមក្នុងកិច្ចប្រជុំ <ឬ>កម្មាភិបាលមកពីនិរតីបាន<ប្រាប់លោក ដោយ>និយាយលម្អិតអំពីការចាប់ដៃគ្នាជាមួយ<យួន> ឬក៏ការក្បត់នេះដែរឬទេ?

[១១:២១:៣៨]

**2-TCW-920៖**

**ឆ៖** ខាងពួកនិរតីគេចោទគាត់អ៊ីចឹងហើយ បានគេចាប់គាត់ – ចាប់ រស់ ញឹម។ គេចោទពួកពាយ័ព្យហ្នឹង វាមិនស្មោះត្រង់។

**កញ្ញា លី និមល៖**

លោកតា សំណួរសួរថា តើលោកតាបានចូលរួមក្នុងការប្រជុំនិយាយអំពីបក្សក្បត់ជាមួយនឹងវៀតណាមអត់ លោកតាបានចូលរួមការប្រជុំហ្នឹងអត់?

2-TCW-920៖

ឆ៖ អត់ទេ។ អត់ទេ ព្រោះខ្ញុំតូចតាច គេឱ្យខំតែធ្វើការគ្នាឯងទៅ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តាមអ្វីដែលគេរាយការណ៍ប្រាប់លោកនោះ តើ រស់ ញឹម គាត់មានភ្ញាក់ផ្អើលទេ ពេលដែលគេចាប់ខ្លួនគាត់ហ្នឹង?

[១១:២២:៤៦]

**កញ្ញា លី និមល៖**

រស់ ញឹម បានភ្ញាក់ផ្អើលអត់ នៅពេលដែលគេមកចាប់ខ្លួនគាត់ គាត់ភ្ញាក់ផ្អើលអត់ នៅពេលដែលមានគេមកចាប់ខ្លួនគាត់?

2-TCW-920៖

ឆ៖ កាលពួកនិរតីចាប់ រស់ ញឹម ហ្នឹង គេចាប់ចូលមកកន្លែងសាលាសាកលនេះ ហើយគាត់ឆ្លើយថាក្បត់។ ពួកនិរតីគេចាប់ពួកពាយ័ព្យនោះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើនៅពេលដែលគេចាប់គាត់ហ្នឹង ឬក៏ប៉ុន្មានថ្ងៃ<> ប៉ុន្មានសប្តាហ៍ <ឬខែមុនពេលគេ> ចាប់ខ្លួនគាត់ហ្នឹង <ថាតើ> រស់ ញឹម ហ្នឹង<>មានព្យាយាមប្រឆាំងនឹងកម្មាភិបាលមកពីនិរតីទេ? <>

[១១:២៣:៤៩]

**កញ្ញា លី និមល៖**

មុនពេលដែល រស់ ញឹម ត្រូវបានចាប់ខ្លួន--

2-TCW-920៖

ឆ៖ អត់ទេ ពីព្រោះគេចោទថាពាយ័ព្យក្បត់ហើយ គឺនិរតីគេដកគាត់ចេញហើយ គេចាប់គាត់បញ្ជូនទៅភ្នំពេញបាត់អស់។ ក្រោយពេលគេចោទថាគាត់ក្បត់ គេមកនាំទាំងកូនគាត់ទៅអស់ទៀត ទៅភ្នំពេញទៅសម្លាប់ចោលអស់។ ប្រពន្ធគាត់នៅខ្សាច់ពោយនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើលោកមានប្រតិកម្មយ៉ាងម៉េចដែរ នៅពេលដែលលោកដឹងថាគេចាប់ខ្លួន រស់ ញឹម នៅបាត់ដំបងហ្នឹង?

**ឆ៖** អត់ទេ អត់មានប្រតិកម្មអីទេ ព្រោះនៃខ្ញុំវាក្រោមការដឹកនាំ ព្រោះគាត់នៅខាងលើគេចោទគាត់ទៅវា ខ្ញុំមិនដឹងធ្វើម៉េច។

**ស៖** បាទ នៅក្នុងចម្លើយរបស់លោកចំពោះមុខឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/9084 <សេចក្តី>ព្រាង<ឯកសារ>ជា<ភាសា>អង់គ្លេសទំព័រ៣០, និងជាភាសាបារាំង ២២-២៣, ជាភាសាខ្មែរគឺ 00057656។ ពេលដែលលោកឆ្លើយដូចតទៅនេះ គាត់ថា ពេលដែល<> គាត់<ស្លាប់ទៅ>ហ្នឹង លោកសោកស្តាយ<ណាស់។> ហើយពួកហ្នឹងវា<សម្លាប់>តែកម្មាភិបាលគ្នាឯងហ្នឹង គ្មានអ្នកណានៅរស់ទេ។ អ៊ីចឹងខ្ញុំសួរលោកថា ហេតុអ្វីបានលោកសោកស្តាយនៅពេលដែលគេចាប់ខ្លួន រស់ ញឹម<>?

**ឆ៖** ខ្ញុំស្តាយ ពីព្រោះខ្ញុំមិនដឹងថាគាត់ក្បត់យ៉ាងម៉េចផង។ ហើយគ្នាឯង ចាប់គ្នាឯង ចោទគ្នាឯង។ ពួកនិរតីចោទពាយ័ព្យក្បត់ ចាប់ពួកពាយ័ព្យពួកអី។ ដល់ខ្ញុំឃើញអ៊ីចឹង គឺដកថយមកស្ទឹងទៅ។ ដល់ខ្ញុំនៅអូរដំបង ក្រោយទៀត គេដកខ្ញុំទៅនៅស្ទឹង។

[១១:២៦:៤៥]

**ស៖** បាទ ពេលដែលលោកទាក់ទងជាមួយ រស់ ញឹម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង តើលោកធ្លាប់<ឃើញថាមានពេលណាមួយនោះ> រស់ ញឹម ហ្នឹងគាត់មិន<ស្មោះ>ត្រង់ជាមួយបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ពួកនិរតីគេចោទ ហើយគេចោទថា រស់ ញឹម គាត់ក្បត់។

**កញ្ញា លី និមល៖**

លោកតាដែលសង្កេតឃើញខ្លួនឯងអត់ថា គាត់ធ្លាប់ក្បត់? លោកធ្លាប់មាន ធ្លាប់សង្កេតខ្លួនឯងអត់? ធ្លាប់បានសង្កេតខ្លួនឯង?

**2-TCW-920៖**

**ឆ៖** ធ្លាប់សង្កេតដែរ ប៉ុនគាត់មិនដែលធ្វើ ធ្លាប់ធ្វើខុស អត់ទេ។ ប៉ុនគេចោទ និរតីគេចោទពាយ័ព្យ។ ចោទគ្នាអ៊ីចឹង។ និរតីមក ក្រោយមកគ្រប់គ្រងចោទពាយ័ព្យក្បត់ ចាប់ពួកពាយ័ព្យ។ គ្នាឯងចាប់គ្នាឯង។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណ។ បាទ សូមអរគុណលោកប្រធាន។ ខ្ញុំដឹងពីពេលវេលាហើយ។ មេធាវីដើម

បណ្តឹងរដ្ឋប្បវេណី គាត់ត្រូវការពេលពី៥ ទៅដល់១០នាទី។ ខ្ញុំមានសំណួរមួយចំនួនទៀត ដែលត្រូវសួរ។ តើខ្ញុំ<អាច>បន្តសួរដល់ម៉ោងដប់មួយ សែសិបប្រាំនាទីបានទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ អត់ទេ។ បើមានខាងដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរ សុំប្រគល់វេទិកាជូនទៅដើមបណ្តឹងរដ្ឋប្បវេណី បាទ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមប្រគល់ម៉ោងដែលនៅសេសសល់ហ្នឹងជូនទៅខាងសហព្រះរាជអាជ្ញា លោកប្រធាន។

[១១:២៨:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ សុំអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ បើដូច្នោះ។

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្នាងលេ៖**

**ស៖** ខ្ញុំនឹងព្យាយាមបញ្ចប់ឲ្យលឿន។ ហើយនិងនិយាយ-- អំពីការសម្អាតក្រោយពេលដែល<គេចាប់> រស់ ញឹម <ព្រោះយើងមានធាតុផ្សំគ្រប់គ្រាន់នៅក្នុងសំណុំរឿង>។ ខ្ញុំសុំនិយាយ<ត្រឡប់ទៅកាន់អ្វីដែល នួន ជា បាននិយាយចំពោះមរណភាពរបស់ រស់ ញឹម។> គាត់<និយាយថា គាត់មិន>សោកស្តាយទេ។ <អ្វីដែលគាត់និយាយនោះមាន>នៅក្នុងសៀវភៅ ដែល<ជា>ឯកសារលេខ <E3/4202>។ <នេះជាសៀវភៅរបស់ ជីណា ចន និង ថេត សម្បត្តិ មានចំណងជើងថា "នៅពីក្រោយវាលពិឃាត"> ជាភាសាអង់គ្លេសគឺ 00757530, ជាភាសាបារាំង 00849433, ជាភាសាខ្មែរ 00858336។ <>អ៊ីចឹង ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស ព្រោះសៀវភៅនេះ សរសេរជាភាសាអង់គ្លេស៖ "ក្នុងចំណោមជនជាប់ចោទ គឺមាន វន វ៉េត, កុយ ធួន ហើយនិងលេខាពាយ័ព្យ គឺ រស់ ញឹម ។ បន្ទាប់ពីរស់នៅជាបងប្អូន វាយប្រហារជាមួយខ្មាំងតែមួយ ឥឡូវ<ពួកគេត្រូវចាត់ទុកថាជាជនក្បត់ទៅវិញ>។ "យើងមិនដែលចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ណាមួយ ដោយគ្មានភស្តុតាង ឬក៏សាក្សីឡើយ" នួន ជា បាននិយាយបែបនេះ។ ហើយ នួន ជា បានបន្តទៅទៀតថា៖ "យើងដឹងច្បាស់អំពីការក្បត់ ក៏ដូចជាផែនការក្បត់ ដើម្បីផ្តួលរំលំរបប ហើយនិងសម្លាប់ប្រជាជនស្លូតត្រង់នៅតាមខេត្ត ដោយមិនមានបញ្ជាពីមជ្ឈិម និងមិន<>មានការដឹងឮពីមជ្ឈិម។ ប៉ុល ពត <>មានភស្តុតាង និងសាក្សី។

ដូច្នេះ គាត់សម្រេចចាប់ខ្លួនជនក្បត់ទាំងនេះ។ ខ្ញុំពុំមានការសោកស្ដាយឡើយ ព្រោះនៅពេលខ្ញុំបានអានចម្លើយសារភាព ខ្ញុំបានដឹងយ៉ាងច្បាស់ថា តើមនុស្សទាំងនេះកំពុងធ្វើអ្វី?”។

[១១:៣១:១៤]

ទំព័របន្ទាប់ គឺភាសាអង់គ្លេសមានលេខ ERN ដូចគ្នា គឺទំព័រ១០៣ <ភាសា>បារាំងមានលេខ <00849434>, ខ្មែរមានលេខ 00858337។ ខ្ញុំសូមដកស្រង់៖ “នួន ជា មិនបានបដិសេធថា សមាជិកបក្សទាំងនេះ ត្រូវបានសម្លាប់នៅក្នុងការបោសសម្អាតក្រោមបញ្ជារបស់ថ្នាក់ដឹកនាំឡើយ ហើយបានបញ្ជាក់ទៀតថា សមាជិកបក្សទាំងនោះ គឺជាជនក្បត់ដែលត្រូវតែសម្លាប់ចោល។” តាមពិត ខ្ញុំសូមដកស្រង់៖ “អ្នកដឹកនាំមួយចំនួនធំនៅមជ្ឈិមបក្សគឺជាអាយ៉ងនៃ<ខ្មែរយៈវៀតណាម>”។ បញ្ចប់ការដកស្រង់។ ហើយនៅទំព័រ១០៥ ភាសាអង់គ្លេស, បារាំងមានលេខ 00849435 ដល់ 36, ខ្មែរមានលេខ <00858340>។ ខ្ញុំសូមដកស្រង់៖ “នួន ជា បាននិយាយថា <គាត់មិនមានការរំខានចិត្ត ជាពិសេសចំពោះ>ការ<>សម្លាប់សមមិត្ត និងមិត្តភក្ដិពីមុនរបស់គាត់នោះ<ឡើយ>។ បក្សបានសម្រេចសម្លាប់<ពួកគេ>ទាំង<នោះ> ព្រោះពួកគេក្បត់បក្ស និងជាតិ។ ខ្ញុំមិនរន្ធត់ ឬក៏ពិបាកចិត្តឡើយនៅពេលដឹងពីការសម្លាប់ពួកគេ។ ពួកគេមានកំហុស ហើយក្បត់ពួកយើង ដូច្នេះពួកគេត្រូវតែទទួលទោសតាមទង្វើររបស់ពួកគេ។ ថ្វីបើពួកយើងគឺជាមិត្តភក្ដិនឹងគ្នាក្ដី ប៉ុន្តែមិត្តភក្ដិ និងការងារនយោបាយត្រូវញែកឲ្យដាច់ពីគ្នា។” បញ្ចប់ការដកស្រង់សម្ដីរបស់ នួន ជា។ “នួន ជា <បន្តពន្យល់ថា វាជាការ> លំបាកនៅក្នុងការជីកឫសគល់របស់ខ្មាំង ដែលបង្កប់នៅក្នុងមេដឹកនាំខ្មែរក្រហម។ សូមបញ្ចប់ការដកស្រង់។

[១១:៣៣:១១]

បាទ ខ្ញុំមានសំណួរពីរ ហើយក្រោយមក ខ្ញុំឈប់ត្រឹមហ្នឹង។ នួន ជា គាត់ថា គាត់បានអានចម្លើយសារភាពរបស់អ្នកដឹកនាំ ដូចជា វន វ៉េត, កុយ ធួន, រស់ ញឹម អីជាដើម។ គាត់និយាយថា ចម្លើយសារភាពរបស់អ្នកទាំងអស់នេះវាច្បាស់ណាស់។ អ៊ីចឹង ខ្ញុំសួរលោកថា ហេតុអ្វីបានជាអ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យជឿលើខ្លឹមសារនៃចម្លើយសារភាពរបស់អ្នកទោស?

**កញ្ញា លី និមលៈ**

លោកតាសំណួរថា ហេតុអីក៏មេដឹកនាំជឿទៅលើចម្លើយឆ្លើយសារភាពរបស់អ្នកទោស? លោកតាយល់សំណួរទេ?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**2-TCW-920៖**

**ឆ៖** អានេះវានៅលើ គេសង្កត់គេ ធ្វើបាបគ្នាទៅ ម្ល៉ោះហើយត្រូវតែគ្នាឆ្លើយទៅ។ ខ្ញុំមិនជឿគាត់ក្បត់ទៅទេ អាហ្នឹងគឺគ្នាឯង សង្កត់គ្នាឯង។ ដូចជានិរតីសង្កត់ពាយ័ព្យអីចឹង ពួកពាយ័ព្យក្បត់ ចូលដៃចូលនេះនោះទៅ និរតីគេល្អ គេមក គេគ្រប់គ្រងពីលើ។ អីចឹងអាគ្នាឯង សង្កត់គ្នាឯងហ្នឹងណា។ ខ្មែរលេងគ្នាឯង។ ខ្លួនខ្ញុំក៏គេចោទថាក្បត់ដែរ ដកខ្ញុំនៅ មកតែនៅស្ទឹងហ្នឹង គេតាមដានមើលយើង។ ដល់គេតាមដានទៅយើង*(ឮមិនច្បាស់)*។

**ស៖** បាទ សូមអរគុណលោកសាក្សី។ សំណួរចុងក្រោយ នួន ជា បាននិយាយថា អ្នកដឹកនាំទាំងអស់ហ្នឹងវាសមនឹងទទួលការប្រព្រឹត្តបែបនោះហើយ។ តើ រស់ ញឹម ដែលលោកស្គាល់តាំងពីទសវត្សរ៍ឆ្នាំ៦០មកនោះ ហើយ<ទល់គ្នានឹង>របបកម្ពុជាប្រជាធិបតេយ្យហ្នឹង <បើតាមការយល់ឃើញរបស់លោក>តើអ្វីដែលគេប្រព្រឹត្តទៅលើ រស់ ញឹម ហ្នឹងវា<ស័ក្តិសមដែរឬទេ>?

**កញ្ញា លី និមល៖**

លោកតាគិតថា វាសមរម្យទេ នៅពេលដែលគេប្រព្រឹត្តទៅលើ រស់ ញឹម អ្វីដែលគេធ្វើមកលើ រស់ ញឹម ហ្នឹង លោកតាគិតថាសមរម្យអត់?

**2-TCW-920៖**

**ឆ៖** អាហ្នឹងមកពី វាចូលបក្សពួកដូចខ្ញុំថាអីចឹង អាពួកនីរតីមកគ្រប់គ្រងលើអាពាយ័ព្យ ចោទអាពាយ័ព្យក្បត់អីចឹងទៅ ថាចូលដៃយួនទៅស្អីណាទៅណា។ អាហ្នឹងខ្មែរយើងអីចឹងណា។ ម្ល៉ោះហើយខាងនិរតី ចាប់ពាយ័ព្យ បោសសម្អាតពាយ័ព្យ ដូចជា រស់ ញឹម អីនេះគាត់ពាយ័ព្យ។ ដល់និរតីមកក្រោយហ្នឹង ពួកតាម៉ុក ពួកស្អី ក្រោយគេហ្នឹង វាទៅជាល្អ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណលោកប្រធាន ហើយ។

សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសាក្សី។ អរគុណដែរ និមល។ ឥឡូវដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ។ ចាំៗបន្តិច! ប្រហែលជាអត់មានសំណួរទេតាមមើលភាគីមេធាវីការពារក្តី។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ពិតហើយលោកប្រធាន ហ្នឹងហើយជាមូលហេតុដែលខ្ញុំងើបឈរឡើង ព្រោះថា ខ្ញុំមិនមានសំណួរអ្វីទេ ហើយខ្ញុំគិតថា ខាងមេធាវី ខៀវ សំផន ក៏ប្រហែលជា<មិន>មាន<សំណួរដល់រូបគាត់>ដែរមើលទៅ។ <បើអ៊ីចឹងយើងអាចឲ្យគាត់សម្រាកបានហើយ>។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានក្រុម មេធាវី ខៀវ សំផន ហ្នឹង ក៏អត់មានសំណួរដែរលោកប្រធាន។

[១១:៣៧:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយព័ត៌មានដ៏ល្អនេះ ហើយអង្គជំនុំជម្រះអរគុណលោកសាក្សី សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនាពេលនេះដល់ពេលដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ លោកនាពេលនេះ លោកអាចសម្រាកបានហើយលោកសាក្សី។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ ហើយបានសេចក្តីសុខសេចក្តីចម្រើន។

ហើយអង្គជំនុំជម្រះក៏សូមអរគុណដែរ លោក ម៉ម រិទ្ធា មេធាវីប្រឹក្សាសាក្សី លោកអាចសម្រាកបានហើយ។ ហើយអរគុណចំពោះកញ្ញា លី និមល បុគ្គលិកអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ និងបុគ្គលទាំងឡាយដែលបានគាំទ្រការរៀបចំប្រព័ន្ធសោតទស្សន៍ និងសម្របសម្រួលដល់កិច្ចដំណើរការសវនាការ ស្តាប់សក្ខីកម្មសាក្សីនេះ ប្រព្រឹត្តទៅបានល្អរហូតដល់ចប់។ ឥឡូវនេះ អាចសម្រាកបានហើយ។

ហើយនៅរសៀលនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សវនាការស្តាប់សក្ខីកម្មសាក្សី នួន ត្រិច ដែលយើងនាំកោះគាត់មកបម្រុងនៅថ្ងៃនេះ។ ហើយឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ តទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅ

រសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣៤ នាទី)*

[១៣:៣៤:១១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ យើងស្ដាប់សវនាការស្ដាប់សក្ខីកម្មសាក្សី នួន ត្រិច។ ហើយអង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅមេធាវីការពារក្ដីលោក នួន ជា ដើម្បីបន្តសួរដេញដោលចំពោះសាក្សី នួន ត្រិច ហើយមេធាវីការពារក្ដីទាំងពីរក្រុមមានពេលវេលាមួយវគ្គនៃថ្ងៃសវនាការក្នុងសួរដេញដោលសាក្សីរូបនេះ។ ម្សិលមិញបានមួយវគ្គហើយនៅសល់មួយវគ្គទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំសូមបន្តទៅលើការសួរសំណួរដែលខ្ញុំបានសួរកាលពីម្សិលមិញ។ ម្សិលមិញនៅពេលរសៀលមុនពេលដែលយើងសម្រាក លោកនិយាយអំពីមន្ទីរឃុំឃាំងដែលលោកបានបញ្ជាក់ថា ជាគុកទួលស្លែងនោះ។ ខ្ញុំចង់សួរលោកបន្ថែមទៀតទាក់ទងទៅនឹងការជាប់ឃុំនៅទីនោះ។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា E3/7537 អង់គ្លេសមានលេខ 00251254, បារាំងមានលេខ 00291004, ខ្មែរមានលេខ 00019647។ លោកបាននិយាយថា៖ “មុនពេលដែលគេយកមកគុកនេះ គឺគេប្រាប់ -- គឺគេកុហកលោកថា គេយកទៅពេទ្យអន្តរជាតិ”។ ថាតើអ្នកណាជាអ្នកប្រាប់លោកថា គេយកលោក<>ទៅពេទ្យអន្តរជាតិនោះ?

**លោក នួន ត្រិច៖**

**ឆ៖** ពេលនុំងអ្នកកន្លែង--

**ប្រធានអង្គជំនុំ៖**

កុំអាលៗទាន់ឆ្លើយតប! អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

[១៣:៣៦:៣៤]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះមតិដំបូងដែលនាំទៅដល់ការសួរសំណួរនេះ <ដែលសាក្សីថាគាត់ជាប់នៅ> "គុកទួលស្លែង"។ ផ្អែកទៅលើ<ការយល់ឃើញរបស់គាត់កាលពីម្សិលមិញលើកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា> គឺ<គាត់បានបញ្ជាក់ច្បាស់ហើយ>ថាមិនមែន<ជាប់>នៅទួលស្លែងទេ ប៉ុន្តែអ្នកដែលយកមកមន្ទីរហ្នឹងគឺក្រោយមកទៀតត្រូវបានគេយកទៅទួលស្លែង។ ហើយសូម្បីកំណត់ហេតុជាមួយ ក.ស.ច.ស ក៏គាត់បាននិយាយដូច្នេះដែរ។ ខ្ញុំគិតថាមេធាវីមិនគួរនាំមុខសាក្សីបែបនេះឡើយ ដោយនិយាយថាសាក្សីនេះទៅ<ជាប់នៅ>ទួលស្លែង ព្រោះសាក្សីក៏មិនបាននិយាយដែរ។ គួរតែសួរថា តើមន្ទីរឃុំឃាំងហ្នឹងគឺកន្លែងណា ឬក៏ទីណាមួយសិន?

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែអាន<សេចក្តីព្រាង>ប្រតិចារឹកកាលពីម្សិលមិញតែប៉ុណ្ណោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើដូច្នេះសូមលោកផ្តល់លេខឯកសារយោងដើម្បីឱ្យយើងមានភាពងាយស្រួលទាំងអស់គ្នា។

**លោក វិចទ័រ កូប៉េ៖**

កាលពីម្សិលមិញ ខ្ញុំបានសួរគាត់ថា តើមន្ទីរឃុំឃាំងណាមួយ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលោកផ្តល់នៅក្នុងសេចក្តីព្រាងប្រតិចារឹកមកតែម្តងមក។

**លោក វិចទ័រ កូប៉េ៖**

គឺនៅចុងបញ្ចប់។ <នៅចុងបញ្ចប់ នៅម៉ោង ១៦:០០ កាលពីម្សិលមិញ។ ខ្ញុំបានសួរគាត់>

[១៣:៣៨:១២]

<ព្រោះឃើញថានៅ>កំណត់ហេតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់បានឆ្លើយពីរដង ថាវាជាមន្ទីរឃុំឃាំងទួលស្លែង។ គឺនៅទំព័រដដែលដូចដែលខ្ញុំបាននិយាយយោង។ ហើយម្សិលមិញខ្ញុំសួរគាត់ថា ហេតុអីបានគាត់ដឹងថាជាការិយាល័យគុកទួលស្លែង គាត់បានថា កាលពីម្សិលមិញគឺថា រួម

ជាមួយចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់ថាដោយសារតែគាត់ឆ្លើយ ហើយនិងអ្វីដែលមាននៅក្នុងឯកសារហ្នឹង ទើបខ្ញុំយល់ឃើញថាសាក្សីគាត់ជាប់នៅការិយាល័យគុកទួលស្លែង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថាទុកឲ្យអង្គជំនុំជម្រះជាអ្នកសម្រេច គ្រាន់តែខ្ញុំយកផ្អែកទៅលើសក្ខីកម្មរបស់គាត់ថា គាត់<ជាប់នៅមន្ទីរគុកទួលស្លែង ២ ឬ៣ថ្ងៃ និងត្រូវគេសួរចម្លើយ និងថតរូបផង>។

[១៣:៣៩:១១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះ ខ្ញុំសូមសួរទៅលោកសាក្សីវិញថា តើលោកត្រូវបានគេឃុំខ្លួននៅការិយាល័យគុក ស-២១ មែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺគួរតែប្រើពាក្យថា "គុកទួលស្លែង"។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមទោស គឺខ្ញុំចង់សួរពីគុកទួលស្លែងនោះឯង។

**លោក នួន ត្រិច៖**

ពេលនុំងគេនាំខ្ញុំទៅហ្នឹង ទៅដាក់កន្លែងហ្នឹង ព្រោះអ្នកដែលទៅទាំងប៉ុន្មានកន្លែងនុំង គឺចូលគុកហ្នឹងសិនបានគេនាំទៅកន្លែងគុកទួលស្លែង។ ខ្ញុំទៅហ្នឹងក៏មិនបានថា កន្លែងគុកទួលស្លែងដែរ ទាល់មានមិត្តខ្ញុំធ្លាប់ស្គាល់គ្នាហ្នឹង គេថាមិត្តឯងមកកន្លែងហ្នឹង សុទ្ធតែជាប់គុក ហើយ។ អ៊ីចឹងបានខ្ញុំភ្ញាក់ដូច អ៊ូ! ខ្ញុំជាប់គុកហើយអ៊ីចឹង។ រួចទៅបានដឹងដល់មេខ្ញុំ មេខ្ញុំហ្នឹង គេមកដោះខ្ញុំថា ឈ្មោះ យៀត ហ្នឹង គេថាមិត្តហ្នឹង មិនទាន់មានពាក់ព័ន្ធទោសត្រូវជាប់គុកទេ យកគាត់ទៅកសាងសិន ហើយក៏គេអនុគ្រោះឲ្យខ្ញុំយក ឲ្យមកកសាងខ្លួន។ ថាបើកសាងខ្លួនមិនបាន នឹងត្រូវជាប់គុកហើយ។ បាទ ប៉ុណ្ណឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អ៊ីចឹង ខ្ញុំត្រូវត្រឡប់ទៅសំណួរដំបូងរបស់ខ្ញុំវិញហើយ លោកសាក្សី។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងទំព័រដែលខ្ញុំបាននិយាយយោងរួចទៅហើយនេះ គឺថាមុនពេលដែលគេយកទៅការិយាល័យគុក គឺគេថា "គេចាប់ទៅ គេភរខ្ញុំថា គេ<យក>ខ្ញុំទៅពេទ្យ<អន្តរជាតិមួយ>។ <>រួចខ្ញុំក៏អត់ដឹងថាកន្លែងហ្នឹងជាកន្លែងការិយាល័យគុកទួលស្លែងហ្នឹងដែរ។ ខ្ញុំស្មានថាការិយាល័យមន្ទីរពេទ្យអន្តរជាតិ។" ដូច្នេះ ខ្ញុំចង់សួរថា តើអ្នកណាដែលប្រាប់លោកថា លោក

01390867



ត្រូវទៅពេទ្យប្រចាំអន្តរជាតិនោះ?

[១៣:៤១:២៣]

**ឆ៖** ឈ្មោះ បងស្រឡៅ។ តែដល់នេះទៅ ខ្ញុំមកកន្លែងហ្នឹង ក៏គេចាប់ បងស្រឡៅ។ ខ្ញុំមកកន្លែងការិយាល័យគុកហ្នឹង ក៏គេចាប់បង ស្រឡៅ ហ្នឹង ទៅពីក្រោយខ្ញុំបាត់ទៅ បាទ។

**ស៖** នៅទំព័រដដែលនោះ គឺលោកនិយាយអំពីមនុស្សម្នាក់ដែលប្រាប់លោកថា លោកនៅក្នុងការិយាល័យគុក ហើយលោកបានប្រាប់ថា ម្នាក់នេះឈ្មោះ <យៀត>។ លោកបាននិយាយថា <“យៀត> ជាអនុប្រធានមន្ទីរពេទ្យដែលខ្ញុំធ្វើការជាមួយហ្នឹង <ដោយគាត់មិនឃើញខ្ញុំនៅកន្លែងធ្វើការគាត់ក៏បានសួរគេអំពីខ្ញុំ។ គេប្រាប់គាត់ថាខ្ញុំត្រូវគេយកមកទីនេះ នៅមន្ទីរគុក អ្នកប្រាប់ហ្នឹងឈ្មោះអុល”>។ អ៊ីចឹង ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីឈ្មោះ យៀត។ តើលោក<>ថា យៀត <ជាអនុប្រធានមន្ទីរពេទ្យ តើលោកច្បាស់ទេ ឬក៏លោកចង់សំដៅទៅ យៀត>ដែលជាប្រធានផ្នែកភស្តុភារនៅ<វរសេនាតូច>៣១៤ នោះមែនទេ?

**ឆ៖** យៀត ហ្នឹងគឺប្រធានភស្តុភារវរៈ ភស្តុភារវរៈ៣១៤។ គាត់ជាប្រធានរបស់ខ្ញុំ ហើយខ្ញុំនៅធ្វើការនៅកន្លែងហ្នឹងជាពេទ្យ។ ហើយដល់បាត់ខ្ញុំ គាត់ក៏សួរបង ស្រឡៅ។ ស្រឡៅ ហ្នឹង ត្រូវជាអនុរបស់ ត្រូវជាប្រធានខាងរងភស្តុភារហ្នឹង។ សួរថា “ស្រឡៅ មិត្តស្រឡៅ មិត្តភក្តិហ្នឹងទៅណាបាត់ហើយ បានអត់ឃើញដើរ ឃើញមកចាក់ថ្នាំចាក់អី។” ហើយបង ស្រឡៅ ថា គេមកយកឡានដឹកទៅបាត់ហើយ ទៅកន្លែង បងអុល។ អុល ហ្នឹង -- បាន យៀត ហ្នឹងភ្ញាក់រូបថា អូ៎! កន្លែងហ្នឹងកន្លែងការិយាល័យគុក បាទ។

[១៣:៤៤:១២]

**ស៖** តើ យៀត គាត់មានសិទ្ធិអំណាចអ្វីនៅក្នុងការិយាល័យគុកហ្នឹង ឬក៏គាត់គ្រាន់តែមកប្រាប់លោកទេ។ ខ្ញុំចង់សួរថាហេតុអ្វីបានជាប្រធានភស្តុភារ<វរសេនាតូច>៣១៤ហ្នឹង មកជួបលោកនៅទីនោះ?

**ឆ៖** គាត់មកជួបហ្នឹង គាត់មកជួប បងអុល ហ្នឹងជាប្រធានហ្នឹង គាត់ថាគាត់នឹងសុំខ្ញុំយកទៅកសាងវិញ ព្រោះខ្ញុំមិនដែលឃើញធ្វើខុសអីទេ អ៊ីចឹងយកទៅកសាងសិន បើថាកសាងមិនបាន ចាំធ្វើតាមហ្នឹង តាមដំណើរហ្នឹងទៅ បាទ។

**ស៖** តើ អុល ហ្នឹងជានរណា? ខ្ញុំគិតថាសាក្សីគាត់ឆ្លើយអ្វី ប៉ុន្តែខ្ញុំស្តាប់អត់ឮ ដោយសារមីក្រូ-

ហ្វូនអត់ទាន់បើក។

ឆ៖ អ៊ុល ហ្នឹង ប្រធានការិយាល័យគុក បាទ ខាងបញ្ជូនទៅគុកទួលស្លែង បាទ។

ស៖ តើលោកដឹងដោយរបៀបណាដែរ?

ឆ៖ ដឹងហ្នឹង ដឹងដោយសារពេល បងយៀត ហ្នឹង គាត់មកជួបនឹង អ៊ុល ហ្នឹង ណែនាំសុំគេហ្នឹង ហើយខ្ញុំនៅក្បែរហ្នឹង គេថាយកខ្ញុំទៅកសាងសិន បានទើបខ្ញុំដឹងថា អូ! ខ្ញុំមានកំហុសអីមួយ បានគេយកមកនុ៎ង បាទ។

ស៖ តើលោកស្គាល់ អ៊ុល មុនពេលដែលលោកជួបគាត់នៅការិយាល័យគុកហ្នឹងដែរឬទេ?

ឆ៖ មកហ្នឹង ខ្ញុំឃើញមុខគាត់ តែខ្ញុំអត់ស្គាល់ អ៊ុល ហ្នឹងទេ ទាល់តែ បងយៀត ក៏គាត់និយាយពិភាក្សាជាមួយទៅ ឡប់មកវិញ បានគាត់និយាយប្រាប់ថា អ៊ុល ហ្នឹងហើយ ជាអ្នកទទួលយកអ្នកទោសទៅដាក់គុកទួលស្លែងអីហ្នឹង បាទ។

[១៣:៤៦:៤៧]

ស៖ តើ អ៊ុល ជាសមាជិករបស់កងពល៣១០ ដែរឬទេ?

ឆ៖ គាត់ដូចជាមិនសមាជិកទេ គាត់អ្នកខាងទទួល ខាងចាប់ចងដាក់គុក ដាក់ច្រវាក់ហ្នឹង អ្នកបញ្ជូនទៅ បាទ។

ស៖ មានសំណួរមួយចំនួនទៀត ដែលខ្ញុំចង់សួរ ទាក់ទងការិយាល័យគុកដដែលនេះ។ តើលោកអាចរៀបរាប់អំពីបរិវេណខាងក្នុងរបស់ការិយាល័យគុកនោះបានទេ?

ឆ៖ ក្នុងការិយាល័យនុ៎ង ទៅនុ៎ង ឃើញមានគេយាមទៅ មានខ្មោះ មានអី សន្តិសុខ គេនៅយាមកន្លែងហ្នឹង ហើយចូលទៅហ្នឹង គេមិនឲ្យយើងដើរទៅណាទេ នៅក្នុងបន្ទប់ បាទ ព្រោះគេថាយើងជាអ្នកទោសហើយ គេអត់ឲ្យយើងដើរទេ បាទ។

ស៖ តើលោកមានបាន<ឃើញ>អ្នកទោសផ្សេងទៀតដែរឬទេ ឬមួយក៏លោកឃើញតែយុទ្ធជនមកពីកងពល៣១០ នោះទេ <ឬតើលោកចាំបានទេថា លោកបានឃើញនរណាខ្លះនៅក្នុងមន្ទីរនោះ>?

ឆ៖ នៅកងពលជាមួយគ្នាហ្នឹង គេបញ្ជូនទៅកន្លែងហ្នឹង គេចាប់បណ្ដើរៗនៅវរៈជាមួយខ្ញុំ ដូចជា មិត្តសេង ហើយនិង មិត្តផាន សុទ្ធនៅជាមួយខ្ញុំនុ៎ង បញ្ជូនទៅកន្លែងហ្នឹង សុទ្ធតែគេយកទៅបាត់ទាំងអស់គ្នា បាទ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** តើលោកអាចប្រាប់បានទេថា លោកថតរូបនៅត្រង់កន្លែងណា នៅក្នុងគុកហ្នឹង? <ឧទាហរណ៍ តើ>ម៉ាស៊ីនថតគេថតលោកនៅត្រង់កន្លែងណាដែរ?

**ឆ៖** ថតនុ៎ង មិនទាន់ទៅថតដល់កន្លែងក្នុងគុកទួលស្លែងទេ គេថតនៅកន្លែងការិយាល័យនុ៎ង។ ថត គេថា ថតដើម្បីទុកក្រែងធ្វើការដាក់ក្នុងប្រវត្តិរូប បាទ។ ហើយខ្ញុំៗ ក៏អត់ដឹងដែរ ព្រោះជំនាន់នុ៎ង ធ្វើការកូនចៅគេ អត់ដឹងដែរ ព្រោះគេថាថត ឲ្យថតហើយ បាទ។

[១៣:៤៩:៤៥]

**ស៖** តើលោកដឹងថា អ្នកដែលគ្រប់គ្រងទៅលើគុកហ្នឹង <ជាមនុស្សមកពី>កងពល៧០៣មែនទេ?

**ឆ៖** អ្នកគ្រប់គ្រងគុកហ្នឹង ច្រើនអ្នកមកពីខាងកងពលនិរតី។ កងពួក៥០២ កងពល៥០២។

**ស៖** តើគេហៅកន្លែងនុ៎ងថា ស-២២ ដែរទេ?

**ឆ៖** ខ្ញុំមិនបានដឹងថា ស មិន ស-២២ ដែរទេ ព្រោះឃើញតែចាប់យកទៅកន្លែងនុ៎ង ខ្ញុំវាមិនដែលប៉ានចូលទៅទេ ព្រោះដឹងថាយកទៅកន្លែងហ្នឹង សុទ្ធតែបាត់ខ្លួនហើយ។

**ស៖** លោកប្រធាន ខ្ញុំនឹងលើកយកឯកសារ E3/5263 គឺជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីមួយរូបឈ្មោះ ស្រេង ធី ដែលនិយាយអំពីគុករបស់កងពល៥០២។ គឺខ្ញុំនិយាយទៅលើ អង់គ្លេស 00282225, បារាំងមានលេខ 00283350, សូមទោសផង ដែលខ្ញុំមិនមានលេខ ERN ជាភាសាខ្មែរ។ លោកសាក្សី ខ្ញុំសួរលោក ដោយសារតែលោកមិនអាចមើលក្រៅបង្អួច នៅពេលដែលគេយកទៅនោះ។ គឺថាដោយសារតែនៅក្នុងកំណត់ហេតុជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា គឺគេយកលោកទៅ២-៣គីឡូម៉ែត្រ។ ប៉ុន្តែសាក្សីរូបនេះ គាត់និយាយអំពីទីតាំងមួយ ដែលហៅថា ស-២២ នៅខាងលិចសាលាទឹកល្អក់។ តើលោកស្គាល់ ឬក៏លោកអាចនឹកឃើញអំពីកន្លែងនេះបានទេ គឺនៅខាងលិចសាលាទឹកល្អក់?

[១៣:៥៣:១១]

**ឆ៖** មិនបាននឹកឃើញដែរទេបាទ ព្រោះជំនាន់នុ៎ង ខ្ញុំវានៅមកដល់ឥឡូវហ្នឹង វា៤៧ឆ្នាំហើយ ភ្លេចភ្លាំងខ្លះហើយ ព្រោះកាលពីនៅនុ៎ងក្មេង ដល់ឥឡូវវាងចាស់ហើយ ចូលភ្លេចមុខភ្លេចក្រោយបាទ។

**ស៖** មិនអីទេលោកសាក្សី។ ឥឡូវនេះខ្ញុំសូមបន្តទៅមុខទៀត។ បន្ទាប់ពីចេញពីការិយាល័យគុក <>គេបញ្ជូនលោកទៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ ខ្ញុំនឹងសួរលោកនៅពេលបន្តិចទៀតនេះ

ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរថា ក្រោយពេលដែលលោកចេញពីព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង តើលោកទៅធ្វើអ្វីបន្តទៀត?

**ឆ៖** គេដកខ្ញុំឲ្យទៅកសាងខ្លួន គេថាខ្ញុំខ្សែក្បត់ គេចាប់ភូមិភាគឧត្តរ។ គេថានៅកងពល៣១០ហ្នឹង សុទ្ធតែអ្នកក្បត់ហើយ អ៊ីចឹងគេយកទៅឲ្យកងសាងខ្លួន គេចាប់ បងយឿត បងអ៊ីហ្នឹងទៀត ក៏ខ្ញុំគេត្រូវបញ្ជូនទៅកសាងខ្លួនលត់ដំនៅខេត្តកំពង់ឆ្នាំង ឲ្យជីកព្រលានយន្តហោះ ដុតធ្យូនភ្នំ ធ្វើព្រលានយន្តហោះ។ ធ្វើការទាំងយប់ទាំងថ្ងៃ ធ្វើពីម៉ោងប្រាំមួយទល់ម៉ោង គិតទៅពីម៉ោងបួនជិតភ្លឺ រហូតដល់ម៉ោងពីរដណ្តប់ ម៉ោងមួយចុះធ្វើការទៀត។ ហើយដល់ក្រោយមកត្រូវវៀតណាមចូលវ៉ៃឆ្នាំ៧៩នេះ គេៗថាពួកមិត្តទាំងប៉ុន្មានដែលត្រូវមានទោសកសាងខ្លួនហ្នឹង ក៏សាងខ្លួនបានល្អហើយ ត្រូវមកទៅតស៊ូប្រឆាំងជាមួយវៀតណាមវិញ។ ហើយខ្ញុំក៏កសាង ហើយឲ្យទៅណាទៀតអ៊ីចេះ? ហើយខ្ញុំក៏គេបញ្ជូនដក គិតទៅនៅកំពង់ឆ្នាំងនុ៎ងជាប់៣ខែកសាងខ្លួនហ្នឹង លត់ដំ។ ហើយក៏គេថា ឲ្យដកទៅធ្វើសង្គ្រាមជាមួយវៀតណាម។ គេថា មិត្តៗសុទ្ធតែមានជីវៈធ្លាប់វ៉ៃទីក្រុងភ្នំពេញ បាទ។ ហើយក៏យកមកបញ្ជូនមកពីកំពង់ឆ្នាំងមកដាក់នៅនឹងយើងតាខ្មៅ។ គេបំពាក់កាំភ្លើង ជិះអាម៉ារីនទៅចុះ ទៅខាងទន្លេបិទ ឡើងទៅវ៉ៃជាមួយវៀតណាម។ តែខ្ញុំគេអត់ឲ្យវ៉ៃទេ គេខ្ញុំពេទ្យដដែល។ គេថា ចេះពេទ្យឲ្យធ្វើពេទ្យសម្រាប់រុំ តាមទាហានយោធា ដើម្បីរុំរបួស បាទ។

[១៣:៥៦:៣១]

**ស៖** នៅពេលដែលគេបញ្ជូនលោកទៅព្រំដែនដើម្បីវាយប្រយុទ្ធជាមួយវៀតណាម ថាតើលោកនៅក្នុងកងអ្វី? តើលោកនៅក្នុងកងលេខ៤មែនទេ?

**ឆ៖** មិនដឹងកងប៉ុន្មានដែរ ព្រោះទៅហ្នឹង គេបញ្ជូនទៅហ្នឹង គេឲ្យធ្វើពេទ្យតាមយោធាហ្នឹង។ ពេលនុ៎ងកំពុងតែទៅហ្នឹង គេបញ្ជូនទៅ ក៏ក្តាប់អត់បានថាកងប៉ុន្មានដែរ។ ហើយក៏ខ្ញុំឡើងទៅគេវ៉ៃគ្នានៅត្រពាំងផ្លុង ហើយនិងច្រករំដេង ហើយខ្ញុំនៅត្រពាំងព្រីង ក៏ត្រូវគ្រាប់ផ្លោងពីវៀតណាម ១០៥ ត្រូវពេញខ្លួន ក៏គេបញ្ជូនយកមកដេកពេទ្យនៅវត្តទទឹម វត្តជិតស្ទួង គេហៅវត្ត ខ្ញុំភ្លេចវត្តហ្នឹងទៅ។ ក៏គេថា ជំងឺរបួសហ្នឹងខ្លាំងណាស់ ក៏គេបញ្ជូនមកភ្នំពេញ មកវិញ បាទ។

**ស៖** នៅក្នុងកំណត់មជ្ឈមណ្ឌលឯកសារកម្ពុជា E3/7537 អង់គ្លេសមានលេខ 00251258, បារាំងមានលេខ 00291009, ខ្មែរមានលេខ 00019651 គឺលោកបាននិយាយដូចតទៅនេះ៖ “ខ្ញុំត្រូវបានគេផ្លាស់ ដោយសារតែយើងមកពី<>ភូមិភាគកណ្តាល ទើបគេបញ្ជូនខ្ញុំទៅ<វ៉ៃនៅ>ស្ទួង នៅក្នុង

ស្រុកមេមត់"។ ហើយក្រោមបន្តិច លោកនិយាយ<ថា>កង<>លេខ៤។ ខ្ញុំមិនមែនបង្កើតដោយខ្លួនឯងទេ គឺជាចម្លើយរបស់លោក។ ចុះមកបន្តិចទៀត លោកឆ្លើយថា៖ "ខ្ញុំត្រូវបានគេផ្ទេរទៅ<>ស្នួង មកខាងជាំព្រីង"។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គេផ្ទេរមកហ្នឹង គឺគេដាក់ព្រលានយន្តហោះហ្នឹងមក មកខាងយោធាឲ្យធ្វើពេទ្យនៅខាងចាំរុំរបួសនៅខាងស្រុកមេមត់ហ្នឹង តាមយោធាហ្នឹង តែខ្ញុំមិនបានចាប់ភ្លឹកថា មិនដឹងកងពលណា និងឬក៏វរៈណា ព្រោះទៅហ្នឹង គឺគេបញ្ជូនដល់បង្ខំ បាទ។

[១៣:៥៩:៣១]

**ស៖** តើលោកចង់មានន័យយ៉ាងម៉េចដែរ នៅពេលដែលលោកថា គេផ្លាស់លោកដោយបង្ខំនោះ?

**ឆ៖** គេដោយឃើញមានវៀតណាមហ្នឹង វ៉ៃសម្រុកចូលខ្លាំង គេក៏ដកពួកដែលជាប់ គេថាអ្នកជនក្បត់ទាំងប៉ុន្មាននៅព្រលានយន្តហោះហ្នឹង ឲ្យមកទប់ទល់នៅ។ អ៊ីចឹងបានខ្ញុំទៅហ្នឹងក៏មិនបានឡើងវ៉ៃនឹងគេដែរ។ បានគេត្រូវរបួស គេសែងមកដល់កន្លែងខ្ញុំ ខ្ញុំក៏រុំរបួស ហើយក៏ត្រូវគ្រាប់ផ្លោងអាអ្នកដែលខ្ញុំរុំនុ៎ង ក៏ស្លាប់ទៅ ខ្ញុំក៏ត្រឹមរបួសខ្លាំងបាទ។

**ស៖** សូមអរគុណដែលលោកបញ្ជាក់ ប៉ុន្តែខ្ញុំមិនយល់ ពេលដែល<>លោកនិយាយថា "បង្ខំ" ហ្នឹង គឺលោកនៅកងវរ<សេនាតូច>៣១៤ <ចំណុះឲ្យកងពល៣១០> ចាប់ពីថ្ងៃ១៧ មេសា ៧៥ រហូតដល់ចុងបញ្ចប់។ ប្រសិនបើលោកជា<យោធា> លោកទទួលបញ្ជាពីមេរបស់លោក គឺលោកត្រូវចាំបាច់ត្រូវតែគោរពបញ្ជា។ អ៊ីចឹងមែនទេ ព្រោះថា ដោយសារតែមានសង្គ្រាម<ច្បាំងជាមួយវៀត-ណាម> ទើបលោកចាំបាច់ត្រូវតែគោរពបញ្ជា ដូច្នេះ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាលោកប្រើពាក្យ "បង្ខំ"ទៅវិញ?

**ឆ៖** គេថា បើយើងមិនទៅ ត្រូវវៀតណាមចូលទឹកដីកម្ពុជាយើងហើយ។ ហើយអ៊ីចឹង យើងទាំងប៉ុន្មានហ្នឹង មិនរស់ទេ។ យើងជានេះ ច្បាស់ជាវៀតណាមចូលអារកនឹងធាងត្នោតហើយ អ៊ីចឹង យើងជាធ្លាប់នៅទ័ព យើងត្រូវតែទៅ ធ្លាប់វ៉ៃភ្នំពេញ ធ្លាប់អីហ្នឹង ឥឡូវត្រូវតែទៅទប់ទល់នឹងជាមួយនឹងវៀតណាមវិញ តែទ័ពខាងកងពល៣១០ កងពលលេខ៤ ហ្នឹងវាទៅខាងនុ៎ង តែខ្ញុំមិនដឹងថា នៅកងពលខ្លួនឯងក៏មិនដឹង ព្រោះទៅ ពេលទៅនុ៎ង វាអត់ជួបគ្នាឯង។

[១៤:០១:៤៧]

**ស៖** ខ្ញុំយល់ ប៉ុន្តែឥឡូវនេះខ្ញុំចង់សួរលោកអ៊ីចេះវិញ តើត្រឹមត្រូវទេ នៅថ្ងៃរំដោះភ្នំពេញ ១៧ មេសា ៧៥ រហូតដល់ពេលដែលវៀតណាមចូលមកគ្រប់គ្រងប្រទេសកម្ពុជាថ្ងៃ ០៧មករា ៧៩ នោះ គឺលោក<>ជាទាហានក្នុងកងពល៣១០រហូត តើអ៊ីចឹងមែនទេ?

**ឆ៖** ពេលនុ៎ង ខ្ញុំរបួសៗមកដេកពេទ្យហើយ គឺដូចជា ដាច់ពីកងពលហើយ មិនដឹងនៅកងពលណាទេ ព្រោះនៅដេកពេទ្យយូរដែរហើយ មកដេកពេទ្យភ្នំពេញជាប់២ខែបាទ។

**ស៖** បាទ ខ្ញុំសូមសួរលោកឲ្យបានច្បាស់លាស់ នៅពេលដែលលោកនៅព្រលានយន្តហោះកំពង់ឆ្នាំង មុនពេលលោកទៅស្លូង តើលោកជា<យោធាម្នាក់>ចំណុះឲ្យកងពល៣១០ មែនទេ?

**ឆ៖** ពេលនុ៎ង ទៅហ្នឹង គេអត់ឮប្រាប់ថាទៅចំណុះកងពល៣១០ មិនដឹងដែរ ព្រោះទៅនុ៎ង គេបញ្ជូនទៅនុ៎ង ដាក់ម៉ាៗអាម៉ាវីនទៅ ព្រោះច្រឡូកច្រឡំគ្នា គ្រប់កងពលដែលគេហៅនិន្នាការកសាងខ្លួននៅកំពង់ឆ្នាំងហ្នឹង គេយកទៅនៅ ឡើងទន្លេបិទហ្នឹង គឺគេចាប់ឡើងឡានទាំងអស់គ្នាទៅបាទ។

**ស៖** បាទ ខ្ញុំសាកល្បងសួរម្ដងទៀត នៅពេលដែលលោកនៅព្រលានយន្តហោះកំពង់ឆ្នាំង គឺថាលោក គឺជាកងទ័ពចំណុះឲ្យកងពល៣១០ ត្រឹមត្រូវដែរឬទេ?

[១៤:០៣:៤២]

**ឆ៖** ជំនាន់នុ៎ងនៅចំណុះកងពល៣១០ បាទ។ តែដល់ពេលទៅធ្វើព្រលានយន្តហោះហ្នឹង ដូចជាដាច់ចំណុះកងពល៣១០ ហើយបាទ ព្រោះកន្លែងហ្នឹង កន្លែងកសាងខ្លួន។

**ស៖** <តើលោកដឹងដោយរបៀបណា?> តើអ្នកណាប្រាប់លោកអំពីរឿងនេះ? <>

**ឆ៖** ខ្ញុំដូចអត់ទាន់យល់ត្រង់ហ្នឹងបាទ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវីគួរសួរគាត់ថា អ្នកណាជាអ្នកប្រាប់គាត់នោះ ប្រាប់គាត់ថា គាត់លែងជាកងទ័ពចំណុះឲ្យកងពល៣១០ ទៀតហើយនោះ។

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** តើអ្នកណាជាអ្នកប្រាប់លោក<ថា> នៅពេលដែលលោកនៅព្រលានយន្តហោះកំពង់ឆ្នាំង <>គឺថាលោកលែងជាកងទ័ពចំណុះឲ្យកងពល៣១០ ទៀតហើយ<>?

[១៤:០៤:៤៣]

**ឆ៖** កន្លែងនុ៎ង កន្លែងកសាង។ កន្លែងគេហៅថា លត់ដំដើម្បីកសាងខ្លួន ព្រោះកន្លែងនុ៎ងកន្លែង

គេថា បើអ្នកណាកសាងខ្លួនមិនបាន គឺអាចវិលមកចូលជាប់គុកទួលស្លែងវិញ។ អ៊ីចឹងនៅកន្លែងនោះជាកន្លែងកសាង។ តែអ្នក -- មេនៅកន្លែងហ្នឹង ខ្ញុំក៏អត់បានស្គាល់ដែរ ព្រោះធ្វើការនៅកន្លែងនោះ ប្រឹងដើម្បីកុំឱ្យតែស្លាប់ ព្រោះដើម្បីការពារជីវិត ព្រោះកាលណាបើមិនប្រឹង ព្រលឹមឡើងម៉ោងបួនយប់ក្រោកធ្វើការ ទាល់ល្ងាចពីម៉ោងមួយទល់ ម៉ោងប្រាំបីយប់។ ប្រាំបីយប់នៅប្រជុំទៀត។ រួចអ៊ីចឹង ដល់អ៊ីចឹងអត់មានបានដឹងថា គេមេនោះ មិនដឹងឈ្មោះអីៗទេ ព្រោះមួយៗប្រឹងតែពីរឿងកសាងខ្លួនខ្លាចងាប់បាទ។

**ស៖** បើសិនជាខ្ញុំសល់ពេលវេលា ខ្ញុំត្រឡប់មកសួរចំណុចនេះវិញ។ លោកប្រធាន ខ្ញុំសូមផ្តល់លេខ ERN ដែលបានសន្យាផ្តល់ជូនគឺ ស្រេង ធី កំណត់ហេតុស្តាប់ចម្លើយ ស្រេង ធី 00270179 ជាលេខឯកសារយោងអំពីឯកសារស-២១<>។ លោកសាក្សី ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទ ដែលយើងបាននិយាយគ្នា<ខ្លះៗ>ពីម្សិលមិញ អំពីកិច្ចប្រជុំ<>នៅក្នុងសាលារៀនមួយនៅជិតវត្តភ្នំ <>គេចាក់<>ខ្សែអាត់សំឡេងឱ្យស្តាប់ ហើយគេប្រាប់លោកថា នេះជាអំពើក្បត់របស់ អឿន និង កុយ ធួន។ <>ម្សិលមិញនៅម៉ោង ១៥:៤៧នាទី លោកបានឆ្លើយថា នៅក្នុងកិច្ចប្រជុំនោះ <មាន>សមមិត្ត<> មកពី<វរសេនាតូច>៣១៤, <>៣០៦, ៣០៧ <ឬវរសេនាធំក៏>មក<ចូលរួមដែរ។> តើលោកអាចជួយបញ្ជាក់ចំណុចនេះបានទេ?

**ឆ៖** ពេលគេមកប្រជុំនៅសាលាខាងជើងវត្តភ្នំហ្នឹង ព្រោះគេហៅមកហ្នឹង វាគ្រប់វរៈមកកន្លែងហ្នឹង។ តែខ្ញុំស្គាល់មិនអស់ទេ វរៈ ព្រោះខ្ញុំស្គាល់តែក្នុងវរៈ៣១៤ ភស្តុភារខ្ញុំហ្នឹងទេ តែដល់វរៈគេនានា ខ្ញុំអត់ស្គាល់គេទេ ព្រោះមកហ្នឹងមកច្រើន ព្រោះកន្លែងហ្នឹងគេចាក់សំឡេង កុយ ឃួន និងមេកងពលខ្ញុំដូចជាលោក អឿន ហើយនិង បងវឿន ដែលជាអនុប្រធានកងពលហ្នឹងគេថា សុទ្ធតែក្បត់ហើយ។ មិត្តនេះជាប្រធាន មិត្តឯងបានក្បត់ ហើយនៅភូមិភាគកណ្តាលក៏ក្បត់ដែរ។ សូមមិត្តឯងកសាងខ្លួនទាំងអស់គ្នា។ កុំឱ្យគេចាប់ទាន់។ បាទ ខ្ញុំបាទៗ។

[១៤:០៨:១៥]

**ស៖** សូមបញ្ជាក់ឱ្យបានច្បាស់បន្ថែមទៀត។ ដូច្នេះ<> គឺថាលោកមិនស្គាល់អ្នកណាម្នាក់មកពីដូចជាកងវរសេនាតូច៣០៦ <ឬ>កងវរសេនាតូច៣០៧ ជាដើមនោះ<ទេ។> មែនទេ?

**ឆ៖** បាទ អត់ស្គាល់ទេ ស្គាល់តែក្នុងវរៈខ្លួនឯងទេបាទ ព្រោះវរសេនាតូចខ្លួនខ្ញុំ ស្គាល់ គឺពួកភស្តុភារគ្នាឯងហ្នឹងស្គាល់បាទ។

**ស៖** នៅក្នុងប្រជុំហ្នឹង គឺលោកនិយាយថា គេបានលើកយកបញ្ហាផែនការដែលធ្វើឡើងដោយ កុយ ធួន និង អឿន ដែលជាអ្នករៀបចំធ្វើរដ្ឋប្រហារនោះ។ <លោកមិនដឹងរឿងនេះឲ្យបានពិស្តារទេ នៅពេលខ្ញុំសួរកាលពីម្សិលមិញនោះ។> តើនេះជាលើកទី១ឬ ដែលលោកបានឮអំពីការបះបោរ ឬ ផែនការធ្វើរដ្ឋប្រហារ ឬក៏ផែនការទម្លាក់<> ប៉ុល ពត នោះ? តើលោកធ្លាប់ឮ <ឬដឹង>អំពីរឿងរ៉ាវ ទាំងអស់នេះមុនកិច្ចប្រជុំនេះដែរឬទេ<>?

**ឆ៖** ទើបឮគេ ប្រធានដែលផ្លាស់មកថ្មីក្តាប់កងពល៣១០ហ្នឹង ទើបប្រធានហ្នឹងគេលើកថា ឈ្មោះ អឿន នៅភូមិភាគកណ្តាលើហ្នឹង ភូមិភាគឧត្តរហ្នឹង ប្រុងថាបះពីវ៉ៃពីក្នុងភ្នំពេញ។ ទើបឮលើក នេះទេ តែពីដើមមក ខ្ញុំអត់ដឹងដែរ ទើបគេហៅប្រជុំហ្នឹង បានឮបាទ។

[១៤:១០:០៥]

**ស៖** ដូច្នេះមុនកិច្ចប្រជុំនោះ ខ្លួនលោកផ្ទាល់ហ្នឹងមិនដែលបានកត់សម្គាល់ឃើញថា ទោះបីក្នុង <វរសេនាតូច>លោក ឬក៏វរសេនាតូចដទៃ ឬក៏វរសេនាធំដទៃ<ក្តី ដែលចាត់ទុកថាជា>សកម្មភាព <បះបោរ ឬសកម្មភាព>រៀបចំធ្វើរដ្ឋប្រហារ <ដែរ>ឬ<ទេ>?

**ឆ៖** បាទ ខ្ញុំអត់ដឹងដែរ ព្រោះអង្កាល់ហ្នឹងខ្ញុំនៅកូនចៅគេ គេឲ្យធ្វើពេទ្យ គិតតែដើរចាក់កងទ័ព ហ្នឹង ព្រោះបើគេឈឺ វាឲ្យគេ ឲ្យទៅចាក់ដើរមើលគេគ្រប់កន្លែងហ្នឹងបាទ។

**ស៖** បាទ ខ្ញុំនឹងសួរឲ្យបានច្បាស់លាស់បន្ថែម។ ម្សិលមិញលោកបាននិយាយអំពីអង់តែន ទូរទស្សន៍ទូលគោកនៅជិតកន្លែងដែលលោកឈរជើង។ នៅម៉ោង១៥:៤៥ លោកក៏បាននិយាយអំពី <> ស្ថានីយ៍វិទ្យុនៅស្ទឹងមានជ័យផងដែរ។ មុនកិច្ចប្រជុំមួយនេះ តើលោកធ្លាប់ដែលបានឮអំពីផែនការ នៅក្នុងកងពល៣១០ ត្រៀមវាយ<>កាន់កាប់ស្ថានីយ៍វិទ្យុស្ទឹងមានជ័យដែរឬទេ?

[១៤:១១:៣៣]

**ឆ៖** បាទ ខ្ញុំអត់ដែលបានឮដែរ បើគេៗប្រជុំអីខ្ញុំក៏អត់ដឹងដែរ ក្រែងគេប្រជុំមេៗខ្ញុំអត់ដឹងដែរ។

**ស៖** អ្នកដែលនិយាយអំពីបញ្ហានេះមិនមែនជាមេបញ្ជាការទេ ប៉ុន្តែជាកូនទាហានធម្មតាដែលគេ បញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងដូចលោកដែរ ហើយគាត់មកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ នៅថ្ងៃទី២៣ មិថុនា ឆ្នាំ២០១៥។ នៅម៉ោង០៩:១១ព្រឹក នោះគាត់បានឆ្លើយនៅពេលនោះថា "មាន ផែនការវាយប្រហារស្ថានីយ៍វិទ្យុស្ទឹងមានជ័យ ហើយនៅពេលជាមួយគ្នាហ្នឹងក៏ត្រូវវាយដណ្តើមកាន់ កាប់ព្រលានយន្តហោះពោធិ៍ចិនតុងផងដែរ។ ហើយគាត់ក៏និយាយថា គោលបំណងចម្បងនោះ គឺថាជា

ការធ្វើរដ្ឋប្រហារហើយ”។ <យោធា>ឋានៈតូច<របស់>កងពល៣១០ ហ្នឹងបានឆ្លើយនូវរឿងរ៉ាវស្រដៀងគ្នានេះដែរ។ តើខ្លួនលោកផ្ទាល់នេះ <>បានដឹងអំពីរឿង<ហ្នឹង មុនពេលកិច្ចប្រជុំនោះ>ដែលយើងនិយាយគ្នាពីម្សិលមិញក៏ដូចជាថ្ងៃនេះ<ដែរឬ>ទេ?

**ឆ៖** ដូចជាអត់ដឹងទេបង ព្រោះខ្ញុំ រឹកហ្នឹងនៅធ្វើពេទ្យវរៈហ្នឹងគិតតែ គិតការងារដើម្បីខ្លាចគេថាយើងមិនធ្វើការ មិនបំពេញការងារគ្រប់បែបបទ អ៊ីចឹងគិតតែការងារខ្លួនឯងខ្លាចគេថាយើងខ្ចាំងយើងអីទៀត អ៊ីចឹងគិតតែកុំឲ្យ ប្រឹងធ្វើម៉េចកុំឲ្យតែខុសខ្លួនបាទ។

**ស៖** មុនកិច្ចប្រជុំមួយ<នោះ> តើលោកមានដឹង<>ថាគេមានឃ្លាំងមួយសម្រាប់<>ស្តុកអាវុធ<ទេ>?

**ឆ៖** អត់ ខ្ញុំអត់បានដឹងដែរបាទ។

[១៤:១៤:១២]

**ស៖** បាទ ខ្ញុំសូមយកសក្ខីកម្មរបស់សាក្សី ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការយើងនេះហើយមកសួរលោក ដើម្បីជួយរំឭកដល់ការចងចាំរបស់លោកខ្លះ។ នៅថ្ងៃទី២៣ មិថុនា <>នៅម៉ោង០៩:១១ព្រឹក សែម ហឿន ដែលមកពីវរសេនាតូច៣០៧ នោះគាត់បានឆ្លើយ សូមដកស្រង់៖ “សូមឲ្យខ្ញុំបញ្ជាក់អំពីផែនការបះបោរបន្តិច មាន សោ ភឹម នៅឯបូព៌ានោះ ហើយនិងតា កុយ ធួន នៅភូមិភាគឧត្តរ។ ពួកគាត់ហ្នឹងបានរៀបចំកម្លាំង<ខ្សែត្រៀមខាងមុខ និងខាងក្រោយ>រួចទៅហើយ។ កងទ័ពមជ្ឈិម <>បានត្រៀមរៀបចំ<ជាខ្សែត្រៀមជួរមុខ> ដើម្បីវាយប្រយុទ្ធទីក្រុងភ្នំពេញ ហើយកងទ័ពតំបន់ហ្នឹង<គឺទុកសម្រាប់វាយតាមតំបន់នានា>។” <បញ្ចប់ការដកស្រង់។>តើសក្ខីកម្មរបស់សាក្សីនេះវាជួយរំឭកដល់ការចង់ចាំរបស់លោកដែរឬទេ?

**ឆ៖** ពេលនុ៎ង ខ្ញុំភ្លេចបាត់ហើយ ព្រោះវាយូរពេក អត់បានចាំដែរ បាទ។

**ស៖** សំណួរចុងក្រោយទៅលើប្រធានបទនេះជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយអំពីវត្តមានរបស់លោកនៅសមរភូមិមុខ នៅពេលដែលវាយប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាម គឺថាលោក និងកងរបស់លោកបានរត់គេចខ្លួន។ សូមដកស្រង់៖ “អាយួន វាអាចនឹងអារកយើង--” អង់គ្លេស 00251258, បារាំង 00291010, ខ្មែរ 00019651។ “ទេ គឺថាយើងព្យាយាមដើរគេចចេញដោយខ្លួនឯង បើសិនណាយើងនៅទីនោះ គឺថាយួនអាចនឹងអារកយើងហើយ”។ តើហេតុអ្វីបានជាកងទ័ពនៅក្នុងអង្គភាពរបស់លោកនោះ <ខ្លាច>យួនអារក?

01390876



[១៤:១៦:៤៤]

**ឆ៖** ពេលហ្នឹងកងទ័ពហ្នឹង គេនៅប្រយុទ្ធ តែខ្ញុំហ្នឹងនៅ គេប្រយុទ្ធទៅ របួស ហើយខ្ញុំក៏រុំរបួសពួកកងទ័ពហ្នឹង។ នៅទប់ទល់នឹងជាមួយវៀតណាមហ្នឹង។ គេថា បើសិនជាវៀតណាមចូលវ៉ៃបាន គេនឹងអារកអស់ហើយពួកទ័ពយើងហ្នឹង។ ហើយពួកងទ័ពហ្នឹង គេប្រយុទ្ធទេ តែខ្ញុំអត់ទ័ពផង ខ្ញុំពេទ្យទេ។ អ៊ីចឹង គេត្រូវរបួស នៅរុំរបួសគេ។ ទទួលខ្ញុំត្រូវផ្តោងហ្នឹងបាទ។

**ស៖** តើការភ័យខ្លាចនេះ គឺជាការភ័យខ្លាចមួយដែលលោកធ្លាប់មានបទពិសោធន៍ជួបកាលពីពេលមុន ឬក៏លោកដឹង<ប្រភពមូលហេតុនៃការ>ភ័យខ្លាចយួន<ចាប់បាន>អារកចោល<ដែរឬទេ>?

**ឆ៖** ដូចពេលនុ៎ងខ្ញុំដូចជាមិនបានដឹងដែរ ដល់ខ្ញុំត្រូវរបួសហើយ ខ្ញុំអត់ដឹងថា គេរត់គេចខ្លួន មិនគេចខ្លួនទេ ព្រោះអង្កាល់រឹកហ្នឹង គេនៅកំពុងតែប្រយុទ្ធជាមួយកងទ័ពវៀតណាម នៅត្រពាំងផ្លុង ហើយនិងច្រករំដេង ហើយទទួលខ្ញុំត្រូវរបួសទៅ ខ្ញុំអត់បានដឹងទៀតទេ ព្រោះខ្ញុំគេបញ្ជូនមកសម្រាកពេទ្យហើយបាទ។

**ស៖** តាមបទពិសោធន៍របស់លោកជាពេទ្យ<យោធា>ហ្នឹង តើលោកធ្លាប់ជួបប្រទះយុទ្ធ<មិត្ត>របស់លោក<>ធ្លាប់បានកងទ័ពវៀតណាមហ្នឹងអារកដែរឬទេ?

[១៤:១៨:៣៣]

**ឆ៖** ដូចមិនដែរទេ ព្រោះអានេះ វានយោបាយខាងខ្មែរក្រហមហ្នឹង គេធ្វើឲ្យយើងមានការឈឺចាប់ជាមួយវៀតណាម។ អ៊ីចឹង ឲ្យយើងប្រឹងវ៉ៃជាមួយវៀតណាម។ អ៊ីចឹងអ្នកដែលទ័ពទាំងប៉ុន្មានហ្នឹងសុទ្ធតែអ្នកមិនដឹង ភ័យ ខំប្រឹងវ៉ៃជាមួយវៀតណាម។

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ អរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរខ្លះៗសួរទៅលោក ក្នុងនាមឲ្យការិយាល័យសហព្រះរាជ

អាជ្ញា។ បាទ លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សីនូវឯកសារមួយដែលជាកំណត់ត្រារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានតែជាភាសាខ្មែរទេ។ ជាប្រវត្តិរូបរបស់កម្ពុជាប្រជាធិបតេយ្យ គឺ E3/7537, ខ្មែរ<ទំព័រ> 00019461 ដល់ 68។ បាទ ខ្ញុំសុំការអនុញ្ញាតបង្ហាញឯកសារនេះ ទៅសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌែល លីសាក់៖**

**ស៖** លោកសាក្សី សូមលោកពិនិត្យមើលឯកសារនេះមើល៍។ <>តើលោកចេះអានទេ? ហើយបើលោកចេះអាន តើនេះ គឺជាប្រវត្តិរូបដែលលោកបានសរសេរនៅក្នុងរបបខ្មែរក្រហមនោះឬ?

**លោក នួន គ្រិច៖**

**ឆ៖** បាទ ខ្ញុំចេះអានដែរ ព្រោះហ្នឹងប្រវត្តិរូបជំនាន់ខ្ញុំនៅខ្មែរក្រហម គេធ្វើប្រវត្តិរូបឲ្យ ព្រោះថ្ងៃចូលធ្វើបដិវត្តន៍ជំនាន់ខ្មែរក្រហមហ្នឹង គេធ្វើប្រវត្តិរូប គេចុះឲ្យអ្នកគ្រប់គ្នាអ៊ីចឹង ត្រូវតែចុះ បាទ។

[១៤:២១:២០]

**ស៖** នៅទំព័រទី១ និងទំព័រទី២ នៃប្រវត្តិរូបនេះ គេបានកំណត់អត្តសញ្ញាណលោកថា ជាពេទ្យ<យោធា>នៅអនុសេនាធំ២ វរសេនាតូច៣១៤ កងពលលេខ៣១០។ ហើយក៏បានបញ្ជាក់ផងដែរថា នៅពេលនុ៎ង លោកមានអាយុ២១ឆ្នាំ នេះបើយោងតាមប្រវត្តិរូបនេះ។ តើត្រឹមត្រូវដែរឬទេថា ប្រវត្តិរូបនេះ <>បានសរសេរនៅឆ្នាំ១៩៧៦ <បន្ទាប់ពីលោកចេញពី ព-៩៩ ទៅ>ចូលជាមួយនឹងកងវរសេនាតូច៣១៤នោះ?

**ឆ៖** ពេលនុ៎ង ខ្ញុំចុះហ្នឹង ខ្ញុំភ្លេចភ្លាំងអស់ហើយ ព្រោះកាលនុ៎ង គេឲ្យធ្វើប្រវត្តិរូប បាទ ព្រោះអត់ចាំទេ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ហើយឥឡូវនេះ ខ្ញុំចូលសួរលោក អំពីកិច្ចប្រជុំ<មួយ> ដែលលោកបានរៀបរាប់រួចហើយថា លោកបានចូលរួមក្នុងកិច្ចប្រជុំនោះ នៅក្នុងសាលារៀនមួយនៅខាងជើងវត្តភ្នំ។ ហើយក្នុងនោះមានលោក ក៏ដូចជាសមាជិកកងពល៣១០ហ្នឹង គឺត្រូវបានគេប្រាប់អំពីការចាប់ខ្លួន អឿន លេខាកងពល ហើយគេក៏បានចាក់ខ្សែអាត់សំឡេង<សារភាពរបស់គាត់>ឲ្យស្ដាប់ផង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែរ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា អង្គប្រជុំហ្នឹង<រៀបចំនៅក្រោមអធិបតីភាពរបស់នរណា? នរណា>ជាអ្នកឡើងនិយាយ? <>

[១៤:២៣:២៥]

**ឆ៖** ពេលគេចាប់ អឿន ចាប់អីហ្នឹងទៅ គេយកភូមិភាគនិរតីមកក្ដាប់ ខ្ញុំអត់ស្គាល់ដែរ មេគេទើបនឹងមកថ្មី ដឹងឈ្មោះអីដែរ បាទ ព្រោះគេថាកងពល៣១០ហ្នឹងក្បត់ហើយ។ ហើយនិងភូមិភាគឧត្តរក៏ក្បត់ដែរ។ អ៊ីចឹងសូមមិត្តទាំងអស់គ្នា កុំ -- កសាងខ្លួនទៅ ឲ្យបានល្អ ព្រោះមេមិត្តទាំងអស់គ្នាហ្នឹងក្បត់ហើយ។ អ៊ីចឹង បាទ ខ្ញុំអត់ដឹងជាគេឈ្មោះអីដែរទេ បាទ។

**ស៖** ខ្ញុំជួយឲ្យលោកអាចនឹកឃើញបាន គឺនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ ក.ស.ច.ស គឺឯកសារ E3/7877, ខ្មែរមានលេខ 00342436, បារាំងមានលេខ 00411784, អង់គ្លេសមានលេខ 00346978។ នេះគឺជាអ្វីដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។ លោកបានឆ្លើយថា៖ "អឿន ជាប្រធានកងពល ត្រូវបានគេចាប់ខ្លួននៅពាក់កណ្ដាលឆ្នាំ៧៧។ ខ្ញុំដឹង ព្រោះដោយសារមានការប្រជុំមួយ នៅក្នុងសាលាមួយក្បែរវត្តភ្នំ ដែលមានកម្មាភិបាល និងយុទ្ធជនទាំងអស់មកពីកងពល៣១០ចូលរួម។ <>ញ៉ៅ បានប្រកាសថា អឿន ត្រូវចាប់ខ្លួនហើយ ព្រោះជាខ្មែ្ស សេ.អ៊ី.អា របស់អាមេរិក។ បើមិនជឿទេ ខ្ញុំនឹងចាក់ខ្សែអាត់ឲ្យស្ដាប់។ បន្ទាប់មកគេ<ចាក់>កាសែតឲ្យស្ដាប់ក្នុងពេលនោះតែម្ដង ដោយដាក់តាមមីក្រូបីបួននៅកន្លែងប្រជុំនោះ។" ដូច្នេះក្នុងចម្លើយនេះ គឺលោកនិយាយនៅពេលដែលលោកសម្ភាសជាមួយ<>សហចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៩ហ្នឹង គឺលោកនិយាយអំពីឈ្មោះ ញ៉ៅ ថាតើវាអាចជួយឲ្យលោកនឹកឃើញបានទេថា ឈ្មោះ ញ៉ៅ ហ្នឹងគឺជាគណៈអធិបតីនៅក្នុងការប្រជុំនោះ?

[១៤:២៥:៥៣]

**ឆ៖** អត់បាននឹកឃើញដែរ ព្រោះពេលនុ៎ងខ្ញុំនៅអង្គុយក្រោយគេ ព្រោះស្ដាប់ទៅតាមសំឡេងគេចាក់ខ្សែអាត់ ហើយឈ្មោះ ញ៉ៅ ហ្នឹងក៏ខ្ញុំអត់ស្គាល់ទេ ព្រោះគេផ្លាស់មកថ្មី គេថាគេប្រធានកងពលមកពីនិរតីហ្នឹងមកក្ដាប់ពួកកងពល៣១០ហ្នឹង។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោកអំពីពេលវេលានៃការប្រជុំនេះ។ តើលោកដឹងទេថា ការប្រជុំហ្នឹងគេធ្វើឡើងនៅពេលណាដែរ? ថាតើគេប្រជុំប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានអាទិត្យ ប៉ុន្មានខែក្រោយពេលដែលគេចាប់ខ្លួន អឿន នោះ? តើលោកអាចដឹងទេថា <>ប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានអាទិត្យក្រោយពេលដែល<គេ

ចាប់ខ្លួន> អឿន <បាត់ទៅ> ទើបគេរៀបចំការប្រជុំនេះឡើង?

**ឆៈ** គេចាប់ អឿន ប្រធានកងពលហ្នឹង បានប្រហែលជាកន្លះខែ ត្រូវគេអ្នកផ្លាស់មកថ្មីពីភូមិភាគនិរតីហ្នឹង គេហៅប្រជុំម៉ាកង តាមវរៈហ្នឹងមកប្រជុំនៅខាងជើងវត្តភ្នំហ្នឹង។

**សៈ** លោកសាក្សី បើតាមកំណត់ត្រារបស់ ស-២១ គឺបានបញ្ជាក់អំពីលេខចូលគឺ ៨១៣៥ នៅក្នុងបញ្ជីស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺលេខាកងពល៣១០ឈ្មោះ អឿន ចូល ស-២១ នៅថ្ងៃ១៩ កុម្ភៈ ១៩៧៧។ លោកបានបញ្ជាក់ថា ការប្រជុំហ្នឹងគឺរៀបចំឡើងប្រហែលជាពីរសប្តាហ៍ក្រោយពេលដែល អឿន បាត់ខ្លួននោះ។ អ៊ីចឹងបានន័យថា វាប្រហែលជាគេរៀបចំនៅក្នុងខែមីនា ៧៧ តើថាវា<>ត្រឹមត្រូវទេ ដែលថាការប្រជុំហ្នឹងរៀបចំនៅក្នុងខែមីនា ៧៧ នោះ?

[១៤:២៨:១៥]

**ឆៈ** ខ្ញុំអត់បានចាំដែរ ព្រោះពេលនុ៎ងអត់បានយកចិត្តទុកដាក់ ព្រោះដល់គេចាប់ប្រធានកងពលទៅ មួយៗភ័យគ្រប់គ្នា។ ឮគេថាឲ្យសុទ្ធតែកងពលហ្នឹងសុទ្ធតែកងពល គេហៅថាខ្មាំង គេថាឲ្យកសាងខ្លួន ដល់អ៊ីចឹង ដល់គេចាប់អ៊ីចឹងនាំគ្នាភ័យគ្រប់គ្នា ព្រោះចាប់ភូមិភាគកណ្តាលផង ចាប់កងពលហ្នឹងផង។ គេថាសុទ្ធតែកងពលខ្មាំង និងភូមិភាគខ្មាំង។ ដល់អ៊ីចឹងអត់មានទៅបានចាប់ភ្លឹកថាថ្ងៃនេះ ដូចជាថ្ងៃណាទេ ព្រោះអត់បានចាប់អារម្មណ៍បាទ។

**សៈ** មិនអីទេលោក ខ្ញុំអាចយល់អំពីចំណុចនេះ។ កិច្ចប្រជុំដែលលោកចូលរួមនៅវត្តភ្នំហ្នឹង ថាតើការប្រជុំហ្នឹងវាធ្វើឡើងអស់រយៈពេលប៉ុន្មានថ្ងៃដែរ ថាតើធ្វើតែ១ថ្ងៃ ឬក៏គេធ្វើឡើងច្រើនថ្ងៃហ្នឹង? តើលោកអាចប្រាប់បានទេថាគេប្រជុំប៉ុន្មានថ្ងៃដែរ?

**ឆៈ** គេប្រជុំ៣ថ្ងៃបាទ គេហៅមកប្រជុំ៣ថ្ងៃ។

**សៈ** ទាក់ទងទៅនឹងការចាក់ខ្សែអាត់របស់ អឿន ហ្នឹង តើគេចាក់<ខ្សែ>អាត់សំឡេង អឿន តាមមីក្រូហ្នឹង គេចាក់<រយៈពេលប៉ុន្មាន>ដែរ?

**ឆៈ** បើតាមគេចាក់ហ្នឹង ចាក់គេប្រធានដែលគេមកថ្មីហ្នឹង ប្រធានកងពលមកថ្មីហ្នឹង គេនិយាយពីរឿងថា កងពលក្បត់និងភូមិភាគកណ្តាលក្បត់ហ្នឹង គេនិយាយរួចទៅ បានគេចាក់សំឡេងហ្នឹងឲ្យស្តាប់។ ដល់ស្តាប់ទៅសំឡេងប្រធានកងពលនុ៎ងមែន។ បាននាំគ្នាថា អូ! ប្រធានហ្នឹងត្រូវគេចាប់ហើយបាទ។

**សៈ** ខ្ញុំចង់សួរថា តើគេចាក់ខ្សែអាត់ហ្នឹង<រយៈពេល>ប៉ុន្មាន<>ដែរ? តើគេចាក់មួយម៉ោង ឬ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏ប៉ុន្មាន<ថ្ងៃ>អីដែរ លោកចាំទេ ពេលដែលគេចាក់ខ្សែអាត់សំឡេងនុ៎ង?

[១៤:៣០:៤៨]

**ឆ៖** ភ្លេចហើយ បាទ ព្រោះយូរហើយ ភ្លេចការចងចាំហើយ បាទ។

**ស៖** លោកសាក្សី ខ្ញុំនឹងអាននូវសម្រង់ពីកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ច.ស របស់បុគ្គលម្នាក់ទៀត ដែលមកពីកងពល៣១០ដែរ គឺជាពេទ្យ<យោធា>ដែលធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលា។ បុគ្គលនោះឈ្មោះ យឿន សំបូរ ហៅ យ៉ន។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារជូនដល់សាក្សី ដើម្បីឲ្យ<>គាត់អាចមើលឃើញឈ្មោះបុគ្គល ក៏ដូចជាអាចមើលពីប្រវត្តិរូបរបស់បុគ្គលនេះផងដែរ។ ដូច្នេះសូមអនុញ្ញាតផ្តល់ឯកសារ E3/5497។ សុំលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៤:៣២:០២]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកបានទទួលនៅចម្លើយរបស់សាក្សីមួយរូបទៀតដែលជាពេទ្យ<យោធា>នៅកងពល៣១០<ដែរ>។ ខ្ញុំបានដាក់សញ្ញាសម្គាល់នៅក្បែរឈ្មោះរបស់គាត់ហើយ គឺគាត់មានឈ្មោះហៅក្រៅថា យ៉ន។ ដូច្នេះខ្ញុំចង់សួរលោកថា លោកចាំ<>មនុស្សម្នាក់ឈ្មោះហៅក្រៅឈ្មោះ យ៉ន ដែល<>ជាពេទ្យ<យោធា>នៅមន្ទីរពេទ្យព្រះកេតុមាលាដែរទេ?

**លោក នួន ត្រិច៖**

**ឆ៖** លោក យ៉ន ឈ្មោះ យ៉ន ហ្នឹងខ្ញុំស្គាល់ ធ្វើការនៅជាមួយគ្នា បាទ នៅក្នុងពេទ្យហ្នឹងជាមួយគ្នាកាលមុនបាទ។

**ស៖** ខ្ញុំចង់អានឲ្យលោកស្តាប់<នូវ>អ្វីដែល យ៉ន បានឆ្លើយ អំពីការប្រជុំក្រោយពេលចាប់ឈ្មោះ អឿន នោះ ហើយគឺឯកសារ E3/5497 ខ្មែរមានលេខ 00343726, បារាំងមានលេខ 00411791 ដល់ 92, អង់គ្លេសមានលេខ 00345959 ដល់ 960។ នេះគឺជាអ្វីដែល យ៉ន បានឆ្លើយ។

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំគិតថា សំណួរគួរតែកែសម្រួលបន្តិច លោកប្រធាន ព្រោះ យ៉ន និយាយអំពីការប្រជុំ ប៉ុន្តែមិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មែនប្រាកដថាជាការប្រជុំជាមួយគ្នាដូចដែលសាក្សីបាននិយាយឡើយ។ ដូច្នេះខ្ញុំគិតថាគួរតែសួរជាទូទៅដល់មិនត្រូវសន្មត ឬក៏សន្និដ្ឋានថាការប្រជុំក្នុងពេលជាមួយគ្នា និងជាការប្រជុំតែមួយ<នោះឡើយ>។

[១៤:៣៤:០៨]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកប្រធាន ខ្ញុំមិនបាននិយាយថា ជាការប្រជុំតែមួយនោះទេ។ ខ្ញុំគ្រាន់តែចង់អានអំពីអ្វីដែល យ៉ន បាននិយាយអំពីការប្រជុំ។ យ៉ន គាត់បាននិយាយដូចតទៅនេះ ទាក់ទងទៅនឹងការប្រជុំក្រោយពេលចាប់ខ្លួន អឿន។ ខ្ញុំសូមដកស្រង់ គឺគាត់និយាយអំពីការដែលគាត់ដឹងអំពីការចាប់ខ្លួនឈ្មោះ អឿន៖ "ខ្ញុំបានដឹងរឿងទាំងអស់នេះ តាមរយៈ សុន សេន ហៅ ខៀវ។ គាត់បានមកចូលរួមប្រជុំបើកវគ្គបង្រៀនកងពល៣១០នៅជិតវត្តភ្នំ ដោយមានការចូលរួមពីកម្មាភិបាល<ពី>កងវរសេនាតូច កងអនុសេនាធំ កងអនុសេនាតូច។ ហើយខ្ញុំជាពេទ្យ<យោធា>ប្រចាំការព្យាបាលសិក្ខាកាមដែលចូលរួមប្រជុំនោះ <ហើយខ្ញុំ>ក៏បានចូលរួមប្រជុំ<នោះ>ដែរ។ វគ្គប្រជុំរៀនសូត្រនេះ មានរយៈពេល៣ថ្ងៃ ពេលនោះ សុន សេន បាននិយាយក្នុងអង្គប្រជុំថា ឈ្មោះ អឿន ប្រធានកងពលមានគំនិតក្បត់ជាមួយឈ្មោះ សំបូរ ជាប្រធានកងពលដែរ។" ហើយអានបន្តទៅទៀត "ក្រោយពេល អឿន ចាប់ខ្លួន, ញ៉ ត្រូវបាន<ចាត់តាំង>ធ្វើជាប្រធានកងពលជំនួស អឿន ដែល សុន សេន បានប្រកាសនៅក្នុងអង្គប្រជុំនោះតែម្តង។ ឈ្មោះ ញ៉ មកពីខាងភូមិភាគនិរតី។ សុន សេន បានមកបើកបង្រៀនតែវគ្គទី១ទេ ក្រោយមកឈ្មោះ ញ៉ ជាអ្នក<គ្រប់គ្រង>វគ្គបង្រៀនបន្តបន្ទាប់ គឺវគ្គទី២ ទី៣ ទី៤ និង ទី៥។" សូមបញ្ចប់ការដកស្រង់។

ដូច្នេះ ខ្ញុំចង់សួរលោកថាតើនេះគឺជាការប្រជុំតែមួយដូចដែលលោកបានចូលរួមដែរឬទេ? ហើយតើលោកចាំទេថា នៅពេលចាប់ផ្តើមការប្រជុំហ្នឹង សុន សេន គាត់បានឡើងថ្លែង<ចំណាប់អារម្មណ៍ដំបូង> មុនពេលដែល ញ៉ បន្តការងាររបស់គាត់?

[១៤:៣៦:១៣]

**ឆ៖** ពេលគេហៅទៅប្រជុំនៅវត្តខាងជើងវត្តភ្នំហ្នឹង សាលាហ្នឹង ដូចឮថាសម្តី ញ៉ កងពលមកក្រោយហ្នឹងទេ។ អត់មានឃើញ សេន ទេ ព្រោះក្រែងគេប្រជុំមុនក៏មិនដឹង ព្រោះខ្ញុំ ក្រែងខ្ញុំទៅវគ្គក្រោយបាទ មិនដឹង។

**ស៖** ក្នុងរបបហ្នឹង តើលោកស្គាល់ថា សុន សេន ជានរណាទេ? ហើយតើលោកធ្លាប់ជួប សុន

សេន ទេ នៅក្នុងរបបនោះ?

**ឆ៖** បានគ្រាន់តែឮ តែឈ្មោះអត់ដែលឃើញគាត់មុខរបៀបម៉េចផង។ មេធំៗអត់ដែលស្គាល់ផង។ ឃើញ -- ឮតែឈ្មោះ។

**ស៖** នៅពេលដែលគេចាក់ខ្សែអាត់ចម្លើយសារភាពរបស់ឈ្មោះ អឿន ហ្នឹង តើគេមានប្រាប់លោកថាគេធ្វើទារុណកម្ម អឿន ដើម្បីទទួលបានចម្លើយសារភាពនោះទេ? តើមានអ្នកណាម្នាក់និយាយថា អឿន ត្រូវបានគេធ្វើទារុណកម្ម ដើម្បីឲ្យឆ្លើយសារភាពបែបនេះទេ?

**ឆ៖** ពេលនុ៎ង ខ្ញុំភ្លេចហើយ ភ្លេចការចងចាំហើយ យូរហើយបាទ។ ដឹងតែចាប់ឈ្មោះ អឿន ហ្នឹងបាទ។

**ស៖** លោកបានផ្តល់ចម្លើយកាលពីមុនថា ក្រោយការប្រជុំនេះ គឺមានការចាប់ខ្លួនកម្មាភិបាលកងពល៣១០ទៀត។ តើលោកអាចប្រាប់បានទេ ថាតើការចាប់ខ្លួនហ្នឹង គេចាប់ខ្លួនញឹកញាប់បែបណាហើយតើមនុស្សប៉ុន្មាននាក់នៅក្នុងកងពលហ្នឹង ត្រូវបានគេចាប់ខ្លួនក្រោយពេលបញ្ចប់ការប្រជុំនោះ?

[១៤:៣៨:២៤]

**ឆ៖** អាពេលនុ៎ងវាឃើញតែគេថា ផ្លាស់ពីកងនេះទៅកងនោះ តែវាដល់នេះទៅ មិនដែលឃើញមកវិញ ឃើញតែទៅបាត់ តែមិនដឹង ដល់សួរគេទៅ គេថាសុទ្ធតែចាប់ខ្លួន។ តែគេ ពេលគេចាប់នុ៎ង គេអត់ឲ្យយើងដឹងទេ គេថា នែ! មិត្តឯងផ្លាស់ទៅនៅវរៈនេះ មិត្តឯងផ្លាស់ទៅវរៈនោះ ដើម្បីកសាងខ្លួន។ តែរឿងត្រង់គេចាប់ថា យកទៅដាក់ទួលស្លែង គឺអត់ដឹងដែរ ព្រោះអ្នកយកទៅនុ៎ងសុទ្ធបាត់ទាំងអស់ អត់ឃើញមកវិញ។

**ស៖** តើលោកធ្លាប់ឃើញផ្ទាល់ភ្នែកទេ គឺថា<>កម្មាភិបាលនៅក្នុងកងវរ<សេនាតូច>របស់លោក ឬក៏កងពលរបស់លោក ត្រូវបានគេចាប់ខ្លួន ឬក៏គេយកទៅនុ៎ង។ តើខ្លួនលោកផ្ទាល់ធ្លាប់ឃើញផ្ទាល់ភ្នែកទេ អំពីហេតុការណ៍បែបនេះ?

**ឆ៖** បានឃើញមេខ្ញុំផ្ទាល់ ពីរនាក់ បងស្រឡៅ ហើយនិង បងនឹម អាហ្នឹងឃើញគេមកហៅយកទៅវ៉ៃ ចងនៅនឹងភ្នែកបាទ។ ព្រោះគាត់មេខ្ញុំផ្ទាល់ដែរហ្នឹងបាទ។

**ស៖** តើលោកឃើញគេចងពួកគាត់ហ្នឹង ឃើញនៅកន្លែងណាដែរ?

**ឆ៖** ពេលនុ៎ងគាត់នៅបឹងបាយ៉ាប ហើយខ្ញុំក៏គេហៅឲ្យទៅព្យាបាលនៅកន្លែងបឹងបាយ៉ាបនៅជិតមន្ទីរពិការ ហើយខាងភស្តុភារ៣១៤ហ្នឹង នៅបឹងបាយ៉ាបហ្នឹងដែរ។ អ៊ីចឹងគេ ក៏ពេលហ្នឹងគេបើក

ឡានមកចងឈ្មោះ នឹម និងឈ្មោះ ស្រឡៅ – ស្រឡៅ ចងនៅនឹងបឹងបាយ៉ាប។ ឈ្មោះ នឹម ចងនៅនឹងជិតវត្តឃ្មួញ ពេលនុ៎ងខ្ញុំឃើញនឹងភ្នែកដែរបាទ។

[១៤:៤០:៥៨]

**ស៖** តើអ្នកណាជាអ្នកមកចាប់ពួកគាត់ចងយកទៅនោះ តើលោកដឹងទេ?

**ឆ៖** ពេលនុ៎ងខាង៥០២ គេ អ៎! ខាងនិរតីគេមកក្ដាប់ហើយ ខ្ញុំអត់ស្គាល់ដែរ ព្រោះគេសុទ្ធទើបផ្លាស់មកភូមិភាគនិរតី គេសុទ្ធតែមកក្ដាប់ពីលើភូមិភាគឧត្តរហ្នឹង។ អ៊ីចឹងអត់បានស្គាល់គេដែរបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:២៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី គឺយើងបាននិយាយគ្នាអំពីការចាប់ខ្លួន ដែលលោកបានឃើញទាក់ទងទៅនឹងការចាប់ខ្លួនមេពីរនាក់របស់លោក ដែលលោកបានរៀបរាប់ថាលោកបានឃើញ<នៅបឹងបាយ៉ាប នាពេលនោះ>។ ហើយអ្នកដែលមកចាប់ខ្លួនពួកគាត់នោះ តើអ្នកដែលមកហ្នឹង មានកាំភ្លើង ឬក៏មានអាវុធ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អីមកជាមួយដែរឬទេ?

**លោក នួន ត្រិច៖**

**ឆ៖** ពេលមកចាប់ បងនឹម និងបង ស្រឡៅ ហ្នឹង គេមានកាំភ្លើងមកជាមួយ។ មកប្អូនប្រាំនាក់។ បាទ ព្រោះមកហ្នឹង ខ្ញុំនៅនឹងដែរ ព្រោះមកដល់ហ្នឹង ហៅ បងនឹម ហ្នឹង ថាមកជួបខ្ញុំបន្តិច។ ហើយបង នឹម ហ្នឹង ក៏គាត់ចេញទៅ ក៏ចាប់ចងយកតែម្តងបាទ។

**ស៖** លោកបានផ្តល់ចម្លើយថា លោកនៅក្នុងកងវរ<សេនាតូច>៣១៤ <ជាវរសេនាតូចភស្តុភារ> នៅក្នុងកងពល៣១០ <>ហើយប្រវត្តិរូបរបស់លោកក៏បានបញ្ជាក់ដូច្នេះដែរ។ <>មានកម្មាភិបាលកង<វរសេនាតូច>៣១៤ មួយចំនួន នៅក្នុង<បញ្ជី>របស់ ស-២១ <ហើយខ្ញុំនឹងសួរលោកអំពីពួកគេ>។

ដូច្នេះ លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ជូនសាក្សីនូវឯកសារមកពីស-២១ ជាបញ្ជីអ្នកទោសមកពីកងពល៣១០ គឺឯកសារ E3/2592<>។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីប្រគល់ជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:០៤:០១]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ខ្ញុំចង់សួរលោកអំពីមនុស្សពីរនាក់ គឺនៅទំព័រទី១ នៃឯកសារនេះ។ លោកសាក្សី គឺចាប់ផ្តើមជាមួយលេខ២៨ នៅក្នុងបញ្ជីនេះ។ លេខ២៨ គឺជាអ្នកទោសមកពីកងពល៣១០ ឈ្មោះ <វ៉ា បេ> ដែលគេ<ស្គាល់>ថាជាលេខាកងវរ<សេនាតូច>៣១៤ ចូលនៅថ្ងៃ០៥ ឧសភា ៧៧។ លោក លោកស្រីចៅក្រម ក៏មាននៅក្នុងលេខ១៣៩៤ នៅក្នុងបញ្ជីរបស់ ក.ស.ច.ស ផងដែរ ហើយអ្នកដែលខ្ញុំនិយាយនៅក្នុងលេខ២៨ហ្នឹង គឺនៅចុងទំព័រ។ តើលោកចាំមនុស្សម្នាក់ដែលគេសរសេរថាជាមេបញ្ជាការកងវរ<សេនាតូច>៣១៤នោះទេ?

**លោក នួន ត្រិច៖**

**ឆ៖** ដូចជាអត់ចាំទេ ព្រោះខ្ញុំចាំតែ បងយៀត ហើយនិងហើយ ក្រាន បាទ ហើយ បា ហ្នឹងអត់ចាំទេបាទ។

**ស៖** បុគ្គលទី២ នៅក្នុងបញ្ជីដដែលហ្នឹងគឺមនុស្សដែលមានលេខ១៤ គឺលេខ១៤ នៅក្នុងបញ្ជីស-២១ E3/2592 នោះ គឺឈ្មោះ ម៉ក យីហឿង ហៅ នឹម ដែលគេរៀបរាប់នៅក្នុងបញ្ជីនេះថា ជាជំនួយការមន្ទីរវរសេនាតូចខាងភស្តុភារ ចូលស-២១ ថ្ងៃ៨ ខែ៥ ៧៧។ ហើយបុគ្គលដដែលនេះក៏មាននៅក្នុងបញ្ជី ក.ស.ច.ស ផងដែរ។ គឺលេខ៤៧០១ ដែលគេរៀបរាប់ថាជាជំនួយការមន្ទីរវរៈ៣១៤ ខាងភស្តុភារដូចគ្នា។ តើលោកស្គាល់មនុស្សដែលមាននៅក្នុងលេខរៀងទី១៤ ឈ្មោះហៅថា នឹម ដែលជាមនុស្សតែមួយដែលលោករៀបរាប់ថាជាអនុប្រធានកងរបស់លោកហ្នឹង តើមែនទេ?

**ឆ៖** បាទ ឈ្មោះ នឹម ហ្នឹងស្គាល់។ ព្រោះគាត់ជាប្រធានខ្ញុំដែរបាទ។

[១៥:០៧:០២]

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថាតើឈ្មោះ នឹម ហ្នឹងគឺជាឈ្មោះដែលលោករៀបរាប់ថាបាន<ឃើញគេ>ចាប់ខ្លួននៅ<បឹងបាយ៉ាប> ដែលលោករៀបរាប់ពីរសៀលហ្នឹង<>មែនទេ?

**ឆ៖** បាទ ឈ្មោះ នឹម ហ្នឹងគេចាប់ខ្លួន ព្រោះ នឹម ហ្នឹងកាលមុនគាត់នៅខាងភស្តុភារវរសេនាវរៈ៣១៤ហ្នឹង។ នឹម ហ្នឹងគាត់ទៅឈរជើង -- តែនៅក្នុងភស្តុភារ៣១៤ដែរ តែគាត់នៅឈរជើងនៅបឹងបាយ៉ាបបាទ។

**ស៖** សូមអរគុណ។ លោក លោកស្រីចៅក្រម ដើម្បីជាកំណត់ត្រាប្រតិចារឹក នឹម ក៏មាននៅក្នុងលេខរៀងទី៩ នៅក្នុងបញ្ជីស-២១ របស់អ្នកទោស<ចំនួន១៩៨នាក់>ដែលត្រូវបានកម្ទេចនៅ<ថ្ងៃទី១០> ខែមិថុនា ៧៧ គឺឯកសារ E3/2132។ គឺ នឹម នៅលេខរៀងទី៩ នៃបញ្ជី<>មនុស្ស<ដែលត្រូវសម្លាប់>នេះ។ ដូច្នេះ ខ្ញុំចង់សួរលោកផងដែរ អំពីមនុស្សមួយចំនួនទៀតដែលលោកធ្លាប់ធ្វើការជាមួយនៅមន្ទីរពេទ្យព្រះកេតុមាលា។ តើលោកដឹងទេថា មានបុគ្គល ឬក៏មានបុគ្គលិកដទៃទៀត នៅក្នុងមន្ទីរពេទ្យព្រះកេតុមាលា ដែលត្រូវបានគេចាប់ខ្លួន ឬក៏បានបាត់ខ្លួននៅក្នុងឆ្នាំ៧៧ ដែរទេ?

**ឆ៖** ពេលនុ៎ងកងពល៣១០ហ្នឹង ត្រូវគេរំសាយ ពួកខាងនិរតីហ្នឹងគេមកក្តោបក្តាប់គឺ ពេទ្យព្រះកេតុមាលាធ្វើការជាមួយគ្នា គឺបាត់ខ្លួនអស់មិនដឹងគេផ្លាស់ទៅខាងណា ដកទៅខាងណា ខ្ញុំអត់បានដឹងដែរ ព្រោះអត់ដែលបានជួបគ្នា អត់ដែលឃើញគ្នា ព្រោះពេលហ្នឹងគេរំសាយពីគ្នាអស់រលីងបាទ។

[១៥:០៩:៣៥]

**ស៖** អ្នកដែលបាត់ខ្លួនពីមន្ទីរពេទ្យព្រះកេតុមាលាហ្នឹង តើពួកគាត់ហ្នឹង គឺជាមនុស្សមកពី<ភូមិភាគឧត្តរ, ភូមិភាគ៣០៤> ដូចលោកដែរ អ៊ីចឹងមែនទេ?

**ឆ៖** អត់ទេ សុទ្ធតែមកពីភូមិភាគកណ្ដាលទាំងអស់គ្នា បាទ។

**ស៖** គឺខ្ញុំនិយាយអំពីភូមិភាគតែមួយជាមួយលោក។ លោកមកពីភូមិភាគកណ្ដាល ដែលពីមុនគេហៅថាជាភូមិភាគឧត្ដរ ឬក៏<ភូមិភាគ>៣០៤នោះ តើមែនទេ?

**ឆ៖** ពីមុនហ្នឹង ជំនាន់៧០គត់មក គេធ្វើរដ្ឋប្រហារវាយទាហានលន់នល់ហ្នឹង គេដាក់ភូមិភាគហ្នឹង ភូមិភាគ៣០៤ គេដាក់ឈ្មោះជាភូមិភាគ៣០៤ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ លោកដឹងទេថា មានអ្វីកើតឡើងចំពោះប្រពន្ធ និងសាច់ញាតិរបស់មេបញ្ជាការកងពល៣១០ ឧទាហរណ៍ដូចថា ប្រពន្ធរបស់ អឿន <លេខា>កងពល៣១០ហ្នឹង តើពួកគាត់ហ្នឹងមានអីកើតឡើង ក្រោយពេលដែលមេបញ្ជាការនោះត្រូវបានគេចាប់ខ្លួន<ទៅនោះ>?

**ឆ៖** ខ្ញុំពេលនុំង អត់ដឹងដែរ គ្រាន់តែឮតគ្នាថា ប្រពន្ធមេបញ្ជាការហ្នឹង គេចាប់អស់ដែរហើយយកទៅជាមួយប្ដីដែរ បាទ។

[១៥:១១:៤០]

**ស៖** មុននេះ ខ្ញុំបានផ្ដល់នូវកំណត់ហេតុស្ដាប់ចម្លើយ<ពី ក.ស.ច.ស.>របស់ពេទ្យ<យោធាម្នាក់>ទៀត ដែលធ្វើការជាមួយលោកដែរ នៅមន្ទីរពេទ្យព្រះកេតុមាលា គឺឈ្មោះ យ៉ន។ ហើយខ្ញុំសូមអាននូវកិច្ចសម្ភាសន៍មួយនេះ គឺ <E3/5497>, ខ្មែរមានលេខ 00343724 ដល់726, បារាំងមានលេខ 00411790 ដល់ 791 ហើយអង់គ្លេសមានលេខ 00345959។ ហើយនេះ គឺជាអ្វីដែល យ៉ន បានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍ជាមួយ<>សហចៅក្រមស៊ើបអង្កេត។ គាត់បាននិយាយអំពីមន្ទីរពេទ្យ។ “សំណួរ៖ តើ សូ ដែលជាប្រធានមន្ទីរពេទ្យនៅរស់រានទេពីរបបនោះ? ឆ្លើយ៖ សូ នៅធ្វើជាប្រធានមន្ទីរពេទ្យ រហូតដល់ចុងឆ្នាំ៧៦។ ខ្ញុំឮថាក្រោយមកទៀត គាត់ត្រូវបានគេបញ្ជូនទៅរៀនសូត្រ ហើយបាត់ខ្លួន។ ក្រោយពេល សូ បាត់ខ្លួន រឿន ដែលជា<>នារីម្នាក់នោះបានក្លាយទៅជាប្រធានមន្ទីរពេទ្យ។ គាត់គឺជាប្រពន្ធរបស់ អឿន <ដែលជាមេបញ្ជាការកងពល៣១០> គឺគេនិយាយប្រាប់គ្នាថា សូ ត្រូវបានចាប់ខ្លួនដោយអង្គការ។ ក្រោយពេល<គេចាប់> សូ <ទៅ> បុគ្គលិកពេទ្យ ត្រូវបានគេចាប់ខ្លួនម្ដងម្នាក់<ៗ>ជាបន្តបន្ទាប់<ដែរ>។” ហើយខ្ញុំអានបន្តទៅទៀត៖ “នៅពេលដែល អឿន ដែលជាមេបញ្ជាការកងពល៣១០ ត្រូវបានចាប់ខ្លួន រឿន ដែលជាប្រពន្ធរបស់ អឿន ហើយនិងជាប្រធានមន្ទីរពេទ្យអង្គខ្លួងហ្នឹង ក៏ត្រូវបានគេចាប់ខ្លួនផងដែរ ក្រោយពេលដែល<>គេចាប់ខ្លួន <អឿន ហើយ>នោះ។” ខ្ញុំសូមបញ្ចប់ការដកស្រង់។

តើលោកចាំអំពីប្រពន្ធមេបញ្ជាការកងពល៣១០ឈ្មោះ អឿន ទេ? ហើយតើលោកដឹងថា គាត់ធ្លាប់ធ្វើការជាប្រធានមន្ទីរពេទ្យរបស់កងពល៣១០ដែរទេ?

**ឆ៖** ពេលនុ៎ង គាត់ធ្លាប់ធ្វើប្រធានមន្ទីរពេទ្យកងពល៣១០ដែរ បាទ។

[១៥:១៤:៣៥]

**ស៖** តើលោកធ្លាប់ជួបគាត់ទេ?

**ឆ៖** ពេលនុ៎ងដែលជួបគាត់ដែរ ទាស់គាត់អ្នកធំ ខ្ញុំជាបុគ្គលិកតូចតាច អត់ដែលហ៊ានទៅនិយាយលែងស្តីជាមួយគាត់ទេ បាទ។

**ស៖** អរគុណលោកសាក្សី។

ដើម្បីជាកំណត់ត្រាប្រតិចារឹក លោក លោកស្រីចៅក្រម គឺលេខ ៦៩៦១ – គឺលេខ ៦៩៦១ នៅលើបញ្ជីស-២១ របស់ ក.ស.ច.ស គឺឈ្មោះ ព្រំ ញ៉ ហៅ វឿន ដែលគេកំណត់ថាជាប្រពន្ធរបស់ អឿន ហើយនិងជាប្រធានក្រុមកុមារនៅក្នុងកងពល៣១០ បានចូល ស-២១ នៅថ្ងៃ២៦ ឬក៏២៧ កុម្ភៈ ៧៧។

លោកសាក្សី ឥឡូវនេះខ្ញុំចង់និយាយអំពីការចាប់ខ្លួនលោកផ្ទាល់<វិញម្តង។> មេធាវីការពារក្តីបានសួរលោកនូវសំណួរមួយចំនួនអំពីការចាប់ខ្លួនលោក ហើយខ្ញុំនឹងសួរបន្តបន្ថែមទៀត។ លោកបានផ្តល់សក្ខីកម្មថា លោកត្រូវបានគេចាប់ដាក់ឡាន ហើយយកទៅ<មន្ទីរ>មួយដែលលោកនៅទីនោះប្រហែលជាពីរបីថ្ងៃ។ ក្នុងពេលដែលលោកស្នាក់ទីនោះពីរបីថ្ងៃហ្នឹង តើគេមានដាក់ខ្នោះជើង ឬក៏ដាក់ខ្នោះដៃ ឬក៏គេមានចងលោកដែរទេ?

**ឆ៖** គេឃុំខ្លួនអត់ឲ្យដើរទៅណា ឲ្យនៅមួយកន្លែង គេថាចាំអង្គការគេមកប្រជុំ នឹងយកមិត្តទៅហើយ។ អ៊ីចឹងគេអត់ឲ្យខ្ញុំដើរទៅណាទេ ព្រោះឲ្យនៅមួយកន្លែងហ្នឹងបាទ។

[១៥:១៦:៣៨]

**ស៖** ខ្ញុំយល់<ហើយ>ថាគេឲ្យលោកនៅទីនោះ ប៉ុន្តែខ្ញុំចង់សួរថា គេមានដាក់ខ្នោះដៃ ឬក៏គេមានចងលោកដែរឬទេ នៅពេលដែលលោកនៅក្នុង<មន្ទីរ>ហ្នឹង រង់ចាំអង្គការនោះ?

**ឆ៖** គេចាក់នៅក្នុងបន្ទប់ អត់ឲ្យដើរទៅណាមកណា គេចាក់សោជាប់បាទ។ តែគ្រាន់តែសោបន្ទប់វាមានទ្វារបង្អួចដែក គេឲ្យយើងមើលក្រៅឃើញ តែគេអត់ឲ្យទៅណា ចេញអត់រួចទេ។

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវសម្រង់កិច្ចសម្ភាសន៍ពីមជ្ឈមណ្ឌលឯកសារកម្ពុជា E3/7537, ខ្មែរមានលេខ 00019647 ដល់ 48, បារាំងមានលេខ 00291005 ដល់ 06, ហើយអង់គ្លេស គឺ 0025

1255។ នេះគឺជាអ្វីដែលលោកឆ្លើយនៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា "សំណួរ៖ នៅពេលដែលលោកមកដល់គុកហ្នឹង តើគេមានភ្ជង់កាំភ្លើងទេ? ឆ្លើយ៖ អត់ទេ គេអត់មានភ្ជង់កាំភ្លើងទេ។ គេសួរខ្ញុំថា មិត្តឯងធ្វើការមានបង្កប់ខ្សែយួនទេ គេហៅកា.ហ្យេ.បេ។ ដល់ពេលនោះ ខ្ញុំថា ខ្ញុំគ្រាន់តែព្យាបាលឲ្យ ខ្ញុំអត់មានខ្សែអីទេ។ រួចទៅគេសួរថា អ្នកឯងមានទទួលការបំពាក់បំប៉នអីទេ ខ្ញុំថា ខ្ញុំអត់មានបំពាក់បំប៉នអីទេ គ្រាន់តែថាមេគេឲ្យធ្វើអី ខ្ញុំធ្វើអ៊ីចឹងទៅ"។ ហើយបន្តមកទៀត នៅខាងក្រោមបន្តិច៖ "ខ្ញុំដេកនៅទីនោះមួយយប់ ហើយនៅព្រឹកឡើងគេមកដល់។ គាត់អះអាងថា មិត្តហ្នឹងគ្មានសកម្មភាពខូចដល់បក្សយើងទេ គេនិយាយអ៊ីចឹងណ៎ា។ ខ្ញុំក៏អត់ចាប់អារម្មណ៍ថាមកកន្លែងគុកកន្លែងអីដែរ ស្មានថាគ្រាន់តែផ្លាស់មកកន្លែងហ្នឹង។ សំណួរ៖ គេអត់មានដាក់ខ្នោះដាក់អីទេ? ឆ្លើយ៖ អត់ទេ គ្រាន់តែថាបាយទឹកអី គេអត់យកចិត្តទុកដាក់យើង។ មួយថ្ងៃហ្នឹងអត់បាយ ហើយមិនដឹងថាហូបឯណា។ ចំពោះពួកគេវិញ គេទៅហូបទៅ ចំណែកយើងចេះតែអង្គុយចាំមើលទៅ ថាតើគេផ្លាស់ទៅណា។ រួចដល់ពេលល្ងាចស្អែកឡើង បានឃើញ តាយ៉ាត ទៅ។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិចលោកសាក្សី តើត្រឹមត្រូវទេ ដែលថាគេអត់មានផ្តល់អាហារអីឲ្យលោកទេ នៅពេលដែលលោកនៅការិយាល័យហ្នឹង? ហើយអ្នកដែលធ្វើការនៅការិយាល័យហ្នឹង គេចេញទៅក្រៅទៅ នៅពេលដែលគេទៅហូបបាយហ្នឹង គេទុកលោកចោលនៅកន្លែងនុ៎ង។ តើអ៊ីចឹងមែនទេ?

[១៥:១៩:៥៩]

**ឆ៖** ពេលនុ៎ងគេទុកអ៊ីចឹងមែនបាទ ព្រោះគេអត់មានរវីរវល់នឹងយើង បាទ។ ហើយខ្ញុំអត់មានចាប់ភ្លឹកថាគេនឹងយកមកដាក់កន្លែងហ្នឹង ក៏មិនដឹងថាគេយកមកធ្វើអី។ បាយក៏គេអត់គិតគូរ។ ពេលនុ៎ងនៅបាយរួម ព្រោះគេមានបាយរបប។ កាលណាយើងទៅ គេមិនយកឲ្យយើង យើងមានបាយណាហូបជំនាន់នុ៎ង សុទ្ធតែបាយរបបរៀងខ្លួន មួយចានៗ បាទ។

**ស៖** ហើយលោកនិយាយពីរបីដងនៅក្នុងពេលផ្តល់សក្ខីកម្មហ្នឹងថា លោកអត់ដឹងថា លោកមកការិយាល័យគុកទេ គឺលោកនិយាយថា ពេលដែលខ្ញុំអានអម្បាញ់មិញហ្នឹងគឺលោកគិតថា លោកត្រូវបានគេផ្ទេរមកធ្វើការនៅកន្លែងថ្មីប៉ុណ្ណោះ។ អ៊ីចឹងមានន័យថា ក្នុងពេលពីរបីថ្ងៃហ្នឹង ដែលលោកនៅទីនោះ លោកគិតថាគេផ្លាស់លោកមកការិយាល័យថ្មី ដើម្បីធ្វើការ។ ហើយលោកអត់ដឹងថា លោកមកការិយាល័យគុកនោះទេ រហូតដល់ពេល យៀត មកបង្ហាញខ្លួន អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពេលនុ៎ង យៀត មកបង្ហាញខ្លួន ពេល យៀត ហ្នឹងដោះទៅ បាន យៀត ហ្នឹងនិយាយ

ប្រាប់ បានដឹងខ្លួន បាទ។

[១៥:២១:៣៦]

**ស៖** នៅពេលដែលគេដោះលែងលោកពីទីនោះ តើលោកត្រឡប់ទៅកងរបស់លោកវិញដោយរបៀបណា? តើលោកទៅជាមួយ យៀត ឬមួយក៏លោកទៅផ្សេងពីគ្នាទេ? ដូច្នេះខ្ញុំចង់ដឹងថា តើនៅពេលដែលគេដោះលែងលោកហ្នឹង លោកធ្វើដំណើរត្រឡប់ទៅវិញដោយរបៀបណាដែរ?

**ឆ៖** ពេលដែលត្រឡប់ទៅវិញហ្នឹង យៀត ហ្នឹងគាត់មកដោះស្រាយ។ បងយៀត ហ្នឹងគាត់ឌុបយកទៅវិញ បាទ។

**ស៖** តើ <យៀត មកយកលោកហ្នឹងនៅពេលណា? គឺថាពេលថ្ងៃ ឬពេលយប់?>

**ឆ៖** ពេល បងយៀត មកយកហ្នឹង គាត់មកយកពេលថ្ងៃត្រង់។ ថ្ងៃត្រង់ហ្នឹង ពេលគាត់ទម្រាំដោះស្រាយចេញ ម៉ោងបីរសៀល បានគាត់ឌុបទៅវិញ បាទ។

**ស៖** ដូច្នេះនៅពេលដែលលោកចាកចេញនៅម៉ោងបីរសៀលហ្នឹង តើលោកអាចរៀបរាប់ <បាន>ទេថា អគារ ក៏ដូចជាបរិវេណកន្លែងនុ៎ង វាមើលវាមានលក្ខណៈបែបណាដែរលោក នៅពេលដែលលោកចាកចេញនៅម៉ោងបីហ្នឹង? <>

[១៥:២៣:២៤]

**ឆ៖** មើលទៅកន្លែងអគារនុ៎ង មើលទៅគួរឲ្យខ្លាច ព្រោះកន្លែងនុ៎ង វាអត់មានកន្លែងល្អល្វេរដូចកន្លែងគេដទៃ សុទ្ធតែមានសោ មានទ្វារ បាទ។

**ស៖** ខ្ញុំសូមអាននូវកិច្ចសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត គឺកិច្ចសម្ភាសន៍របស់លោកផ្ទាល់នុ៎ង គឺនិយាយអំពីពេលវេលាដែលគេចាប់លោកដាក់ការិយាល័យគុកនោះ គឺឯកសារ E3/7877, ខ្មែរមានលេខ 00342436 ដល់ 437, បារាំងមានលេខ 00411785, អង់គ្លេសមានលេខ 00346979 គឺលោករៀបរាប់ដូចតទៅនេះ អំពីពេលវេលាដែលលោកត្រូវបានគេចាប់ខ្លួននោះ។ ខ្ញុំសូមដកស្រង់៖ "នៅពេលនោះ ខ្ញុំរស់នៅអន្លង់ក្ងាន មានឡានមួយមកដឹកខ្ញុំទៅ ជាឡានធុនតូចបិទឃ្លុបជិត ឡាន៤x៤ របស់អាមេរិក មិនមានស្លាកទេ។ ពេលឡើងលើឡានហ្នឹង នោះគេមិនមានចងខ្ញុំទេ ពេលមកដល់បឹងបាយ៉ាប ឡានបានដឹកមនុស្សបន្ថែមពីរនាក់ទៀត។ គេដឹកពួកខ្ញុំមកដក់នៅការិយាល័យមួយ ខ្ញុំមិនស្គាល់ការិយាល័យនោះទេ។" សូមបញ្ចប់ការដកស្រង់។ នៅពេលដែលលោកផ្តល់ចម្លើយដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត លោកមិនបាននិយាយទួលស្តែងទេនៅក្នុងការសម្ភាសនោះ ប៉ុន្តែ

គឺថា នៅក្នុងអ្វីដែលខ្ញុំទើបតែអានហ្នឹង លោកមិនដឹងថា<មន្ទីរ>ដែលគេឃុំខ្លួនពីរបីថ្ងៃហ្នឹង<ជាមន្ទីរអ្វីនោះទេ>។ តើវាជាការត្រឹមត្រូវទេដែលថាលោកមិនដឹង? ថាតើការិយាល័យហ្នឹងដែលការិយាល័យដែលលោកស្នាក់នៅពីរបីថ្ងៃហ្នឹងជាការិយាល័យអ្វី តើអ៊ីចឹងមែនទេ?

[១៥:២៦:០៧]

**ឆ៖** ពេលនុ៎ងគួរឲ្យខ្ញុំសង្ស័យ ព្រោះគេអត់មានប្រើយើង គេអត់មានរវីរវល់យើង អ៊ីចឹងខ្ញុំនឹកថាខ្លួនខ្ញុំត្រូវមានទោសហើយ ព្រោះគេ ព្រោះខ្ញុំ ក្នុងកងពលហ្នឹងសុទ្ធតែកងពលក្បត់ផង គេទុកខ្ញុំថាជាអ្នកក្បត់ដែរហើយបាទ។

**ស៖** ហេតុផលដែលខ្ញុំសួរលោកអំពីបញ្ហានេះ ព្រោះថា ខ្ញុំចង់ឲ្យលោកបញ្ជាក់ <>ពីម្សិលមិញ គឺគេសួរលោក ដោយគេអាននូវសម្រង់ពីការសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកនិយាយអំពីទួលស្លែង។ ហើយមេធាវីការពារក្ដីបានសួរថា ហេតុអ្វីបានជាលោកឆ្លើយថា លោកនៅទួលស្លែងហ្នឹង គឺថាជាចម្លើយ លោកឆ្លើយថាអ៊ីចេះ កាលពីម្សិលមិញនេះ។ គឺលោកឆ្លើយដូចគ្នានៅថ្ងៃនេះផងដែរ។ “ក្រោយពេលដែលគេដាក់នៅក្នុងគុក អ្នកដែលត្រូវបានចោទប្រកាន់<ពី អុល>ទាំងអស់ហ្នឹងត្រូវបានគេបញ្ជូន<បន្ត>ទៅទួលស្លែង” សូមបញ្ចប់ការដកស្រង់។ តើខ្ញុំយល់ត្រឹមត្រូវទេដែលថា កន្លែងដែលលោកនៅហ្នឹង កន្លែងដែលគេឃុំខ្លួនលោកហ្នឹង គឺជាកន្លែង<ដែល> អុល <គ្រប់គ្រងនោះ>មិនមែនជាការិយាល័យទួលស្លែងទេ គ្រាន់តែថាអ្នកដែលនៅកន្លែងហ្នឹងមួយចំនួនត្រូវបានគេបញ្ជូនបន្តទៀតទៅទួលស្លែង។ តើខ្ញុំយល់អ៊ីចឹងវាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពាក្យហ្នឹងត្រឹមត្រូវ ព្រោះទៅទួលស្លែង គេមិនមែនចាប់យកទៅដល់តែម្ដងទេ ព្រោះគេចូលកន្លែងហ្នឹងសិន បានគេបញ្ជូនទៅដល់កន្លែងនុ៎ងបាទ។

[១៥:២៨:២១]

**ស៖** បាទ ខ្ញុំសូមសួរបញ្ជាក់ឲ្យបានច្បាស់ពីចំណុចនេះ។

បាទ លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញរូបថតមួយ គឺរូបថតបង្ហាញពីជញ្ជាំងនៃគុកទួលស្លែង ឯកសារ E3 គឺ E3/8063.95 បាទ យើងសូមការអនុញ្ញាតបង្ហាញឯកសារនេះជូនទៅសាក្សី និងសូមបញ្ចាំងនៅលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយផ្នែកសោតទស្សន៍ចាក់បង្ហាញនូវឯកសារអម្បាញ់មិញនេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់សហព្រះរាជអាជ្ញារងអន្តរជាតិ។

*(ការបង្ហាញឯកសារជារូបភាព)*

**សួរដោយលោក ខេល លីសាក់៖**

**ស៖** នៅក្នុងរូបថតដែលលោកកំពុងមើលនេះ គឺថានៅម្ខាង គឺយើងឃើញ<របងជញ្ជាំងស័ង្កសី> ហើយខាងស្ដាំមានរបង<>ដែក ហើយក្នុងចន្លោះហ្នឹង គេមានដាក់បន្លាលួស។ សំណួរខ្ញុំសួរថា មន្ទីរគុកដែលគេឃុំឃាំងលោកពីរបីថ្ងៃហ្នឹង តើវាជាបរិវេណដែលមានរបង មានបន្លាលួស ដូចគ្នាអ៊ីចឹង ឬក៏យ៉ាងណា?

**លោក នួន ត្រិច៖**

**ឆ៖** ពេលគេឃុំខ្លួនខ្ញុំពីរបីថ្ងៃនុ៎ង គឺរបងដែកទេ អត់ដាក់របងលួសទេ។ តែរបងដែកហ្នឹងសន្តិសុខគេយាមជុំវិញ បាទ ទាហានយោធាគេយាមជុំវិញ គេអត់ឲ្យយើងដើររហេតរហូត បាទ។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែសំណួរខ្ញុំសួរថា -- សំណួរខ្ញុំសួរអ៊ីចេះ ថាតើលោកមានបានឃើញលួសបន្លា តើលោកមានឃើញរបងគុកហ្នឹង វាមានពីរជាន់អ៊ីចឹង មានរបងខាងក្រៅ ខាងក្នុង ហើយនៅចន្លោះរបងទាំងពីរហ្នឹង គឺមានដាក់លួសបន្លា។ លោកមានឃើញអ៊ីចឹងទេ?

**ឆ៖** ពេលគេយកទៅហ្នឹង អាហ្នឹងកន្លែងខ្ញុំការិយាល័យហ្នឹង អត់មានរបងទេ។ គេមានតែរបងនេះជុំវិញ គេចាក់សោ ហើយនិងយោធាគេនៅយាមជុំវិញ។ អារបងលួសហ្នឹង ទាល់តែទៅកន្លែងគុកទួលស្លែងបានមាន បាទ។

[១៥:៣១:៣៤]

**ស៖** តើលោកចង់និយាយថាម៉េច ពេលដែលលោកនិយាយថា គេបញ្ជូនលោកទៅទួលស្លែង? ឥឡូវនេះ យើងខ្ញុំកំពុងតែសួរលោកអំពីមន្ទីរគុកដែលគេឃុំឃាំងលោកពីរបីថ្ងៃ? បើខ្ញុំយល់មិនច្រឡំទេ គឺមិនមានរបងដូចនេះទេ។ មិនមានរបង ហើយមានលួសបន្លាព័ទ្ធជុំវិញអ៊ីចឹងទេ<នៅមន្ទីរដែល អុលគ្រប់គ្រងហ្នឹង> អ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់មានទេ ព្រោះកន្លែងហ្នឹងគ្រាន់តែគេមកធ្វើប្រវត្តិរូបយើង ឆ្អាលនឹងបញ្ជូន បាទតែអត់ទាន់មានបន្លាលួសឲ្យយើងដឹងខ្លួនទេ បាទ។

**ស៖** មេធាវីការពារក្ដីបានសួរលោកកាលពីម្សិលមិញហើយ ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់។ ក្រោយរយៈពេល២ថ្ងៃនៅឯមន្ទីរគុក ដែល<គ្រប់គ្រងដោយ> អុល<> តើ<>ក្រោយពេលរបបនោះ ដួលរលំ

ទៅ <>លោកមានដែលមានពេលណាមួយមកបានមើលទួលស្លែងដែរទេ?

**ឆ៖** អត់ដែលបានមកទេ ព្រោះតាំងពីនុ៎ងមក ខ្ញុំទៅរស់នៅស្រុកឆ្នាំ៧៩ ដែលវៀតណាមវ៉ៃដាច់ហ្នឹង ខ្ញុំត្រឡប់ទៅស្រុកវិញ មិនដែលមកឃើញគុកទួលស្លែងទេ។ មិនដែលឃើញទេ ទើប -- បើមកមកត្រឹមទីក្រុងភ្នំពេញម្តងយាមទេ បាទ។

**ស៖** ខ្ញុំសួរបញ្ជាក់ឲ្យច្បាស់បន្ថែមទៀត។ បើខ្ញុំយល់មិនច្រឡំ នៅពេល យៀត មកទទួលយកលោកពីមន្ទីរ<របស់ អុល>។ គឺថាគាត់យកឡានមកដឹកលោកចេញពីមន្ទីរ<របស់ អុល> ត្រឡប់ទៅកងរបស់លោកវិញ។ អ៊ីចឹងមែនទេ?

[១៥:៣៣:៤៥]

**ឆ៖** បាទ គាត់យកទៅកន្លែងហ្នឹងវិញ បាទ។

**ស៖** នៅក្នុងកំណត់ហេតុជាមួយសហចៅក្រមស៊ើបអង្កេត ដែលខ្ញុំអានឲ្យស្តាប់ប៉ុន្មាននាទីមុននេះ នៅពេលដែល<មានឡានធំមួយ>មកយកលោក <គឺលោកនៅកន្លែងមួយឈ្មោះថា>"អន្លង់ក្ងាន"។ តើអន្លង់ក្ងាន នៅឯណា<> ហើយ<>លោកធ្វើអ្វីដែរមុនពេលគេចាប់ខ្លួនលោកនុ៎ង?

**ឆ៖** នៅអន្លង់ក្ងានហ្នឹង ពេលនុ៎ង ពេលខ្ញុំចាប់ខ្លួនខ្ញុំហ្នឹង ខ្ញុំនៅជាពេទ្យព្យាបាលនៅកន្លែងតាមមន្ទីរអន្លង់ក្ងាន ឃ្លួញ កប់ស្រូវ ដើរព្យាបាលពួកយោធា គេនៅធ្វើស្រែ ខ្លះនៅកិនម៉ាស៊ីន ខ្លះទៀត គេខាងបើកអង្ករអីឲ្យយោធា។ បាទ ពេលនុ៎ង ខ្ញុំនៅធ្វើជាពេទ្យនៅឡើយទេ បាទ។

**ស៖** តើលោកអាចប្រាប់ទីតាំងអន្លង់ក្ងាននេះបានទេ តើអន្លង់ក្ងាននៅក្នុងទីក្រុងភ្នំពេញ ឬក៏នៅជាយក្រុងភ្នំពេញ?

**ឆ៖** អន្លង់ក្ងានហ្នឹង បើភស្តុភារវរសេនាតូច៣១៤ហ្នឹង ភស្តុភារប្រចាំធំនៅក្នុងទីក្រុងភ្នំពេញ តែកន្លែងសាខាគេធ្វើការគ្រប់កន្លែងហ្នឹងចាប់ពីភូមិមេម៉ាយរហូតដល់បឹងបាយ៉ាបនិងកប់ស្រូវ។ កប់ស្រូវគេដាក់ម៉ាស៊ីនអារឈើ ហើយអន្លង់ក្ងានគេដាក់ម៉ាស៊ីនស្រូវសម្រាប់បើកឲ្យយោធាបាទ។

[១៥:៣៦:០៩]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ អន្លង់ក្ងាននេះ គឺជាកន្លែងដែលគេបញ្ជូនយុទ្ធជនពីកងពល៣១០នោះទៅឲ្យធ្វើស្រែមែនទេ? តើកន្លែងនេះជាកន្លែងតែមួយជាមួយនឹងបឹងបាយ៉ាបដែរទេ?

**ឆ៖** អន្លង់ក្ងានហ្នឹងវាទៅហួសបឹងបាយ៉ាប តែវាជាប់ក្នុងបឹងបាយ៉ាបដែរ ព្រោះកងពល៣១០ហ្នឹងចុះធ្វើស្រែ ធ្វើចម្ការម្តុំត្រង់ហ្នឹង រហូតដល់កប់ស្រូវបាទ។

**ស៖** សូមអរគុណលោកដែលបានបញ្ជាក់ចំណុចនេះ។ ឥឡូវនេះ ខ្ញុំទៅសួរលោកអំពីព្រលានយន្តហោះកំពង់ឆ្នាំង គឺថាជាទីកន្លែងដែលលោកបានផ្តល់សក្ខីកម្មថា គេបញ្ជូនលោកទៅការដ្ឋាននោះ គឺនៅពេលក្រោយគេចាប់ខ្លួនលោក។ លោកក៏បានឆ្លើយផងដែរថា គេបានប្រាប់លោក ថាគេបញ្ជូនលោកទៅហ្នឹងគឺជាកន្លែងលត់ដំអប់រំ បើតាមដែលលោកយល់នោះ ហើយគេប្រាប់លោកថាគេបញ្ជូនលោកទៅកំពង់ឆ្នាំងទៅកន្លែងលត់ដំនោះ តើ<>បើតាមការលោកយល់ហ្នឹង បញ្ជូនទៅកន្លែងលត់ដំហ្នឹងគឺចង់ថាយ៉ាងម៉េចដែរ?

**ឆ៖** គេបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងកន្លែងហ្នឹងកន្លែងលត់ដំ គេថាឲ្យយើងកសាងខ្លួនឲ្យបានផុតពីសេចក្តីស្លាប់ បើយើងទៅលត់ដំមានការមិនលត់ដំ មិនយកចិត្តទុកដាក់ បើយើងយកជើងដៃដាច់ដៃ យកជើងរាដាច់ជើង ព្រោះកន្លែងហ្នឹងគេថាកងចក្រកំពុងតែវិល។ អ៊ីចឹងយើងត្រូវតែការលត់ដំឲ្យជាប់ កុំឲ្យហ៊ានមាត់ គិតតែពីរឿងធ្វើការបាទ។

**ស៖** <>សរុប<>ទាំងអស់ទៅ<តើលោកធ្វើការ>នៅឯការដ្ឋានកំពង់ឆ្នាំង <>បានប៉ុន្មានខែដែរ?

[១៥:៣៨:៤៧]

**ឆ៖** បាន៣ខែបាទ នៅលត់ដំកន្លែងហ្នឹងបាន៣ខែ។ ៣ខែបានគេថាវៀតណាមចូលវ៉ៃប្រទេសកម្ពុជាហ្នឹង ក៏គេថាអ្នកដែលលត់ដំទាំងប៉ុន្មានហ្នឹងកសាងខ្លួនបានហើយ។ អ៊ីចឹងយើងត្រូវទៅបំពាក់អាវុធវ៉ៃកងទ័ពវៀតណាម គេថាកងទ័ពវៀតណាមឈ្លានពានប្រទេសកម្ពុជាបាទ។

**ស៖** អំឡុងពេល៣ខែ ដែលលោកបានលត់ដំខ្លួននៅឯការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង តើវានៅក្នុងឆ្នាំ១៩៧៧ ឬ៧៨?

**ឆ៖** លត់ដំនៅក្នុង១៩៧៨។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ ថាគេតម្រូវឲ្យលោកធ្វើការងារអ្វីដែរនៅឯការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងរយៈពេល៣ខែនោះ?

**ឆ៖** នៅកំពង់ឆ្នាំងនុ៎ង គេធ្វើព្រលានយន្តហោះនុ៎ង គេឲ្យយើងជីក ហើយនិងដុតថ្មនភ្នំ ដើម្បីគេឲ្យលុងថា ធ្វើកប៉ាល់ហោះចម្បាំង សម្រាប់វ៉ៃខ្មាំង។ ដុតថ្មនហ្នឹង យើងទៅដាប់ថ្មននុ៎ង ដាប់ៗថ្មហ្នឹងដាក់ថ្មន។ ហើយក៏ខ្លះជីក ដូចជាមានសំរាមនៅក្នុងដី១០ម៉ែត្រអីហ្នឹង ប៉ុនកូនដៃ ក៏គេឲ្យជីកយកចេញដែរ។ គេថា ខ្លាចក៏ប៉ាល់ហោះចុះទៅស្រុត បាទ។

**ស៖** លោកបានបញ្ជាក់ថា កិច្ចការមួយរបស់លោកគឺ<ដាក់>ឆ្នូន<បំផ្ទុះ>ដើម្បីយកថ្ម។ តើលោកហ្នឹងជាអ្នក<បំផ្ទុះ>ហ្នឹងដោយផ្ទាល់ដែរឬ?

**ឆ៖** មានមិត្តគេអ្នកចេះដុត ខ្ញុំគ្រាន់តែអ្នកដាប់ថ្មទេ អង្គុយដាប់ថ្ម ដើម្បីញាត់ឆ្នូនហ្នឹងចូលក្នុងរន្ធថ្មហ្នឹង បាទ។

[១៥:៤១:៥០]

**ស៖** អ៊ីចឹងលោកគឺជាអ្នកដាប់ថ្ម ហើយប្រហោងដែលលោកដាប់ហ្នឹង គឺគេយកឆ្នូនទៅដាក់ក្នុងហ្នឹង ដើម្បីបំផ្ទុះវា។ តើ<>ការផ្ទុះហ្នឹង វាផ្ទុះក្នុងរបៀបម៉េចដែរ<>?

**ឆ៖** ពេលដុតទៅ វាផ្ទុះដូចគ្រាប់បែកដែរ បាទ។ បើអ្នកណានៅជិត ត្រូវអំបែងថ្មហ្នឹងរបួសដូចយើងគ្រាប់បែកអ៊ីចឹង បាទ។

**ស៖** លោកបានឆ្លើយថា នៅពេលដែលលោកដុតហ្នឹង តើឆ្នូនហ្នឹង គេមាន១ជារំសេវនៅក្នុងហ្នឹង <ហើយលោកដុតវាទៅ តើលោកបំ>ផ្ទុះ<វាដោយ>របៀបហ្នឹង<ឬ>?

**ឆ៖** មានជាតិរំសេវនៅក្នុងហ្នឹង បាទ។

**ស៖** តើពលករ<>ដែលធ្វើការនៅទីហ្នឹង<> បានទទួលរងរបួស ឬក៏ស្លាប់ដោយសារការបំផ្ទុះឆ្នូនហ្នឹង <ញឹកញាប់>ដែរទេ?

**ឆ៖** ពេលនុ៎ង ខ្លះកំពុងតែជីកដី មិនបានចាប់ភ្លឹក ខ្លះក៏ត្រូវនឹងអំបែងថ្ម មានរបួសធ្ងន់ ខ្លះក៏មានគ្រោះថ្នាក់ជាច្រើន ដោយសារនឹងឆ្នូនផ្ទុះហ្នឹង មិនបានចាប់ភ្លឹក។ បើអ្នកគេដុត គេនឹងរត់ក្រាប។ បើអ្នកដែលធ្វើការនៅក្បែរគ្នា គ្នាអត់បានដឹង ក៏ត្រូវផ្ទុះត្រូវ បាទ។

**ស៖** នៅក្នុងអំឡុងពេល៣ខែ ដែលលោកនៅ<ធ្វើការ>ទីនោះ តើលោក<>ចំណាយពេលវេលាប៉ុន្មាន <ក្នុងការដាប់>ថ្មដាក់ឆ្នូនហ្នឹង<>?

[១៥:៤៤:២៧]

**ឆ៖** ធ្វើពីម៉ោង បើព្រលឹមឡើង ធ្វើពីម៉ោងបួន បាទ ម៉ោងបីក្រោកប្រជុំ។ ម៉ោងបួន គេឲ្យចូលទៅធ្វើការដុតឆ្នូនហ្នឹង រហូតដល់ទល់ម៉ោងពីរដណ្តប់ថ្ងៃត្រង់ បាទ។

**ស៖** អ្វីដែលខ្ញុំចង់ស្វែងយល់នោះ តើនេះជាការងារដែលលោកធ្វើរាល់ថ្ងៃក្នុងរយៈពេល៣ខែនៅឯព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹង ឬក៏ថាការបំផ្ទុះថ្មហ្នឹងដែលគេដុតឆ្នូនហ្នឹង គេធ្វើតែក្នុងពេលណាមួយទេ<តែប៉ុណ្ណោះ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អាហ្នឹងតាមមេគេចាត់ ជួនកាលត្រូវវេនខ្ញុំ គេឲ្យ ជួនកាលវេនឲ្យទៅជីក គេចាត់តាំង មេគេចាប់តាំងឲ្យទៅជីកដីព្រលានយន្តហោះ ជីក។ ខ្លះគេឲ្យទៅវ៉ៃថ្ម ព្រោះអាហ្នឹងតាមទៅលើគេមេ គេអ្នកចាត់តាំងបាទ។

**ស៖** ខ្ញុំសូមអានឲ្យលោកស្ដាប់នូវកិច្ចសម្ភាសន៍របស់លោកគឺ E3/7877, ខ្មែរ 00342437, អង់គ្លេស 00346979, បារាំង 00411785 ដល់ 86។ នៅត្រង់នេះ លោកបានរៀបរាប់អំពីការងាររបស់លោកនៅកំពង់ឆ្នាំង សូមដកស្រង់៖ “គេបានបញ្ជូនខ្ញុំទៅកំពង់ឆ្នាំងតែម្នាក់ឯង ប្រហែលជាក្នុងឆ្នាំ ៧៨ គេឲ្យខ្ញុំជីកប្រហោងថ្មហ្នឹង ដើម្បីដាក់ៗឆ្នូនបំផ្ទុះ ដើម្បីធ្វើព្រលានយន្តហោះចម្បាំង ហើយនិងយកថ្មហ្នឹងទៅធ្វើព្រលានយន្តហោះផង។ នៅពេលដែលបំផ្ទុះហ្នឹង គឺថាមានអ្នកត្រូវរបួសហ្នឹងប្រាំ ប្រាំមួយនាក់ជាញឹកញាប់ហ្នឹង។” ខ្ញុំសូមឲ្យលោកបញ្ជាក់បន្តិច នៅពេលលោកនិយាយថាជាមធ្យមហ្នឹង គឺអ្នកត្រូវរបួសពីប្រាំទៅប្រាំមួយនាក់។ ពាក្យថាមធ្យមកន្លែងនេះ លោកសំដៅទៅលើថារងរបួស<> ដោយសារតែការបំផ្ទុះថ្មរងរបួសអីចឹង។ អីចឹងវារងរបួសរាល់ថ្ងៃ រាល់អាទិត្យ ឬរាល់ខែ?

[១៥:៤៧:២៧]

**ឆ៖** ការធ្វើហ្នឹង បើពេលដុតឆ្នូនហ្នឹង បើពេលណាដែលគេត្រូវដុតឆ្នូនច្រើន គឺមានរបួសហើយ តែបើដុតឆ្នូនតិចទេ អត់សូវមានរបួសទេ តែបើគេថាថ្ងៃហ្នឹងត្រូវផែនការថា យើងត្រូវរំលាយថ្មភ្នំហ្នឹងឲ្យខ្លាំង អីចឹងត្រូវមានរបួសហើយបាទ។

**ស៖** ខ្ញុំសូមបង្ហាញលោកនូវរូបថតពីរបីសន្លឹក គឺជារូបថតដែលបានមកពីការដ្ឋានកំពង់ឆ្នាំង។

លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតបង្ហាញជូនសាក្សី ជាមួយនឹងឯកសាររូបថត។ រូបថតទាំងនេះគឺថាជាការកំណត់ទីតាំងដោយសហចៅក្រមស៊ើបអង្កេត គឺE3/8041 – E3/8041, ខ្មែរ <00364449> និងរូបថតពីរសន្លឹកនៅលើឯកសារនេះតែម្ដង ហើយយើងខ្ញុំក៏សូមចាក់បញ្ចាំងនៅលើអេក្រង់ផងដែរ បាទ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះអនុញ្ញាត ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវឯកសារ និងរូបភាពនៅលើអេក្រង់ទូរទស្សន៍ តាមសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក ខេល លីសាក់៖**

<មានរូបថតចំនួនពីរនៅលើសន្លឹកក្រដាសដែលខ្ញុំទើបតែឲ្យលោក> សូមចាក់បញ្ចាំងរូបថតទី១

នៅលើអេក្រង់ជាមុនសិន។

*(ការបង្ហាញឯកសាររូបថត)*

**សួរដោយលោក ខេល លីសាក់៖**

**ស៖** រូបថតទី១ដែលខ្ញុំចង់សួរលោក លោកឃើញបុរសម្នាក់ចង្អុលទៅកន្លែងថ្ម កន្លែងហ្នឹងគឺគាត់ចង្អុលទៅឃើញមានថ្ម ហើយផ្ទាំងថ្មនេះគឺជាផ្ទាំងថ្មក្រោយគេ សល់ពីគេបំបែកមក។ តើលោកស្គាល់ទីតាំងនេះទេ លោកសាក្សី?

**លោក នួន ត្រិច៖**

**ឆ៖** ទីតាំងហ្នឹងដូចជាមិនមែនកន្លែងខ្ញុំធ្វើការ បាទ ដូចអត់ស្គាល់កន្លែងហ្នឹង។

**ស៖** តើលោកធ្វើការនៅទីតាំងដែលលោកបំផ្ទុះថ្មនោះ? ចុះកន្លែងដែលលោកបំផ្ទុះថ្មហ្នឹង គឺជាកន្លែងដែលគេបម្រុងធ្វើរូងសម្រាប់ដាក់យន្តហោះនោះ ឬក៏ជាកន្លែងផ្សេង?

**ឆ៖** ធ្វើនៅព្រលានយន្តហោះហ្នឹង គេធ្វើជារូងដាក់យន្តហោះនៅព្រលានទុំងតែម្តង គេលុងភ្នំហ្នឹង ដើម្បីថាដាក់កប៉ាល់ហោះចូលក្នុងហ្នឹង គេអត់ធ្វើរូងទេ។ គេថា លុងឆ្នួនទុំងឲ្យកប៉ាល់ហោះហ្នឹងធ្វើព្រលានទុំង កប៉ាល់ហោះចូលចតក្នុងទុំង បាទ។

[១៥:៥១:៥៦]

**ស៖** សំណួរដែលខ្ញុំចង់សួរនោះគឺ កន្លែងដែលគេ កន្លែងបំផ្ទុះថ្មហ្នឹងជាកន្លែងតែមួយ <>នឹងកន្លែងដែល<លោក>ជីករូងដើម្បី<ដាក់រំសេវបំផ្ទុះ>ហ្នឹងឬយ៉ាងម៉េច?

**ឆ៖** កន្លែងជីកថ្មហ្នឹង គេបន្តជាប់ពីកន្លែងព្រលានយន្តហោះទៅ ឲ្យគេអ្នកជីកធ្វើព្រលានព្រលានអ្នកដុតនេះ ភ្នំៗ ដើម្បីកាលណាព្រលានហ្នឹង គេឲ្យធ្វើឲ្យស្អាត។ គេថា ដើម្បីឲ្យកប៉ាល់ហោះចុះបាទ។

**ស៖** បាទ លោកប្រធាន សុំការអនុញ្ញាតចាក់បញ្ចាំងរូបថតទី២ នៅទំព័រដដែល គឺទំព័រឯកសាររបស់សហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/8041។ បាទ សុំបញ្ចាំងរូបថតនេះផង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** បាទ ឯកសារនេះគឺទំព័រដដែលទេលោកសាក្សី ដែលខ្ញុំបានឲ្យទៅលោកមើលនោះ។ នៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ក្នុងរូបថតនេះបុគ្គលដដែលនេះ គាត់បានចង្អុលទីជញ្ជាំងមួយកន្លែង។ ខ្ញុំចង់សួរលោកថា តើលោកមានចាំទីតាំងនេះទេ? តើលោកមានចាំទីតាំងនេះ ដែលបុរសម្នាក់កំពុងចង្អុល ហើយមានជញ្ជាំងនេះ?

**លោក នួន ត្រិច៖**

**ឆ៖** ពេលនុ៎ង--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ! បាទ សូមអញ្ជើញឆ្លើយ! ទំនងមិនមែនជញ្ជាំងទេ។ អាហ្នឹងទំនងភ្នំទេ? ជញ្ជាំងម៉េច?

[១៥:៥៤:១២]

**លោក នួន ត្រិច៖**

**ឆ៖** ពេលធ្វើនុ៎ង យកភ្នំទេធ្វើរង។ ហើយអត់យកជញ្ជាំង អត់យកថ្មហ្នឹង យកអាថ្មហ្នឹង យកមកវ៉ៃធ្វើព្រលានយន្តហោះ បាទ។ ហើយកាលមួយរឹកហ្នឹង ខ្ញុំធ្វើហ្នឹង វាមិនទាន់បានរួចទេ ព្រោះដល់ពេលគេវៀតណាមគេថាវ៉ៃទៅ គេឲ្យនាំ ឲ្យផ្លាស់ទៅវ៉ៃវៀតណាមនៅទល់ដែនវិញ បាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកនៅចាំទេថាមានភ្នំតូចមួយ និងមានជញ្ជាំងនេះ ដូចជាជញ្ជាំងភ្នំអីចេះសម្រាប់ឲ្យពលករហ្នឹងគាត់រត់<>មកបាំង<>កុំឲ្យត្រូវថ្មដែលបំផ្ទុះហ្នឹង។ លោកចាំទេ?

**ឆ៖** បើចាំៗអាកូនថ្មតូចហ្នឹងគេចង្អុលហ្នឹងបាទ អាថ្មធំហ្នឹងអត់បានចាំទេ ព្រោះពេលនុ៎ងវាមិនទាន់ធ្វើបែក។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំមានរូបថតខ្លះៗថែមទៀត ហើយរូបថតទាំងអស់នេះ គឺបានមកពីការកំណត់ទីតាំងទី៣ របស់សហចៅក្រមស៊ើបអង្កេត ជាទីតាំងមួយដែលជាប់ពាក់ព័ន្ធទៅនឹងរូងភ្នំនោះ។ គឺឯកសារ E3/8055 បាទ E3/8055។ បាទ យើងខ្ញុំក៏សូមការអនុញ្ញាតបង្ហាញឯកសារនេះទៅសាក្សីផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

*(ការបង្ហាញឯកសារជារូបភាព)*

[១៥:៥៦:៣២]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីសូមលោកបើកទៅមើលរូបថតទី២។ ហើយយើងខ្ញុំក៏សូមចាក់បញ្ចាំងនៅលើអេក្រង់ផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

*(ការបង្ហាញឯកសារជារូបភាព)*

**សួរដោយលោក ឌេល លីសាក់៖**

បាទ សូមត្រឡប់ទៅរូបថតមុនរូបថតនេះ។

**ស៖** រូបថតដែលយើងកំពុងតែឃើញនេះលោកសាក្សី នេះគឺជារូងមួយដែលគេបានបំផ្ទុះថ្មដែលនោះ គឺចាប់ផ្ដើមធ្វើតាំងពីដើមដំបូងមកម្ល៉េះ។ តើលោកនៅចាំ ឬក៏ទៅស្គាល់ទីតាំងនេះដែរឬទេ? តើនេះជាទីកន្លែងដែលៗលោកចោះថ្មដើម្បីដាក់ឆ្នូន<>បំផ្ទុះថ្មនោះឬក៏មិនមែនទេ?

[១៥:៥៨:០៦]

**ឆ៖** ទីតាំងហ្នឹងទីតាំងខ្ញុំធ្វើហើយ តែដល់មកឥឡូវខ្ញុំភ្លេចហើយ ព្រោះអង្កាល់ធ្វើៗរបៀបអ៊ីចឹង។

**ស៖** ក្នុងរយៈពេល៣ខែដែលលោកធ្វើការនៅការដ្ឋាននោះ រូងនេះដែលគេបានបំផ្ទុះថ្មនេះ លោកដឹងទេវាៗមានជម្រៅប៉ុនណាទៅ? មានជម្រៅប៉ុន្មានម៉ែត្រទៅ? តើរូងនេះជ្រៅជម្រៅប៉ុន្មានម៉ែត្រដែរ?

**ឆ៖** អង្កាល់ពេលធ្វើហ្នឹងទើបបានខ្ញុំនៅធ្វើរយៈ៣ខែហ្នឹង ទើបបានរូងហ្នឹងបានប្រហែល ១០ ម៉ែត្រជាងទេ ព្រោះវាថ្មហ្នឹងវារឹងពេក ធ្វើទាន់ ទៅអត់ទាន់រួច ទៅម្ដងតិចៗបាទ។

**ស៖** បាទ ឥឡូវនេះសូមចាក់បញ្ចាំងរូបថតបន្ទាប់មកទៀត រូបថតលេខ៣ ជារបាយការណ៍ គឺឯកសារ E3/8055 ដដែល ក៏ប៉ុន្តែមានរូបថតទី៣។ បាទ សូមចាក់បញ្ចាំងរូបថតទី៣ នេះ។

*(ការបង្ហាញឯកសារជារូបភាព)*

នេះជារូបថត ដែលមន្ត្រីស៊ើបអង្កេត គាត់បានស៊ើបអង្កេត ក្រោយពេលចូលទៅក្នុងរូងថ្មដែលយើងបានឃើញនេះ។ យើងបានឃើញពីរូបថតមុនៗមកដែរនោះ។ នៅពេលដែលលោកឈប់ធ្វើការនៅទីនោះ។ តើ<រូង>ហ្នឹង មានកម្ពស់ប៉ុន្មានម៉ែត្រដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

យើងខ្ញុំមិនជំទាស់ចំពោះការជីករូងភ្នំនៅកំពង់ឆ្នាំងនេះទេ។ ហើយច្បាស់ ខ្ញុំក៏យល់ច្បាស់ដែរ ថា

នេះគឺជារូងភ្នំនៅព្រលានយន្តហោះនៅកំពង់ឆ្នាំងហើយ។ កាលដែលសួរសាក្សីបែបនាំមុខ ឲ្យឆ្លើយអំពីរូងនេះ គឺថាមិនសមស្របទេ។ ដូចខ្ញុំបានលើកឡើងអ៊ីចឹង គឺថាគេមានជីកធ្វើរូងអ៊ីចឹងមែនទេ ប៉ុន្តែសួរនាំមុខអ៊ីចឹង មិនត្រឹមត្រូវទេ។

[១៦:០០:៥៨]

**លោក ខេល លីសាក់៖**

តាមការពិត ខ្ញុំត្រូវសួរសាក្សីអំពីដំណើរការនៃការជីករូងហ្នឹងជាបន្តបន្ទាប់ទេ។ ដូច្នេះ លោកប្រធាន តើអនុញ្ញាតឲ្យខ្ញុំសួរបន្តទៅទៀតឬ?

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី ពេលដែលលោកធ្វើការអស់រយៈពេលបីខែហ្នឹង លោកនៅចាំទេ ថារូងហ្នឹងមានកម្ពស់ប៉ុន្មានម៉ែត្រដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក នួន ត្រិច៖**

**ឆ៖** បាទ ពេលហ្នឹង ខ្ញុំភ្លេចហើយ ព្រោះយូរហើយ វាមិនបានចាំ ព្រោះបាទ ភ្លេចភ្លាំងអស់ហើយបាទ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** បាទ ខ្ញុំសូមសួរពីរបីសំណួរទៀត មុននឹងយើងបញ្ចប់នៅថ្ងៃនេះ។ លោកបានឆ្លើយថា គឺថាលោកត្រូវប្រើរំសេវ ត្រូវដុតរំសេវហ្នឹងដើម្បីបំផ្ទុះ។ តើមានរយៈពេលប៉ុន្មាន គិតចាប់ពីពេលដែលគេដុតទៅហើយ ហើយគេរត់គេចខ្លួនដើម្បីកុំឲ្យផ្ទុះត្រូវហ្នឹង? មុននឹងគ្រាប់រំសេវហ្នឹង វាផ្ទុះហ្នឹង តើគេត្រូវរត់គេចខ្លួនជាមុនប៉ុន្មាននាទីដែរ?

[១៦:០២:២៦]

**ឆ៖** ពេលដុតហ្នឹងគឺ ដុតភ្លាមហ្នឹង នាំគ្នារត់ ដល់រត់ទៅ ជួនកាលរត់ទាន់ ជួនកាលរត់អត់ទាន់បាទ។

**ស៖** ក្នុងរយៈពេល៣ខែដែលលោកធ្វើការនៅទីនោះ តើមានអ្នកធ្វើការនៅទីនោះណាម្នាក់ស្លាប់ដោយសារតែការបំផ្ទុះថ្មនេះទេ?

**ឆ៖** ខ្ញុំធ្វើការហ្នឹង ពេលស្លាប់ ឮជួនកាល ឮគេថាត្រូវចំកញ្ចឹងក មានស្លាប់ដែរ តែមិនបានឃើញនឹងភ្នែក តែគេថាមានស្លាប់។ ព្រោះពេលធ្វើហ្នឹង វាធ្វើចែកជាក្រុមៗ បាទ។

**លោក ឌេល លីសាក់៖**

លោកប្រធាន តាមការពិត ខ្ញុំត្រូវទៅសួរសំណួរស្ដីអំពីលក្ខណៈការងារទូទៅ ប៉ុន្តែតើខ្ញុំបន្តសួរសំណួរតទៅទៀតបានទេ ឬក៏ឈប់សិន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៧ ខែធ្នូ ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមនៅម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី នួន ត្រិច បញ្ចប់។ បាទ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក នួន ត្រិច សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកឱ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់កន្លែងគាត់ស្នាក់នៅ ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់ចូលរួមផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលទំនងជាតែមួយវគ្គសវនាការនៃព្រឹកស្អែកនោះទេ។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*